អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2018, 15:42
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E3/9614 | 01212340-01212433 | 22/01/2018 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំទាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| ជំនួសឯកសារមិនទាន់កែតម្រូវដោយឯកសារដែលបានកែតម្រូវរួច។ |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| |

ស្នើដោយ៖អង្គភាពបកប្រែភាសា ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

[01037039-01037060]

**១. ទស្សនទានអំពីអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណីនៅក្នុងបរិបទរបស់ប្រទេសកម្ពុជា**

ដើម្បីយល់ដឹងកាន់តែច្បាស់លាស់ពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលរៀបចំធ្វើឡើងដោយរបបខ្មែរក្រហម ផ្នែកនេះ ផ្ដល់ជូនចំណុចមួយដែលធ្វើការប្រៀបធៀបជាមួយនឹងទំនៀមទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណីរបស់ប្រទេសកម្ពុជា។ អាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណីមុនឆ្នាំ ១៩៧៥ នៅក្នុងប្រទេសកម្ពុជាត្រូវបានរៀបចំភាគច្រើនដោយមានការយល់ព្រមពីបុគ្គលដែលគេចង់ឲ្យរៀបអាពាហ៍ពិពាហ៍ និងប្រារព្ធឡើងដោយមានពិធីសាសនា (សម្រាប់ប្រជាជនដែលភាគច្រើនកាន់ពុទ្ធសាសនា ជាពិសេសពាក់ព័ន្ធនឹងឥទ្ធិពលស្ថានភាពកម្មផល) និងមានផលប៉ះពាល់ខាងយេនឌ័រខុសៗគ្នាទៅលើបុរស និងស្ត្រី។

Deleted:

សារណាឆ្នាំ ១៩៦៨ ចំនួនពីរក្បាលរបស់ Ebihara ផ្ដល់នូវការស្ទង់មតិមួយក្នុងចំណោមការស្ទង់មតិខាងនរវិទ្យាដ៏ទូលំទូលាយបំផុតនៃជីវិតតាមភូមិស្រុកនៅមុនសម័យខ្មែរក្រហម រួមទាំង ពិធីមង្គលការ និងអាពាហ៍ពិពាហ៍។ នាងរៀបរាប់អំពីពិធីមង្គលការថាជាពិធីល្អិតល្អន់ដែលមានរយៈពេលជាច្រើនថ្ងៃ ដោយបង្កប់នូវអត្ថន័យវប្បធម៌យ៉ាងស៊ីជម្រៅ៖ មង្គលការតាមលក្ខណៈប្រពៃណីដែលហៅថា “រៀបការ” គឺជា “ពិធីដែលសប្បាយរីករាយបំផុត និង (ដោយមានទាំងពីធីជាច្រើន) ខ្ជះខ្ជាយបំផុត ... ក្នុងចំណោមកម្មវិធីទាំងអស់ក្នុងជីវិត” ដែលរួមមានពិធីសាសនាដែលបានគ្រោងទុកដោយប្រុងប្រយ័ត្ន និងសម្លៀកបំពាក់ប្រពៃណីលម្អសម្រាប់កូនក្រមុំ និងកូនកំលោះ។ ពិធីនេះមានបញ្ចូលទាំងសកម្មភាពពិធីសាសនារហូតដល់ទៅ ១៣ មុខ។ មនុស្សសំខាន់ៗក្នុងការរៀបចំអាពាហ៍ពិពាហ៍ និងពិធីមង្គលការរួមមានឪពុកម្ដាយ សាច់ញាតិ មិត្តភក្ដិ ចាស់ទុំ ព្រះសង្ឃ គ្រូទាយ តន្ត្រីករ និងអ្នកភូមិ ដែលបំពេញតួនាទីផ្នែកខ្លះ ឬផ្នែកទាំងអស់នៃការធ្វើពិធីសាសនា និងការប្រារព្ធពិធីតាមលក្ខណៈវប្បធម៌។ អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងភាគច្រើនដោយឪពុកម្ដាយ ជាចម្បងគឺម្ដាយ និង “ក្នុងករណីភាគច្រើន ទំនោរចិត្ត និងសេចក្ដីប៉ងប្រាថ្នារបស់កូន [ត្រូវបាន] យកមកពិចារណា ហើយគាត់/នាង [មិនត្រូវបាន] បង្ខំឲ្យធ្វើអ្វីមួយដែលមិនត្រូវចិត្តនោះទេ”។ ត្រឡប់មកវិញ ឪពុកម្ដាយជាទូទៅបានទទួលនូវ “ការគោរព ការយកចិត្តទុកដាក់ និងភក្ដីភាពពីកូនរបស់ខ្លួន”។ ទំនាក់ទំនងអាពាហ៍ពិពាហ៍មានតាំងពីទំនាក់ទំនងនៃភាពចាំបាច់ ឬភាពងាយស្រួលរហូតដល់ “មនោសញ្ចេ-តនា និងការគោរពគ្នា” ទៅវិញទៅមកយ៉ាងជ្រាលជ្រៅ ហើយត្រូវបានបកស្រាយយ៉ាងត្រឹមត្រូវបំផុតថាជាការចងសម្ព័ន្ធរវាងគ្រួសារទាំងមូល មិនមែន

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ត្រឹមតែទំនាក់ទំនងលក្ខណៈបុគ្គលនោះទេ។ ចំណងក្រុមគ្រួសារដែលស្អិតរមួតត្រូវបានគេចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃសង្គមដែលចុះសម្រុងគ្នា[5]។

ដោយសារតែលទ្ធផលពីកម្មរបស់ខ្លួន ការចរចា និងពិធីអាពាហ៍ពិពាហ៍បែបពុទ្ធសាសនិកត្រូវមានទំនាក់ទំនងមិនត្រឹមតែសមាជិកក្រុមគ្រួសារដែលនៅមានជីវិតប៉ុណ្ណោះទេ តែថែមទាំងដូនតាផងដែរ។ Ebihara បានចង្អុលបង្ហាញពី "សារៈសំខាន់ជាខ្លាំង" នៃទំនាយរបស់គូស្វាមីភរិយា ដែលត្រូវពិនិត្យពិច័យដោយអាចារ្យ [អ្នកមានជំនឿលើសាសនា] ដើម្បីវាយតម្លៃគូព្រេងគ្នាខាងតារាសាស្ត្រ និងដើម្បីកំណត់កាលបរិច្ឆេទអាពាហ៍ពិពាហ៍ដែលវិសេសវិសាលបំផុត[6]។ LeVine ពិភាក្សាពីសារៈសំខាន់នៃកាតព្វកិច្ចខាងវប្បធម៌ក្នុងអំឡុងពិធីមង្គលការនៃការឱ្យតង្វាយទៅដល់ "ដូនតា" ដើម្បីជាមធ្យោបាយនៃការប្រទានពរដល់អាពាហ៍ពិពាហ៍[7]។ ក្រុមអ្នកស្រាវជ្រាវក៏បានចង្អុលបង្ហាញពីសារៈសំខាន់ខាងកម្មផលនៃមង្គលការ និងអាពាហ៍ពិពាហ៍ ដោយចាត់ទុកការរួមសម្ព័ន្ធគ្នាប្រកបដោយជោគជ័យថាជាសញ្ញានៃកុសលពីអតីតជាតិ និងជាមធ្យោបាយសម្រាប់បង្កើនកុសលសម្រាប់អនាគតជាតិ[8]។ ដោយសារប្រទេសកម្ពុជាគឺជាប្រទេសដែលកាន់ពុទ្ធសាសនាភាគច្រើនលើសលុប ផ្នែកសាសនាបែបនេះមានឥទ្ធិពលជាខ្លាំង។ អ្វីដែលមិនសូវត្រូវបានស្រាវជ្រាវគឺការប្រែប្រួលតាមតំបន់

---

[5] សារណារបស់ Ebihara បង្ហាញពីពិធីមង្គលការ និងទំនៀមទម្លាប់រៀបអាពាហ៍ពិពាហ៍ពីឆ្នាំ ១៩៥៩ ដល់ឆ្នាំ ១៩៦០ នៅក្នុងភូមិស្វាយ ខេត្តកណ្ដាល។ ក្រោយមក អ្នកស្រាវជ្រាវបានទៅលេងជាថ្មីនូវ ភូមិដដែលនោះក្នុងឆ្នាំ ១៩៩០-១៩៩១ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ។ May Ebihara, *ស្វាយ, ភូមិខ្មែរនៅក្នុងប្រទេសកម្ពុជា* (សារណានៃសាកលវិទ្យាល័យ Columbia University ឆ្នាំ ១៩៧៨): ទំព័រ ១១២-១១៧; ៤៧៤-៤៧៥។ សូមមើលផងដែរ Henri Locard, *កូនសៀវភៅក្រហមរបស់ ប៉ុល ពត៖ ភាសិតរបស់អង្គការ* (ឈៀងម៉ៃ៖ Silkworm Books, ឆ្នាំ ២០០៥): ទំព័រ ៣៧៩-៣៨៥។

[6] Ebihara, *ស្វាយ៖ ភូមិខ្មែរ*, ទំព័រ ៤៧៣។

[7] Peg LeVine, *ក្តីស្រឡាញ់ និងការភ័យខ្លាចនៅក្នុងប្រទេសកម្ពុជា៖ មង្គលការ កំណើត និងគ្រោះថ្នាក់ខាងពិធីសាសនាក្រោមរបបខ្មែរក្រហម* (សិង្ហបុរី៖ សារព័ត៌មានសាកលវិទ្យាល័យ National University of Singapore, ឆ្នាំ ២០១០)៖ ទំព័រ ២៥។ LeVine អះអាងថា ប្រជាជនកម្ពុជាបានជួបប្រទះ "អំពើប្រល័យពូជសាសន៍ខាងវប្បធម៌" នៅក្រោមរបបខ្មែរក្រហមដោយសារតែអវត្តមាននៃសិទ្ធិវប្បធម៌ដើម្បីហៅរកវាល់ដូនតាក្នុងអំឡុងពិធីអាពាហ៍ពិពាហ៍ដោយបង្ខំ។

[8] សូមមើលជាទូទៅ Ebihara, ស្វាយ៖ ភូមិខ្មែរ; LeVine, *ក្តីស្រឡាញ់ និងការភ័យខ្លាចនៅក្នុងប្រទេសកម្ពុជា* និង Katherine Bricknell, "ចានក្នុងរាវរមែងប៉ះទង្គិចគ្នា"៖ ការរំលាយអាពាហ៍ពិពាហ៍ និង "ការបំផ្លាញ" ផ្ទះនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន" *Geoforum* ៥១ (ឆ្នាំ ២០១៤)៖ ទំព័រ ២៦២-២៧២។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

សាសនា និងជាតិសាសន៍ (ឧទាហរណ៍ ក្នុងចំណោមជនជាតិចាម ជនជាតិដើមភាគតិច និងជនជាតិវៀតណាម និងក្រុមជនជាតិផ្សេងទៀត) នៃពិធីអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណី។

ប៉ុន្តែ សូម្បីតែមានការប្រែប្រួលក៏ដោយ ក៏ការស្រាវជ្រាវដែលបានធ្វើឡើង បង្ហាញថា អាពាហ៍ពិពាហ៍តាមការរៀបចំមានចំនួនច្រើន។ Heuveline និង ប៉ូច រៀបរាប់អំពីអាពាហ៍ពិពាហ៍បែបនេះថាជា "អាពាហ៍ពិពាហ៍តាមការរៀបចំដោយមានការយល់ព្រម" ដែលមានសិទ្ធិអំណាចត្រូវបានផ្តល់ដោយអ្នកដែលគេចង់ឲ្យរៀបការទៅឲ្យអ្នកកណ្តាលដែលជឿទុកចិត្តបាន ហើយការផ្សំផ្គុំធ្វើឡើងដោយយោងទៅសំណុំនៃលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃពីភាពសក្តិសមគ្នា និងភាពត្រូវគ្នា[9]។ ដើម្បីរៀបចំពិធីមង្គលការ ការយល់ព្រមពីអ្នកដែលគេចង់ឲ្យរៀបការ ជាពិសេសកូនស្រី ត្រូវបានសង្កត់ធ្ងន់ក្នុងការស្រាវជ្រាវនេះ[10]។ អាពាហ៍ពិពាហ៍កុមារបានត្រូវបានអនុវត្ត និងសហព័ន្ធប្រាសចាកការយល់ព្រម ដោយសារអនីតិជនជាទូទៅមិនត្រូវបានចាត់ទុកថាមានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្ត ដោយមានការជូនដំណឹងឲ្យបានពេញលេញ។ ប៉ុន្តែ ជាទូទៅ អាពាហ៍ពិពាហ៍តាមការរៀបចំជាលក្ខណៈប្រពៃណីនៅក្នុងប្រទេសកម្ពុជាមុនរបបខ្មែរក្រហម ត្រូវបានរៀប រាប់យ៉ាងច្រើននៅក្នុងឯកសារវិទ្យាសាស្ត្រថាជា អាពាហ៍ពិពាហ៍រវាងមនុស្សពេញវ័យដោយមានការយល់ព្រម។ ការយល់ព្រម និងសិទ្ធិក្នុងការជ្រើសរើសគូស្រករបស់ខ្លួនគឺត្រូវបានសង្កត់ធ្ងន់ដូចគ្នានេះដែរនៅក្នុងការរៀបចំអាពាហ៍ពិពាហ៍ជន

Deleted: រៀបរាប់

Formatted: Condensed by 0.3 pt

---

[9] Heuveline និង ប៉ូច, "តើអាពាហ៍ពិពាហ៍ភ្លេចអតីតកាលរបស់ខ្លួនឬ?" ទំព័រ ១០១។ សូមមើលផងដែរសម្រាប់ការរិះគន់ជាទូទៅបន្ថែមទៀតចំពោះអាពាហ៍ពិពាហ៍តាមការរៀបចំតាមលក្ខណៈប្រពៃណី និងអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏ដូចជាការអនុវត្តនៃអាពាហ៍ពិពាហ៍ដោយបង្ខំជនរំលោភសេពសន្ថវៈ, Rebecca Surtees, "ការរំលោភសេពសន្ថវៈ និងអំពើរំលងផ្លូវភេទនៅក្នុងសង្គមកម្ពុជា" *អំពើហិង្សាលើស្ត្រីនៅក្នុងសង្គមអាស៊ី*, Lenore Manderson និង Linda Rae Bennett, ពណ្ណាធិការ (ទីក្រុងឡុងដ៍៖ Routledge Curzon, ឆ្នាំ ២០០៣)៖ ទំព័រ ៩៣-១១៣។

[10] Ebihara, *ស្វាយ៖ ភូមិខ្មែរ* ទំព័រ ៣១៥-៣១៦; Judith Ledgerwood, *ការផ្លាស់ប្តូរគំនិតខ្មែរអំពីយ៉េនឌ័រ៖ ស្ត្រី រឿងរ៉ាវ និងសណ្តាប់ធ្នាប់សង្គម* (សារណាសាកលវិទ្យាល័យ Cornell University, ឆ្នាំ ១៩៩០)៖ ទំព័រ ១៧៧; Patrick Heuveline និង ប៊ុនណាក់ ប៉ូច, "តើអាពាហ៍ពិពាហ៍ភ្លេចអតីតកាលរបស់ខ្លួនឬ?" ស្ថេរភាពអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហម" ប្រជាសាស្ត្រ ៤៣៖១ (ឆ្នាំ ២០០៦)៖ ១០១; និង Toy-Cronin, "អ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំ?" ទំព័រ ៥៤៧។ សូមមើលជាទូទៅ Ysa Osman, *ការរុករកការប្រេះឆា៖ អន្តរអាពាហ៍ពិពាហ៍មូស្លីម-ព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា (ភ្នំពេញ, np, ឆ្នាំ ២០១០)*។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ជាតិចាមខ្មែរ (មូស្លីម)[11]។ ដូចគ្នានេះដែរ ក្រមរដ្ឋប្បវេណីដែលបានយកមកអនុវត្តនៅមុនឆ្នាំ ១៩៧៥ សន្មត់ពីការរៀបចំអាពាហ៍ពិពាហ៍ជាមូលដ្ឋានដោយផ្អែកលើការព្រមព្រៀងពីភាគីពាក់ព័ន្ធ ទោះបីជាវាបានអនុញ្ញាតឱ្យមានតួនាទីរបស់ឪពុកម្តាយក៏ដោយ[12]។

Ebihara រៀបរាប់អំពីការសុំរៀបការតាមលក្ខណៈប្រពៃណីជាធម្មតាមួយថា៖

*"តាមទំនៀមទម្លាប់ដ៏ល្អបំផុតបុរសវ័យក្មេងសម្រេចចិត្តដោយខ្លួនគាត់ថាតើត្រូវរៀបការជាមួយនរណា ហើយពេលគាត់សម្រេចចិត្តរួចហើយ គាត់សុំឪពុកម្តាយរបស់គាត់ឲ្យចាប់ផ្តើមសួរនាំដល់ក្រុមគ្រួសារខាងកូនស្រី។ នៅពេលដែលក្រុមគ្រួសារខាងកូនស្រីទទួលយកការសុំរៀបការនេះ ស្ត្រីវ័យក្មេងខ្លួននាងត្រូវបានពិគ្រោះយោបល់ និងជាថ្មីម្តងទៀត បើតាមប្រពៃណី នាងមានសេរីភាពដើម្បីទទួលយក ឬច្រានចោលនូវសំណើនេះ"*[13]។

Deleted:

អាពាហ៍ពិពាហ៍ដោយមានការស្នើឡើងនេះមានការផ្តល់សិទ្ធិ និងការទទួលខុសត្រូវ ហើយដូច្នេះវាក៏ផ្តល់នូវឋានៈដល់ភាគីដែលពាក់ព័ន្ធផងដែរ។ អាពាហ៍ពិពាហ៍ក៏គឺជាផ្នែកមួយពាក់ព័ន្ធនឹងយេនឌ័រផងដែរដែលមានភាពចាំបាច់ និងផលប៉ះពាល់ផ្សេងៗគ្នាសម្រាប់បុរស និងស្ត្រី ជាពិសេសដោយសារអាពាហ៍ពិពាហ៍បម្រើជាការចាក់ឫសនៃតួនាទីយេនឌ័រដែលសង្គមកំណត់។ Ledgerwood និងអ្នកដទៃទៀតបានចង្អុលបង្ហាញអំពីរបៀបដែលអាពាហ៍ពិពាហ៍គឺជាប្រភពតែមួយដែលសំខាន់បំផុតនៃអំណាច និងការវាយតម្លៃវប្បធម៌នៅក្នុងប្រទេសកម្ពុជា ជាពិសេសសម្រាប់ស្ត្រី[14]។ ការស្រាវជ្រាវភាគច្រើនបង្ហាញឱ្យឃើញថា ស្ត្រីដែលមិនរៀបការរួមទាំងអ្នកដែលមិនដែលបានរៀបការ លែងលះគ្នា ឬជាស្ត្រីមេម៉ាយ នាំមកនូវការភ័ន្តច្រឡំពីឋានានុក្រមយេនឌ័

---

[11] សូមមើលជាទូទៅ Ysa Osman, *ការរុករកការប្រេះឆា៖ អន្តរអាពាហ៍ពិពាហ៍មូស្លីម-ព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា (ភ្នំពេញ, np, ឆ្នាំ ២០១០)*។

[12] Toy-Cronin, "អ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំ?" ទំព័រ ៥៤៧។

[13] Ebihara, *ស្វាយ៖ ភូមិខ្មែរ,* ទំព័រ ៤៦៧។

[14] សូមមើល Locard, *កូនសៀវភៅក្រហមរបស់ ប៉ុល ពត* ទំព័រ ៤៨៩៖ "អាពាហ៍ពិពាហ៍បានបញ្ជាក់ពីការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងឋានៈ ជាពិសេសសម្រាប់កូនក្រមុំ"។ សូមមើលផងដែរ Trudy Jacobsen, *ព្រះដែលបាត់បង់៖ ការបដិសេធចំពោះអំណាចរបស់ស្ត្រីក្នុងប្រវត្តិសាស្ត្រកម្ពុជា* (Copenhagen៖ វិទ្យាស្ថានណ័រឌីកសម្រាប់ការសិក្សាពីតំបន់អាស៊ី, ឆ្នាំ ២០០៨)៖ ទំព័រ ៩៧, "អាពាហ៍ពិពាហ៍បានផ្តល់ឲ្យស្ត្រីនូវឋានៈ និង ការការពារតាមផ្លូវច្បាប់"។

Deleted: Unrevised translation. A revised translation will be provided upon request.

រជាធរមាន។ លើសពីនេះទៀត ខណៈកំពុងរស់នៅជាមួយក្រុមគ្រួសារ ស្ត្រីដែលមិនរៀបការត្រូវបានដាក់សម្ពាធយ៉ាងខ្លាំងឲ្យរៀបការ ដែលនាំឲ្យស្ត្រីរៀបការស្ទើរតែទាំងអស់គ្នានៅមុនរបបខ្មែរក្រហម[15]។

អាពាហ៍ពិពាហ៍ដែលបានកំណត់តាមប្រពៃណីអាចសម្គាល់បាន តាមរយៈអតុល្យភាពអំណាចតាមយេនឌ័ររវាងស្វាមី និងភរិយា។ ទោះបីជាអំណាចមួយចំនួនស្ថិតក្នុងដៃរបស់ភរិយា ឧទាហរណ៍ នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ ក៏សង្គមដែលមានឋានានុក្រមខ្លាំងរបស់ប្រទេសកម្ពុជាបានដាក់ស្ត្រីនៅក្នុងមុខតំណែងដែលមានឋានៈទាបជាងបុរស[16]។ ដោយត្រឹមតែឧទាហរណ៍ចំនួនពីរគឺ ប្រពន្ធបានហៅថា ប្តីរបស់នាងថា បង (រៀមច្បង) បើទោះបីជាគាត់មានអាយុតិចជាងនាងក៏ដោយ ហើយនាងត្រូវបានគេរំពឹងថានឹង_ស្តាប់តាមសំណើរបស់ប្តីចំពោះទំនាក់ទំនងផ្លូវភេទដែលជាផ្នែកមួយនៃកាតព្វកិច្ចរបស់ប្រពន្ធ[17]។

កាតព្វកិច្ចល្អបំផុតរបស់ប្រពន្ធត្រូវបានចងក្រងនៅក្នុង *ច្បាប់ស្រី* ឬជាក្រមប្រតិបត្តិសម្រាប់ស្ត្រី ដែលជាកំណាព្យខ្មែរជាប្រពៃណីនៅក្នុងប្រពៃណីពុទ្ធសាសនា[18]។ ស្ត្រីដែលល្អបំផុតគឺត្រូវបានរៀបរាប់ថាជាកូនស្រី និងប្រពន្ធដែលគោរពតាមកាតព្វកិច្ច។ នាងទទួលខុសត្រូវសំខាន់បំផុតចំពោះភាពសុខដុមក្នុងក្រុមគ្រួសារ ក៏ដូច

---

[15] សូមមើលជាទូទៅ Bricknell, "ចានក្នុងរាវរមែងប៉ះទង្គិចគ្នា"; Ebihara, ស្វាយ៖ ភូមិខ្មែរ; Ledgerwood, ការផ្លាស់ប្តូរគំនិតខ្មែរអំពីយ៉េនឌ័រ; និង Judy Ledgerwood, "ការវិភាគអំពីស្ថានភាពរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា៖ ការស្រាវជ្រាវលើស្ត្រីនៅក្នុងសង្គមខ្មែរ" (ភ្នំពេញ៖ UNICEF, ឆ្នាំ ១៩៩២)។

[16] Edward B. Fiske, "ការប្រើដៃទាំងពីរ៖ ស្ត្រី និងអប់រំនៅក្នុងប្រទេសកម្ពុជា" (ទីក្រុងម៉ានីល៖ ធនាគារអភិវឌ្ឍន៍អាស៊ី, ឆ្នាំ ១៩៩៥)៖ ទំព័រ ២១ លើកឡើងពី Ebihara៖ "ថ្វីបើកម្ពុជាមិនមែនជារបបបិតាធិបតេយ្យជាប្រពៃណី ដែលអំណាចស្ទើរតែទាំងអស់ស្ថិតលើបុរសក៏ដោយ ក៏វាគឺជាប្រទេសដែលឋានានុក្រមជាខ្លាំង ហើយស្ត្រីមានឋានៈទាបជាងបុរស"។

[17] Jan Ayako, "ឆ្ពោះទៅកាន់យុទ្ធសាស្ត្រមានប្រសិទ្ធភាពសម្រាប់ការផ្តល់អំណាចដល់ស្ត្រី៖ បទពិសោធន៍របស់ស្ត្រីក្នុងគម្រោងកែលម្អជីវភាព, ខេត្តតាកែវ ប្រទេសកម្ពុជា" (និក្ខេបបទថ្នាក់អនុបណ្ឌិត, សាកលវិទ្យាល័យ Ritsumeikan Asia Pacific University, ឆ្នាំ ២០០៨)៖ ទំព័រ ៤១។

[18] សម្រាប់ការពិភាក្សាបន្ថែមទៀតអំពីរបៀបដែលគោលការណ៍ត្រួតពិនិត្យនៃ *ច្បាប់ស្រី* ដូចដែលវាបានមានឥទ្ធិពលលើឋានៈស្ត្រីនៅក្នុងប្រទេសកម្ពុជាឆ្លងកាត់ប្រវត្តិសាស្ត្ររហូតមកដល់សព្វថ្ងៃនេះ សូមមើល Nakagawa Kasumi "លើសពីសំពត់ស? សិទ្ធិរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា" (ភ្នំពេញ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, ឆ្នាំ ២០០៦)។ សូមមើលផងដែរ Katherine Bricknell, "យើងមិនឆ្នាំងបាយចាស់ទេ ពេលដែលយើងបានឆ្នាំងថ្មី៖ សុន្ទរកថាស្តីពីភាពល្អបំផុត និងការអនុវត្តរបស់ស្ត្រីនៅក្នុងកម្ពុជាបច្ចុប្បន្ន" សញ្ញា៖ ទិនានុប្បវត្តិនៃស្ត្រីនៅក្នុងវប្បធម៌ និងសង្គម, ៣៦៖២ (ឆ្នាំ ២០១១)៖ ទំព័រ ៤៣៧-៤៦២។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ជាកិត្តិយសគ្រួសារ ដែលមានន័យថា ស្ត្រីព្យាយាមរក្សាព្រហ្មចារី និងភាពបរិសុទ្ធនៃរបស់ខ្លួននៅក្នុងគ្រួសារ[19]។ Ledgerwood ចង្អុលបង្ហាញថា គេស្ទើរតែមិនអាចមើលរំលងពី "សារៈសំខាន់ជាខ្លាំង" ដែលជនជាតិខ្មែរផ្តល់លើ "ព្រហ្មចារីរបស់កូនស្រីក្នុងអាពាហ៍ពិពាហ៍ [និង] លើការរៀបចំអាពាហ៍ពិពាហ៍ឲ្យបានត្រឹមត្រូវដែលធ្វើឡើងដោយឪពុកម្តាយ" ដើម្បីបង្ហាញពីកិត្តិយស និងឋានៈរបស់គ្រួសារ[20]។ Natale សរសេរពី *ច្បាប់ស្រី* "ការមានទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍ ដោយយល់ព្រម ឬក៏មិនក៏ដោយ នឹងបំផ្លិចបំផ្លាញការផ្លាស់ប្តូររបស់កូនក្រមុំសម្រាប់អាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ"[21]។ ផ្ទុយទៅវិញ អាពាហ៍ពិពាហ៍មួយជីវិតជាសញ្ញានៃ "ស្ថានភាពកម្មផល" វិជ្ជមានរបស់គ្រួសារទាំងមូល[22]។

ជាសង្ខេប មង្គលការតាមលក្ខណៈប្រពៃណីមុនរបបខ្មែរក្រហមមានសារៈសំខាន់ជាពិសេសសម្រាប់គូស្វាមីភរិយា ក្រុមគ្រួសារ និងសហគមន៍ទាំងមូល រួមទាំងវិញ្ញាណដូនតាផងដែរ។ អាពាហ៍ពិពាហ៍ទាំងនោះភាគច្រើនត្រូវបានរៀបចំ ជាញឹកញាប់បំផុត ដោយមានការយល់ព្រមពីអ្នកដែលគេចង់ឲ្យរៀបការ និងតាមទំនៀមទម្លាប់ កម្រត្រូវបានបង្ខិតបង្ខំ បើយោងតាមការស្រាវជ្រាវដែលបានធ្វើឡើងកន្លងមក។ ឪពុកម្តាយ ពូកចាស់ទុំ និងសហគមន៍បានផ្តល់សុពលភាពដល់ការផ្សំផ្គុំនៅឯពិធីមង្គលការដោយមានការចូលរួមពីវិញ្ញាណដូនតា។ ការផ្សំផ្គុំបានត្រឹមត្រូវមានអត្ថន័យទៅលើអត្តសញ្ញាណសង្គម ជាតិ និងវប្បធម៌នៃអ្នកដែលគេចង់ឲ្យរៀបការ ក៏ដូចជានៅលើសក្តានុពលនៃកម្មផលសម្រាប់ការកសាងកុសលសម្រាប់អនាគតជាតិនៅក្នុងបរិបទពុទ្ធសាសនា។

## ២. អាពាហ៍ពិពាហ៍នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

[19] Ledgerwood, "ការវិភាគអំពីស្ថានភាពស្ត្រីនៅក្នុងប្រទេសកម្ពុជា" ទំព័រ ២២៖ "ស្ត្រីដែលបង្ហាញពីឋានៈខ្ពង់ខ្ពស់របស់ខ្លួន (ភាពបរិសុទ្ធ និងកិត្តិយស) តាមរយៈអាកប្បកិរិយាសមរម្យ"; Jacobsen, ព្រះដែលបាត់បង់, ទំព័រ ១១៩-១២២។

[20] Ledgerwood, ការផ្លាស់ប្តូរគំនិតខ្មែរអំពីយ៉េនឌ័រ, ទំព័រ ២៤។ សូមមើលផងដែរ Fiske, "ការប្រើដៃទាំងពីរ", ទំព័រ ២៣។

[21] Katrina Natale, "ខ្ញុំអាចមានអារម្មណ៍ថា ព្រលឹងខ្ញុំហោះហើរឆ្ងាយពីរាងកាយរបស់ខ្ញុំ៖ ការសិក្សាមួយស្តីពីអំពើហិង្សាផ្អែកយ៉េនឌ័រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តបាត់ដំបងនិង និងខេត្តស្វាយរៀង" (ភ្នំពេញ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, ឆ្នាំ ២០១១)៖ ទំព័រ ១៩។

[22] Bricknell, "ឋានក្នុងរាវរមែងប៉ះទង្គិចគ្នា" ទំព័រ ២៦៥-២៦៨។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ឌី នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបរាប់សង្ខេបយ៉ាងទូលំទូលាយពីភាពខុសគ្នាយ៉ាងខ្លាំងនៃពិធីមង្គលការក្នុងរបបខ្មែរក្រហម បើធៀបទៅនឹងពិធីមង្គលការតាមលក្ខណៈប្រពៃណី។ បុរស និងស្ត្រីភាគច្រើនមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសដៃគូរបស់ខ្លួនទេ ហើយជំនួសមកវិញ *អង្គការ* ដែលបានអះអាងខ្លួនថាជាឪពុកម្ដាយរបស់មនុស្សគ្រប់គ្នា បានចាត់តាំងប្ដីប្រពន្ធឱ្យពួកគេ។ ជនរងគ្រោះគឺរួមមានទាំងបុរស និងស្ត្រី។ ជាញឹកញាប់ គូស្វាមីភរិយាដែលមិនដែលស្គាល់គ្នាសោះ ត្រូវបានបង្ខំឱ្យប្ដេជ្ញាចំពោះគ្នាទៅវិញទៅមកក្នុងពិធីមង្គលការដែលរៀបចំដោយកម្មាភិបាលខ្មែរក្រហម។ សមាជិកគ្រួសារមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងពិធីមង្គលការទេ និងមិនត្រូវបានពិគ្រោះយោបល់ក្នុងការរៀបចំអាពាហ៍ពិពាហ៍ ឬការផ្សំផ្គុំនោះដែរ។ សម្លៀកបំពាក់បែបប្រពៃណី ការរាំច្រៀង និងពិធីសាសនាត្រូវបានហាមឃាត់។ គូស្វាមីភរិយាបានរៀបការដោយស្លៀកសម្លៀកបំពាក់ខ្មែរក្រហមធម្មតាគឺឯកសណ្ឋានពណ៌ខ្មៅ និងស្បែកជើងកង់ឡាន។ ជាផ្នែកមួយនៃពិធីមង្គលការដែលធ្វើឡើងតិចជាងប្រាំនាទី ប្ដី និងប្រពន្ធដែលត្រូវបានចាត់តាំងបានសន្យាជាសាធារណៈថានឹងមានកូនក្នុងរយៈពេលមួយឆ្នាំ។ គូស្វាមីភរិយាដែលបានរៀបការហើយបានស្នាក់នៅជាមួយគ្នាពីរបីថ្ងៃបន្ទាប់ពីពិធីមង្គលការជាញឹកញាប់ដោយមានពួកឈ្លបខ្មែរក្រហមតាមដានដើម្បីប្រាកដថា ពួកគេបានបំពេញអាពាហ៍ពិពាហ៍ដោយមានទំនាក់ទំនងផ្លូវភេទនឹងគ្នា។ បន្ទាប់មក គូស្វាមីភរិយាបានត្រឡប់ទៅក្រុមការងាររៀងៗខ្លួន ដោយបានជួបជុំគ្នាក្នុងឱកាសទៅលេងប្ដីប្រពន្ធរៀងរាល់ប្រាំពីរទៅដប់ថ្ងៃម្ដង ឬអាចយូររហូតដល់រាប់ខែទើប_បានជួបគ្នាម្ដង។ គោលបំណងសំខាន់នៃអាពាហ៍ពិពាហ៍គឺមិនមែនដើម្បីបង្កើតក្រុមគ្រួសារឯកជនដូចនៅក្នុងបរិបទបែបប្រពៃណីនោះទេ ប៉ុន្តែគឺដើម្បី “បង្កើតកុមារដើម្បីបម្រើបដិវត្តន៍”[23]។ នៅក្នុងស្មារតីនៃបដិវត្តន៍ គូស្វាមីភរិយាត្រូវបានតម្រូវឱ្យហៅគ្នាទៅវិញទៅមកថា មិត្តប្ដី [សមមិត្តប្ដី] និងមិត្តប្រពន្ធ [សមមិត្តប្រពន្ធ][24]។

---

[23] ខាំបូលី ឌី, *ប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ២០០៧) ៖ ទំព័រ ៣២-៣៥។ សូមមើលផងដែរជាទូទៅ Nakagawa Kasumi, *អំពើហិង្សាផ្អែកយេនឌ័រនៅក្នុងអំឡុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)* (ភ្នំពេញ៖ np, ឆ្នាំ ២០០៨); សុធារី យីម, “អតីតកាល និងបច្ចុប្បន្ននៃអ្នករស់រានមានជីវិតពីអាពាហ៍ពិពាហ៍ដោយបង្ខំ៖ បទពិសោធន៍ឆ្ពោះទៅរកការព្យាបាល” (ភ្នំពេញ៖ គម្រោងអ្នកការពារកម្ពុជា និង Medica Mondiale, nd)។ ទោះបីជាមិនបានរៀបរាប់ទាំងស្រុងពីអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ សូមមើលផងដែរ យុវសន្តិភាព, *នារីបដិវត្តន៍, អ្នកបដិវត្តន៍ជាស្ត្រី៖* រឿងរ៉ាវនៃខ្មែរក្រហមពីកម្មាភិបាលស្ត្រី (ភ្នំពេញ, ឆ្នាំ ២០១២)។

[24] Jacobson, ព្រះដែលបាត់បង់, ទំព័រ ២២៣។

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

Deleted: *Unrevised translation. A revised translation will be provided upon request.*

ជាទូទៅ ការស្រាវជ្រាវបានពណ៌នាការផ្សំផ្គុំអាពាហ៍ពិពាហ៍ដោយបង្ខំថាធ្វើតាមអំពើចិត្ត លើកលែងតែមានការត្រួតពិនិត្យពីប្រវត្តិយ៉ាងប្រញាប់ប្រញាល់ដោយមេដឹកនាំខ្មែរក្រហម ដើម្បីផ្សំផ្គុំអ្នកដែលមានប្រវត្តិស្រដៀងគ្នា រួមទាំងការបំបែកប្រជាជន "ចាស់" និងប្រជាជន "ថ្មី"។ ដោយសារសាសនាទាំងអស់ត្រូវបានលុបបំបាត់ចោលនៅក្រោមរបបនេះ អ្នកកាន់ឥស្លាមខ្មែរ និងពុទ្ធសាសនិកខ្មែរត្រូវបានផ្សំផ្គុំនឹងគ្នា[25]។ សេចក្ដីលម្អិតផ្សេងទៀត និងភាពប្រែប្រួលដែលបានលើកឡើងដោយក្រុមអ្នកស្រាវជ្រាវគឺការអនុវត្តការរៀបអាពាហ៍ពិពាហ៍ស្ត្រីវ័យក្មេងស្រស់ស្អាតដល់ពួកទាហានខ្មែរក្រហមពិការ ហើយស្ត្រីដែលបដិសេធត្រូវបានឃុំឃាំង ធ្វើទារុណកម្ម និងបានបង្ខំឱ្យធ្វើការងារធ្ងន់នៅឆ្ងាយពីផ្ទះរបស់ពួកគេ។ ស្ត្រីមួយចំនួនក្នុងចំណោមស្ត្រីទាំងនេះបានធ្វើអត្តឃាត[26]។ ការខុសប្លែកផ្សេងទៀតនៅក្នុងការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានការស្រាវជ្រាវរបស់ Toy-Cronin ដែលបង្ហាញថា ពិធីមង្គលការមានភាពម៉ឺងម៉ាត់ជាងសម្រាប់ប្រជាជន ១៧ មេសា[27] ខណៈដែល ហ៊ុយ ចន្ទុលបង្ហាញថា ពិធីមង្គលការរបស់ប្រជាជនមូលដ្ឋានមានភាពខុសគ្នាបន្តិចពីពិធីមង្គលការរបស់ពួកកម្មាភិបាល[28]។ Braaf រកឃើញភ័ស្តុតាងដែលថា អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហមត្រូវបានប្រើលើជនជាតិភាគតិចមួយចំនួនដើម្បីរំលាយសហគមន៍នោះទៅក្នុងប្រជាជនខ្មែរ[29]។

របៀបអនុវត្តគោលនយោបាយខ្មែរក្រហមស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំប្រហែលជាមានការប្រែប្រួលតាមតំបន់ [30]។ ប្រការនេះអាចជួយក្នុងការពន្យល់ពីការរៀបរាប់របស់ Ponchaund អំពី បុរស និងស្ត្រីវ័យក្មេង

---

[25] សូមមើលជាទូទៅ Farinas So, *ស្បៃមុខនៃប្រទេសកម្ពុជា៖ ការចងចាំរបស់ស្ត្រីម៉ូស្លីមចាមបន្ទាប់ពីរបបខ្មែរក្រហម* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ឆ្នាំ ២០១១); និង Rochelle Braaf, "អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងអំឡុងរបបខ្មែរក្រហម" (ភ្នំពេញ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, ឆ្នាំ ២០១៤)។

[26] សូមមើល Jacobson, *ព្រះដែលបាត់បង់*, ទំព័រ ២៣០, ស្ដីពីយោធិនពិការដែលផ្ដល់អំណោយដល់ស្ត្រីវ័យក្មេងសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងបដិវត្តន៍។ សូមមើល ខាំបូលី, *ប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ*, ទំព័រ ៣៣ ស្ដីពីការដាក់ទណ្ឌកម្មចំពោះការបដិសេធចំពោះការរៀបអាពាហ៍ពិពាហ៍ជាមួយទាហាន និងការធ្វើអត្តឃាតរបស់កូនក្រមុំ។

[27] Toy-Cronin, "អ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំ?" ទំព័រ ៥៤៨។

[28] Ratana C. Huy, "ពិធីមង្គលការក្នុងរបបខ្មែរក្រហម" *ការស្វែងរកការពិត* លេខ ២៥ (ឆ្នាំ ២០០២)៖ ទំព័រ ២៦-២៨។

[29] Braaf, "អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច" ទំព័រ x។

[30] សូមមើលជាទូទៅ Natale, "ខ្ញុំអាចមានអារម្មណ៍ថាព្រលឹងខ្ញុំហោះហើរ"; Braaf, "អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច"។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

នៅក្នុងសហគមន៍ទូទៅគឺ "ស្មើភាពគ្នា និងមានសេរីភាពក្នុងការជ្រើសរើសគូស្រករបស់គេ" ហើយនៅពេលដែលយ៉ាងហោចណាស់គូស្វាមីភរិយាចំនួន ១០ គូបានឆ្លងកាត់ទម្រង់ការនៃការស្នើសុំការអនុញ្ញាតពី*អង្គការ* "ប្រធានតំបន់នឹងកំណត់កាលបរិច្ឆេទ និងទីកន្លែងសម្រាប់ពិធីមង្គលការរួម"[31]។ ចំណុចផ្ទុយគ្នាគួរឱ្យកត់សម្គាល់មួយទៀតនៅក្នុងឯកសារវិទ្យាសាស្ត្រគឺការរៀបរាប់របស់ LeVine អំពីលក្ខណៈនៃអាពាហ៍ពិពាហ៍ទាំងនេះថាជា "ការកេណ្ឌ" ជាជាងការបង្ខំ ដោយអះអាងថា ការរៀបចំអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហមមិនបានឃ្លាតចេញពីអាពាហ៍ពិពាហ៍តាមការរៀបចំតាមលក្ខណៈប្រពៃណីទេ[32]។ ផ្ទុយទៅវិញ ជាទូទៅ ក្រុមអ្នកស្រាវជ្រាវយល់ស្របថា អាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម បានឃ្លាតចេញយ៉ាងខ្លាំងពីអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណី ដោយសារអាពាហ៍ពិពាហ៍ទាំងនោះភាគច្រើនធ្វើឡើងដោយគ្មានការជ្រើសរើសគូស្រករដោយគ្មានការយល់ព្រមដ៏មានអត្ថន័យ និងត្រូវបានបង្ខិតបង្ខំនៅក្នុងបរិយាកាសគាបសង្កត់នៃការគំរាមកំហែងជាប្រចាំថាត្រូវស្លាប់ ឬរងទណ្ឌកម្ម។

អាពាហ៍ពិពាហ៍ដោយបង្ខំរួមបញ្ចូលទាំងអំពើហិង្សាផ្លូវភេទ ដោយសារមានការបង្ខំឱ្យមានទំនាក់ទំនងផ្លូវភេទដើម្បីបំពេញអាពាហ៍ពិពាហ៍នោះផងដែរ។ ក្រុមអ្នកស្រាវជ្រាវបានចងក្រងជាឯកសារអំពីការអនុវត្តនេះ។ ឯម រៀបរាប់អំពីផ្ទះតូចមួយដែលបានរៀបចំសម្រាប់គូស្វាមីភរិយា បន្ទាប់បានរៀបចំពិធីមង្គលការក្នុងរបបខ្មែរក្រហម និងទណ្ឌកម្ម ឬការបាត់ខ្លួនដែលប្រឈមមុខដោយគូស្វាមីភរិយាដែល "បានបដិសេធក្នុងការទទួលយកគ្នា" នៅយប់បន្ទាប់ពីពិធីមង្គលការ[33]។ Ye ពិភាក្សាអំពីរបៀបដែលបទបញ្ជាឱ្យបំពេញអាពាហ៍ពិពាហ៍នាំឱ្យមានការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទសម្រាប់ស្ត្រីជាច្រើនពីសំណាក់ប្តីដែលគេចាត់តាំងឱ្យពួកគេ[34]។ ប្រធានបទនេះមានរៀបរាប់ផងដែរនៅក្នុងកម្រង់ឯកសារដ៏វែងក្រោមចំណងជើងថា

---

[31] Francois Ponchaund, កម្ពុជា៖ ឆ្នាំសូន្យ (ញូវយ៉ក៖ Holt, Rinehart and Winston, ឆ្នាំ ១៩៧៨)៖ ទំព័រ ១២៥-១២៦។

[32] LeVine, ក្តីស្រឡាញ់ និងការភ័យខ្លាច, ទំព័រ ២៩។

[33] សុឃីម ឯម, "បុគ្គលិកពេទ្យជាស្ត្រីបដិវត្តន៍នៅក្នុងស្រុកត្រាំកក់" ការស្វែងរកការពិត លេខ ៣៥ (ឆ្នាំ ២០០២)៖ ទំព័រ ១៧-១៩។

[34] Beini Ye, "អាពាហ៍ពិពាហ៍ដោយបង្ខំជាកញ្ចក់នៃដោះស្រាយទំនាស់នៅកម្ពុជា" *Peace Review,* ២៣៖៤ (ឆ្នាំ ២០១១)៖ ទំព័រ ៤៧០។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

អាពាហ៍ពិពាហ៍ក្រហម ដែលផលិតដោយ ប៉ាន់ រិទ្ធី សម្រាប់មជ្ឈមណ្ឌលបុប្ផាណាក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ ២០១២[35]។

ក្រុមអ្នកស្រាវជ្រាវបានអះអាងថា ស្ត្រី និងបុរសជាញឹកញាប់មានជម្រើសជាយុទ្ធសាស្ត្រដើម្បីរស់រានមានជីវិតបានដោយបង្ខំចិត្តយល់ព្រមចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយការប្រឆាំងយ៉ាងហោចណាស់ក្នុងការប៉ុនប៉ងដើម្បីបដិសេធ គឺជារឿងធម្មតា។ ជាការពិតណាស់ គេអាចយល់បានពីការធ្វើអត្តឃាតរបស់ស្ត្រីតាមរយៈចំណុចនេះ។ Toy-Cronin ចង្អុលបង្ហាញអំពីរបៀបដែលជាច្រើននៃអ្នកឆ្លើយសំណួររបស់នាងបានត្អូញត្អែរយ៉ាងជូរចត់ថា “ឪពុកម្តាយពួកគេមិនត្រូវបានអនុញ្ញាតឲ្យបំពេញតួនាទីជាប្រពៃណីរបស់ពួកគេក្នុងការរៀបចំអាពាហ៍ពិពាហ៍ និងមិនអាចចូលរួមក្នុងពិធីនេះទេ”[36]។ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានជនរងគ្រោះជាច្រើនចាត់ទុកថាជាអំពើអកតញ្ញូចំពោះឪពុកម្តាយ និងដូនតា។ ចំពោះស្ត្រីដែលត្រូវបានចិញ្ចឹមបីបាច់ ក្រោមការអប់រំឲ្យការពារព្រហ្មចារីឲ្យបាន ទោះជាត្រូវលះបង់អ្វីទាំងអស់ នោះទំនាក់ទំនងផ្លូវភេទនៅក្នុងអាពាហ៍ពិពាហ៍ទាំងនេះគឺជារឿងតក់ស្លុតជាពិសេស។

បើទោះបីជាអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម គឺជាគោលនយោបាយថ្នាក់ជាតិ និងស្ទើរតែបានអនុវត្តជាសកលបើយោងតាមការស្រាវជ្រាវដែលបានរកឃើញក្តី ក៏អត្រាប្រេវ៉ាឡង់មិនដែលត្រូវបានគេកំណត់ឡើយ។ McGrew ផ្តល់ការប៉ាន់ប្រមាណទ្រូសៗអំពីអាពាហ៍ពិពាហ៍ដោយបង្ខំដោយផ្អែកលើការគណនាចំនួនប្រជាជន និងការស្រាវជ្រាវរបស់នាង៖

*“តើអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈទូលំទូលាយប៉ុណ្ណាដែរ? ដោយប្រើវិធីប្រៀបធៀប វាត្រូវបានប៉ាន់ប្រមាណថា ស្ត្រីផ្តល់ភាពសុខស្រួលជាង ២០០.០០០ នាក់ត្រូវបានក្លាយជាទាសករនៃយោធារបស់ប្រទេសជប៉ុននៅក្នុងអំឡុងពេល និងនៅជុំវិញសង្គ្រាមលោកលើកទី ២។ ទោះបីជាការអនុវត្តទាំងពីរនេះមានភាពខុសគ្នាទាំងស្រុងក៏ដោយ ក៏ចំនួននេះអាចមានតំលៃប្រហាក់ប្រហែលគ្នា។ ប្រសិនបើនៅក្នុងភូមិកម្ពុជាមួយដែលមានប្រជាជន ១.០០០ នាក់ មានជាមធ្យមនូវអាពាហ៍ពិពាហ៍ជាក្រុមចំនួនពីរដងនៅក្នុងអំឡុងពេលបួនឆ្នាំដែលពួកខ្មែរក្រហមបានកាន់អំណាច ដោយមានស្ត្រី ១៥ នាក់ចូល*

[35] ដូចឯកសារខាងលើ។

[36] Toy-Cronin, “អ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំ?” ទំព័រ ៥៤៨។

Deleted: *Unrevised translation. A revised translation will be provided upon request.*

*រួមក្នុងពិធីម្តងៗ នេះនឹងមានន័យថាអាចមានស្ត្រីច្រើនដល់ ២១០.០០០ នាក់ត្រូវបានបង្ខំចូលក្នុងអាពាហ៍ពិពាហ៍ក្នុងចំណោមប្រជាជនសរុបចំនួនប្រាំពីរលាននាក់"*[37] ។

ទោះជាយ៉ាងណា អាពាហ៍ពិពាហ៍ជាច្រើនត្រូវរងការបង្ខំនៅក្នុងរបបខ្មែរក្រហម (ហើយវាជាការច្បាស់ណាស់ថាមានរាប់ពាន់ករណី) ក្រុមអ្នកស្រាវជ្រាវរៀបរាប់ភាគច្រើនពីគោលនយោបាយមួយជាមួយនឹងការអនុវត្តជាប្រព័ន្ធ ទូលំទូលាយ និងក្រោមការបង្ខិតបង្ខំយ៉ាងសាហាវ។ គោលនយោបាយនេះគឺជាការរំលោភលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបានលុបចោលនូវគោលការណ៍វប្បធម៌ស្នូល រួមទាំងការចូលរួមពីក្រុមគ្រួសារ និងដូនតា។ ជនរងគ្រោះភាគច្រើនបំផុតមិនបានធ្វើការជ្រើសរើសគូស្រករ មិនទទួលបានបរិយាកាសមួយដែលអាចមានការយល់ព្រមតាមផ្លូវចិត្ត និងត្រូវបានបង្ខិតបង្ខំ នៅពេលដែលមិនមានការយល់ព្រម។ គូស្វាមីភរិយាដែលបានចាត់តាំងត្រូវរងការបង្ខំឱ្យមានទំនាក់ទំនងរបស់សហព័ទ្ធ ដែលនាំឱ្យមានការចាប់រំលោភក្នុងចំណងអាពាហ៍ពិពាហ៍ និងទម្រង់ដទៃទៀតនៃអំពើហិង្សាផ្លូវភេទ ក៏ដូចជាការប៉ះទង្គិចផ្លូវចិត្ត។

## ៣. អាពាហ៍ពិពាហ៍ក្រោយការដួលរលំនៃរបបខ្មែរក្រហម (ក្រោយឆ្នាំ ១៩៧៩)

របបខ្មែរក្រហមត្រូវបានផ្តួលរលំដោយកងទ័ពវៀតណាមនៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩។ នៅប៉ុន្មានថ្ងៃភ្លាមៗបន្ទាប់ពីមានការដួលរលំនេះ គឺជារយៈពេលនៃភាពចលាចល និងមានលក្ខណៈប្រែប្រួលមួយសម្រាប់ប្រជាជនទាំងមូល នៅពេលដែលប្រជាជនបានវិលត្រឡប់ទៅផ្ទះដើមរបស់ពួកគេ ហើយក្រុមគ្រួសារបានចាប់ផ្តើមការងារកសាងចំណងទាក់ទងឡើងវិញជាមួយសមាជិកដែលនៅរស់។ គោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនៃរបបខ្មែរក្រហមបានធ្វើឱ្យភាពរីកររនេះកាន់តែធ្ងន់ធ្ងរឡើង។ ការស្រាវជ្រាវបានបង្ហាញថាមិនមានគោលនយោបាយថ្នាក់ជាតិដោយរដ្ឋាភិបាលបណ្តោះអាសន្ន បន្ទាប់ពីការដួលរលំនៃរបបនេះដើម្បីដោះស្រាយជាក់លាក់ពីស្ថានភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ឬជម្រើសការរំលាយដែលអាចធ្វើបានសម្រាប់គូស្វាមីភរិយា

---

[37] Laura McGrew, "ស្ត្រីកម្ពុជា និងឆ្នាំសូន្យ" នៅលើកំណាត់គ្រោះ៖ ស្ត្រីនៅអាស៊ីអាគ្នេយ៍ប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា ៥ (ឆ្នាំ ១៩៩៨)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ទាំងនេះ[38]។ ហេតុដូច្នេះ គូស្វាមីភរិយាត្រូវបានទុកឲ្យចរចាដោយខ្លួនឯងអំពីស្ថានភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំរៀងៗខ្លួន។

ឯកសារស្រាវជ្រាវស្តីពីការអភិវឌ្ឍដំបូងៗនៅទសវត្សរ៍ឆ្នាំ ១៩៩០ និងទសវត្សរ៍ឆ្នាំ ២០០០ មិនបានរៀបរាប់ពីអាពាហ៍ពិពាហ៍ដោយបង្ខំជាក់លាក់នោះទេ ដោយចង្អុលបង្ហាញជំនួសវិញពីអត្រាខ្ពស់នៃគ្រួសារដែលមានស្ត្រីជាមេគ្រួសារនៅក្នុងសម័យនោះ។ អ្វីដែលជាការព្រួយបារម្ភយ៉ាងខ្លាំងនៅទសវត្សរ៍ឆ្នាំ ១៩៨០ គឺសមាមាត្រនៃគ្រួសារនៅតាមជនបទដែលមានស្ត្រីជាមេគ្រួសារ ដែលត្រូវបានគេគិតថាខ្ពស់រហូតដល់ ៣០% ទៅ ៣៥% នៃគ្រួសារសរុប និងឈានដល់ ៥០% នៅក្នុងភូមិខ្លះ[39]។ តាមពិតទៅ នៅពេលដែល Ebihara វិលត្រឡប់ទៅភូមិដែលនាងបានសិក្សានៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ មានស្ត្រីដល់ទៅ ៨០,៥% ក្នុងចំណោមប្រជាជនសរុប[40]។ “ស្ត្រីមេម៉ាយ” ដ៏ច្រើនដូច្នេះ នៅពេលនេះត្រូវបានផ្សារភ្ជាប់ទៅនឹងអត្រាមរណភាពខ្ពស់របស់បុរស

---

[38] ការស្រាវជ្រាវរបស់ Toy-Cronin បង្ហាញថា អាពាហ៍ពិពាហ៍មិនបានអនុវត្តតាមនីតិវិធីចុះបញ្ជីណាមួយជាផ្លូវការនោះទេ (សូមមើល “អ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំ” ទំព័រ ៥៤៨)។ គោលនយោបាយថ្នាក់ជាតិនេះមិនត្រូវបានរៀបរាប់នៅក្នុងឯកសារវិទ្យាសាស្ត្រស្តីពីការអភិវឌ្ឍនៅសម័យនោះទេ ដូចជារបាយការណ៍របស់ Ledgerwood សម្រាប់អង្គការ UNICEF (ការវិភាគអំពីស្ថានភាពស្ត្រីនៅក្នុងប្រទេសកម្ពុជា” [ឆ្នាំ ១៩៩២]); ឯកសាររបស់ Peter Utting ក្រោមចំណងជើង *រវាងក្តីសង្ឃឹម និងអសន្តិសុខ៖ ផលវិបាកសង្គមនៃដំណើរការសន្តិភាពនៅកម្ពុជា* (ញូវយ៉ក៖ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍សង្គមនៃអង្គការសហប្រជាជាតិ [UNRISD], ឆ្នាំ ១៩៩៤); ឬរបាយការណ៍អង្គការ UNICEF នៅឆ្នាំ ១៩៩៥៖ “ឆ្ពោះទៅកាន់អនាគតកាន់តែប្រសើរ៖ ការវិភាគអំពីស្ថានភាពរបស់កុមារ និងស្ត្រីនៅក្នុងប្រទេសកម្ពុជាទេ”។

[39] Jacqueline Desbarats, “អ្នករស់រានមានជីវិតដែលមានចំនួនកាន់តែច្រើន៖ ការផ្លាស់ប្តូរចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៧៥-១៩៩៣” ឯកសារសម្រាប់កម្មវិធីសាកលវិទ្យាល័យ Temple Arizona State University សម្រាប់ការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (ឆ្នាំ ១៩៩៥)៖ ទំព័រ ១២៦។

[40] Alexander Hinton, “លើសពីការរងទុក្ខវេទនា-ការភ័យរន្ធត់នៃអំពើប្រល័យពូជសាសន៍ក្រោមរបបខ្មែរក្រហម៖ ការសម្លឹងមើលពីការស្រាវជ្រាវរបស់លោកស្រី May Ebihara “*នរវិទ្យា និងសហគមន៍នៅកម្ពុជា៖ ការឆ្លុះបញ្ចាំងស្តីពីការស្រាវជ្រាវរបស់លោកស្រី May Ebihara*”, John Marston, ed (Caulfield៖ សារព័ត៌មានសាកលវិទ្យាល័យ Monash University, ឆ្នាំ ២០១១)៖ ការស្រង់សម្តីពី Ebihara, ទំព័រ ៥៩។ គួរឱ្យភ្ញាក់ផ្អើលណាស់ លោកស្រី Ebihara មិនបានពិនិត្យពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងពេលដំណើរទស្សនកិច្ចត្រឡប់មកវិញរបស់នាងមកកាន់ភូមិស្វាយក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ក្នុងអំឡុងពេលមានជម្លោះ និងក្នុងរបបនោះ ក៏ដូចជាការធ្វើចំណាកស្រុករបស់បុរសទៅរកការងារធ្វើ និងបុរសដែលអាចត្រូវបានគេកេណ្ឌឱ្យចូលបម្រើក្នុងកម្លាំងប្រដាប់អាវុធ[41]។

អ្វីដែលមិនត្រូវបានរៀបរាប់នៅក្នុងឯកសារស្រាវជ្រាវនោះស្តីពីការអភិវឌ្ឍ គឺជាការផ្សារភ្ជាប់ដែលអាចទៅរួចរវាងពីគ្រួសារដ៏ច្រើនដែលមានស្ត្រីជាមេគ្រួសារ និងអាពាហ៍ពិពាហ៍ដោយបង្ខំដែលបែកបាក់ ជាពិសេសដោយសារ "ស្ត្រីមេម៉ាយ" អាចត្រូវបានប្រើនៅក្នុងភាសាខ្មែរដើម្បីចង្អុលបង្ហាញពីស្ត្រីណាម្នាក់ដែលធ្លាប់បានរៀបការ ប៉ុន្តែលែងមានស្វាមីនៅជាមួយ ដោយសារប្តីស្លាប់ ចែកផ្លូវគ្នា ឬលែងលះគ្នា។ ទោះបីជាមិនបានរៀបរាប់ពីអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏ការស្រាវជ្រាវរបស់ Sato រកឃើញថា "ប្រទេសកម្ពុជាមិនមានកម្មវិធីរដ្ឋាភិបាលណាមួយដើម្បីគាំទ្រដល់ស្ត្រីមេម៉ាយ ឬលែងលះគ្នាដែលមានកូននោះទេ" នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ បើទោះបីជាការពិតដែលថា នៅពេលលែងលះ ម្តាយមានទម្លាប់យកកូនទៅមើលថែ ហើយក្នុងចំណោមគំរូរបស់នាង គ្មានស្ត្រីជាម្តាយណាម្នាក់បានទទួលការគាំទ្រចិញ្ចឹមកូនពីអតីតស្វាមីរបស់ខ្លួនទេ[42]។ ជាថ្មីម្តងទៀត ខណៈដែលមិនបានរៀបរាប់ពីអាពាហ៍ពិពាហ៍ដោយបង្ខំដោយពួកខ្មែរក្រហម របាយការណ៍ស្តីពីការអភិវឌ្ឍផ្សេងទៀតនៅក្នុងដើមទសវត្សរ៍ឆ្នាំ ២០០០ ពិភាក្សាអំពីកេរដំណែលនៃអំពើឃោរឃៅថាជាការកើនឡើងយ៉ាងរីករាលដាលនៃអំពើហិង្សាក្នុងគ្រួសារ ការប្រពន្ធច្រើន និងការបោះបង់ចោល បន្ទាប់ពីការដួលរលំនៃរបបនេះ[43]។ លទ្ធផលនៃចំនួនជាច្រើននៃគ្រួសារដែលមានស្ត្រីជាមេគ្រួសារបាននាំឱ្យកំណត់ឡើង

---

[41] Peter Utting, *រវាងក្តីសង្ឃឹម និងអសន្តិសុខ*, ទំព័រ ៩៣-៩៤។

[42] Nao Sato, "សមាសភាព និងការងាររបស់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ៖ ករណីសិក្សាមួយនៃភូមិជនបទមួយក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា" ឯកសារការងារស៊េរីលេខ ១១, មជ្ឈមណ្ឌលអាព្រិច សម្រាប់ការសិក្សាពីសន្តិភាព និងការអភិវឌ្ឍ, Singha, ជប៉ុន, ឆ្នាំ ២០០៦៖ ទំព័រ ២១-២២។ សូមមើលផងដែរ Desbarats, "អ្នករស់រានមានជីវិតដែលមានចំនួនកាន់តែច្រើន" ដែលពិភាក្សាអំពីរបៀបដែលនៅឆ្នាំ ១៩៨៦ ជាង ៩៧% នៃប្រជាជនជនបទស្ថិតក្នុងក្រុមសាមគ្គី ឬកសិដ្ឋានរួម ជាមួយនឹងអត្ថប្រយោជន៍នៃការផ្តល់ជូននូវប្រព័ន្ធសុវត្ថិភាពមួយសម្រាប់អតិរេកនៃស្ត្រីមេម៉ាយ និងក្មេងកំព្រា។ នៅឆ្នាំ ១៩៨៩ គោលនយោបាយទាំងនេះត្រូវបានគេបោះបង់ចោលជាមួយនឹងការមកដល់នៃកម្មវិធីការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច ដែលនាំឱ្យស្ត្រីធ្វើការងារបុរស ឬត្រូវផ្តល់ហិរញ្ញប្បទានដើម្បីជួលកម្លាំងពលកម្មជាបុរស។ អាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានគ្របដណ្តប់ទេ។

[43] Cathy Zimmerman, "ចានក្នុងរាវរមែងប៉ះទង្គិចគ្នា៖ អំពើហិង្សាក្នុងគ្រួសារនៅក្នុងប្រទេសកម្ពុជា" (ភ្នំពេញ៖ មូលនិធិអាស៊ីនៃប្រទេសកម្ពុជា ឆ្នាំ ១៩៩៤); Jan Ovesen, Ing-Britt Trankell និង Joakim Ojendal, "នៅពេលដែលគ្រប់គ្រួសារគឺកោះមួយ៖ អង្គ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

វិញទាំងស្រុងពីតួនាទីយេនឌ័រ ដោយស្ត្រីធ្វើជាអ្នកទំនុកបម្រុង និងអ្នកថែទាំគ្រួសារ ព្រមទាំងអ្នកសម្រេចចិត្តសំខាន់នៅក្នុងគ្រួសារ[44]។

ការស្រាវជ្រាវរបស់ Bricknell គឺជាផ្នែកមួយនៃការស្រាវជ្រាវមួយចំនួនតូចដើម្បីពិនិត្យមើលផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ និក្ខេបបទរបស់នាងពិនិត្យមើលអាពាហ៍ពិពាហ៍ជាថ្មី និងការលែងលះក្រោយការបោះបង់ចោលយ៉ាងរាលដាល ការមានប្រពន្ធច្រើន និងការរំលោភបំពាននៅក្នុងបរិបទនៃការចលាចលស៊ីវិលដែលបន្តរហូតដល់ឆ្នាំ ១៩៩៨ ហើយជាលទ្ធផលនាងបាន_ពិនិត្យពីកម្រិតនៃសមាមាត្របុរស និងស្ត្រីនៅពេលរបបនេះដួលរលំ។ ដោយអះអាងថា "ឋានៈសង្គមរបស់ស្ត្រីនៅតែអាស្រ័យលើទំនាក់ទំនងចុះសម្រុងគ្នាក្នុងចំណងអាពាហ៍ពិពាហ៍ និងជាមួយឪពុកម្ដាយ" ការលែងលះនិងភាពមេម៉ាយនាំមកនូវមាក់ងាយពីសង្គម និងដាក់កម្រិតដល់ការទទួលបានប្រភពស្នូលនៃអំណាច និងឋានៈ។ "ស្ត្រីមេម៉ាយ" ត្រូវបានគេឲ្យតម្លៃក្នុងសង្គមថាជាការមិនពេញលេញ និងក្នុងវប្បធម៌ថាអពមង្គល ដោយសារស្ត្រីទាំងនេះ តាមនិយមន័យ បានធ្វើខុស*ច្បាប់ស្រី* ទាក់ទងនឹងការចុះសម្រុងគ្នា និងភាពស្អិតរមួតក្នុងគ្រួសារ។ ហេតុនេះ អាពាហ៍ពិពាហ៍ម្ដងទៀតបន្ទាប់ពីរបបនេះត្រូវបានគេមើលឃើញថាជាការលោះកំហុសសម្រាប់គោលបំណងជាច្រើន។ Bricknell បានអះអាងថា ក្រោយរបបនេះ ស្ត្រីបន្តរើសយកជម្រើសជាយុទ្ធសាស្ត្ររួមទាំងការទទួលយកការក្លាយជាប្រពន្ធទីពីរ ឬទីបីជាមួយនឹងឋានៈទាបជាងគេ។ ស្ត្រីផ្សេងទៀតបានព្យាយាមដោះស្រាយការខូចខាត "ស្ថានភាពកម្មផល" នៃអាពាហ៍ពិពាហ៍ដោយបង្ខំដោយការរៀបអាពាហ៍ពិពាហ៍ម្ដងទៀតតាមជម្រើស និងដោយមានការចូលរួមរបស់ដូនតា និងឪពុកម្ដាយ តាមរយៈពិធីតាមលក្ខណៈប្រពៃណី[45]
។

យោងតាមការស្រាវជ្រាវរួមបញ្ចូលគ្នា អាពាហ៍ពិពាហ៍ដោយបង្ខំនាំមកនូវផលប៉ះពាល់ខាងយេនឌ័រ និងមានផលវិបាកសង្គម សេដ្ឋកិច្ច និងវប្បធម៌យ៉ាងខ្លាំងទៅលើស្ត្រី និងកូនរបស់ពួកគេ។ ផលប៉ះពាល់ទាំងនេះក៏ជាលក្ខណៈចិត្តសាស្ត្រផងដែរ។ Ye ចង្អុលទៅរកភាពឯកោខាងផ្លូវចិត្តដែលបានជួបប្រទះដោយអ្នករស់រាន

ការសង្គម និងរចនាសម្ព័ន្ធអំណាចក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា" របាយការណ៍ស្រាវជ្រាវ Uppsala ក្នុងនរវិទ្យាវប្បធម៌ លេខ ១៥ (ឆ្នាំ ១៩៩៦)។

[44] Desbarats, "អ្នករស់រានមានជីវិតដែលមានចំនួនកាន់តែច្រើន" ទំព័រ ២០។

[45] Bricknell. "ធានក្នុងភាវរមែងប៉ះទង្គិចគ្នា" ទំព័រ ២៦៥-៧០។

Formatted: Condensed by 0.3 pt

Deleted: *Unrevised translation. A revised translation will be provided upon request.*

មានជីវិតពីអាពាហ៍ពិពាហ៍ដោយបង្ខំ ជាពិសេសស្ត្រី និងរបៀបដែលការប៉ះទង្គិចផ្លូវចិត្តនេះអាចនឹងត្រូវបានបញ្ជូនទៅកូន[46]។ Kogure ពិភាក្សាអំពីផលប៉ះពាល់អវិជ្ជមានលើការអប់រំកូនដោយសារតែអាពាហ៍ពិពាហ៍ដោយបង្ខំ[47]។ ការស្រាវជ្រាវដែលអាចរកបាន មិនបានពិភាក្សាអំពីការផ្លាស់ប្តូរខាងអារម្មណ៍ ផ្លូវចិត្ត ឬអាកប្បកិរិយា និងផលវិបាកនៃការប៉ះទង្គិចផ្លូវចិត្តលើបុរស អត្តសញ្ញាណបុរស ឬនិយមន័យនៃភាពជាបុរសដោយសារតែគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងរបស់សហព័ទ្ធដែលត្រូវបានបង្ខំ។

គេមិនច្បាស់ទេអំពីចំនួននៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់ និងចំនួនដែលបែកបាក់បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ ភ័ស្តុតាងតាមដំណើររឿងបង្ហាញថា ប្រហែលជាពាក់កណ្តាលនៃអាពាហ៍ពិពាហ៍ទាំងនោះបានបែកបាក់[48]។ ផ្ទុយទៅវិញ គំរូរបស់ LeVine បានបង្ហាញលទ្ធផលថា "ជាង ៨០ % (១៥៨ នាក់នៃចំនួន ១៩២ នាក់) នៃអ្នកឆ្លើយសំណួររបស់គាត់ចាត់ទុកអាពាហ៍ពិពាហ៍របស់ពួកគេតាមបញ្ជាពួកខ្មែរក្រហមថាជាការរៀបចំស្របច្បាប់" ដោយចំនួនដូចគ្នានេះដែរនៅបន្តរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃ[49]។ អត្រានេះគឺខ្ពស់ខ្លាំងជាងការចង្អុលបង្ហាញដោយក្រុមអ្នកស្រាវជ្រាវផ្សេងទៀត។

ការស្រាវជ្រាវរបស់ Toy-Cronin ពិភាក្សាអំពីភាពខុសគ្នានៃមូលហេតុដែលគូស្វាមីភរិយានៅតែបន្តរស់នៅរួមគ្នា ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រី៖ បំណងប្រាថ្នាដើម្បីរក្សាចំណងគ្រួសារ ជាពិសេសនៅពេលដែលកូនកើតចេញពីអាពាហ៍ពិពាហ៍ ភាពចាំបាច់ខាងហិរញ្ញវត្ថុ តម្រូវការសម្រាប់ការការពារ និងការថែរក្សាគ្នាទៅវិញទៅមក ឬឥទ្ធិពលនៃបទដ្ឋានវប្បធម៌ប្រឆាំងនឹងការបែកបាក់គ្នា។ ប៉ុន្តែ នាងអះអាងថា ភ័ស្តុតាងដែលថា គូស្វាមីភរិយានៅតែនៅជាមួយគ្នាមិនបដិសេធ ឬទុកជាមោឃៈចំពោះការពិតដែលថា ជាញឹកញាប់ប្តី

[46] Ye, "អាពាហ៍ពិពាហ៍ដោយបង្ខំជាកញ្ចក់" ទំព័រ ៤៧១។

[47] Katsuo Kogure, "ផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងប្រទេសកម្ពុជានៅក្រោមរបប ប៉ុល ពត" ឯកសារពិភាក្សាលេខ ៨០៥, វិទ្យាស្ថានស្រាវជ្រាវសង្គម និងសេដ្ឋកិច្ច, សាកលវិទ្យាល័យ Osaka University, ខែមីនា ឆ្នាំ ២០១១។ សូមមើលផងដែរជាទូទៅ Nigel P. Field, "ការចម្លងអន្តរជំនាន់ការប៉ះទង្គិចផ្លូវចិត្តផ្តើមចេញពីរបបខ្មែរក្រហម៖ ទស្សនៈអារម្មណ៍ផ្សារភ្ជាប់"។ សម្លាកលាក់មុខរបស់ប្រទេសកម្ពុជា៖ ចិត្តវិទ្យានៃការប៉ះទង្គិចផ្លូវចិត្តបន្ទាប់ពីរបបខ្មែរក្រហម, Beth Van Schaack, Daryn Reicherter និង ឆាំង យុ, ពណ្ណាធិការ (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០១១)៖ ទំព័រ ៧០-៨៥។

[48] McGrew, "ស្ត្រីកម្ពុជានៅក្នុងឆ្នាំសូន្យ"។

[49] LeVine, ក្តីស្រឡាញ់ និងការភ័យខ្លាច, ទំព័រ ២៦ ទំព័រ ៨៧។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ប្រពន្ធទាំងពីរសុទ្ធតែជាជនរងគ្រោះ ដោយសារគោលនយោបាយនៃរបបខ្មែរក្រហមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ៖ “សម្រាប់ប្រជាជនកម្ពុជា ផលប៉ះពាល់ជាបន្តនៃការបន្តស្ថានភាពអាពាហ៍ពិពាហ៍អាស្រ័យជាសំខាន់លើអំពើព្រៃផ្សៃដែលត្រូវបានប្រើដើម្បីបង្ខំអាពាហ៍ពិពាហ៍ និងការឈឺចាប់ និងការប៉ះពាល់ដែលបណ្តាលមកពីការខ្វះខាតនៃអ្វីដែលជាពិធីដ៏សំខាន់មួយ និងការប្រារព្ធពិធីតាមវប្បធម៌នៃប្រទេសកម្ពុជា”[50]។ ការរកឃើញនេះអាចត្រូវបានសន្និដ្ឋានថាត្រូវអនុវត្តចំពោះទាំងបុរស និងស្ត្រីដែលរស់រានមានជីវិតពីគោលនយោបាយខ្មែរក្រហមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងរបស់សហព័ទ្ធ។

50 Toy-Cronin, “អ្វីជាអាពាហ៍ពិពាហ៍ដោយបង្ខំ?” ទំព័រ ៥៥៥ ទំព័រ ៥៨៦។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

**៤. អាពាហ៍ពិពាហ៍ដោយបង្ខំជាបទឧក្រិដ្ឋនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា**

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តដោយរបបខ្មែរក្រហមចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩[51]។ តុលាការនេះបានបញ្ចប់សំណុំរឿងមួយក្នុងចំណោមសំណុំរឿងដែលបានស្នើឡើងចំនួនបួនករណី ដោយសំណុំរឿង ០០២ ត្រូវបំបែកទៅជាសំណុំរឿងតូចជាងមុនដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីដោយសារវ័យចាស់ជរារបស់ជនជាប់ចោទ (ឥឡូវនេះ ពួកគេមានអាយុប្រមាណជា ៨០ ឆ្នាំហើយ)។ បទចោទក្នុងសំណុំរឿង ០០២ ដែលបានរួមបញ្ចូលទាំងអាពាហ៍ពិពាហ៍ដោយបង្ខំជាផ្នែកមួយនៃគោលនយោបាយទាំងប្រាំដែលបានប្រើដោយរបបនេះដើម្បីអនុវត្តគោលបំណងឧក្រិដ្ឋរបស់ខ្លួន។ ការចោទប្រកាន់ពីបទអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ទាំងនោះ ដែលសំដៅនៅក្នុងដីកាចោទប្រកាន់ថាជា "បទប្បញ្ញត្តិនៃអាពាហ៍ពិពាហ៍" នឹងត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿង ០០២/០២ ដែលជិតចូលមកដល់ថាជា "អំពើឃោរឃៅដទៃទៀត" ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[52]។ អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបទចោទប្រកាន់ធំបំផុតទីពីររបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺបន្ទាប់ពីការជម្លៀសដោយបង្ខំ នៅក្នុងសំណុំរឿង ០០២។ ថ្មីៗនេះ ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានស្នើសុំឲ្យមានការស៊ើបអង្កេតលើអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងរំលោភសេពសន្ថវៈខាងក្នុង និងខាងក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ សម្រាប់សំណុំរឿង ០០៤[53]។ នេះបង្ហាញពីការយល់ដឹងកាន់តែច្រើនអំពីទំហំនៃអំពើហិង្សាខាងយេនឌ័រដែ

[51] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ខែ កក្កដា ឆ្នាំ ២០០៣ ដែលបានផ្ដល់សច្ចាប័ននៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤) ចូលអាននៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ នៅ www.eccc.gov.kh/english/cabinet/agreement/5/។ សម្រាប់សាវតាស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា សូមមើល John D.Ciorciari, ed., *សាលាក្ដីខ្មែរក្រហម* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០៦)។

[52] ដីកាដំណោះស្រាយ, សំណុំរឿង 002/19-9-2007-ECCC-OCIJ, កថាខណ្ឌ ៨៤៣-៤៤, ១៤៣០, ១៤៤១។

[53] សេចក្ដីថ្លែងការណ៍៖ "សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំការស៊ើបអង្កេតការចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងសំណុំរឿង ០០៤" (ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤) ចូលអាននៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ នៅ

Deleted: ដោយសារ

Deleted: *Unrevised translation. A revised translation will be provided upon request.*

លជាឧបករណ៍ដែលត្រូវបានប្រើដោយរបបនោះ ដើម្បីគ្រប់គ្រង និងបណ្ដុះភាពភ័យរន្ធត់ដែលជាផ្នែកមួយនៃអំពើឃោរឃៅទូទៅ។

Toy-Cronin បានរៀបរាប់អំពីរបៀបដែលអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងប្រទេសកម្ពុជាគឺមានលក្ខណៈពិសេស ដោយសារជនរងគ្រោះរបស់វាមានទាំងបុរស និងស្ត្រី ទោះបីជានាងកំណត់បទឧក្រិដ្ឋនេះថាបានសម្តែងក្រោមរបបខ្មែរក្រហមនៅក្នុងបរិបទនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងសំណុំរឿងដែលមានពីមុននៅក្នុងតុលាការពិសេសរបស់ប្រទេសសៀរ៉ាឡេអូន និងតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដាក៏ដោយ។ ដូចគ្នានេះដែរ N. Anderson រៀបរាប់ចេញពីទស្សនវិស័យផ្នែកច្បាប់នូវភ័ស្តុតាងដែលប្រមូលបាននៅឆ្នាំ ២០១០ នៅក្នុងលក្ខខណ្ឌនៃការចោទប្រកាន់លើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា[54]។ K. Anderson បានលើកឡើងពីករណីជាមុន (មុនពេលអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង) អំពីមូលហេតុដែលបទឧក្រិដ្ឋខាងយេនឌ័រគួរតែត្រូវបានសង្កត់ធ្ងន់ក្នុងការស៊ើបអង្កេត និងការកាត់សេចក្ដី[55]។ Natale ពិនិត្យមើលបទឧក្រិដ្ឋផ្លូវភេទ និងយេនឌ័រដែលមិនត្រូវបានគ្របដណ្ដប់ដោយអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា យោងតាមការចោទប្រកាន់របស់ខ្លួនសម្រាប់សំណុំរឿង ០០២/០២ (ដូចជាការរំលោភសេពសន្ថវៈនៅខាងក្រៅនៃអាពាហ៍ពិពាហ៍ដោយបង្ខំ)[56] ប៉ុន្តែទោះយ៉ាងណាជារឿងសំខាន់ដើម្បីយល់ពីបរិបទពេញលេញនៃអំពើហិង្សាខាងយេនឌ័រក្រោមរបបនេះ។ Braafពង្រីកការស្រាវជ្រាវនេះដើម្បីរាប់បញ្ចូលអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ដោយអះអាងថា "មានភ័ស្តុតាងដែលថា ការអនុវត្តរបស់ពួកខ្មែរក្រហមស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានប្រើប្រឆាំងនឹងជន

www.eccc.gov.kh/en/articles/internationalco-prosecutor-requests-investigation-alledged-sexual-and-gender-based-violence។

[54] Natalae Anderson, "អនុស្សរណៈ RE៖ អាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០ ចូលអាននៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៤ នៅ www.d.dccam. org/Abouts/Intern/Natalae_Forced_marriage.pdf។

[55] Katrina Anderson, "ការបើកការផ្សះផ្សាពីលើថ្នាក់ដឹកនាំរបស់វា៖ ការឆ្លើយតបទៅនឹងអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម" ទិនានុប្បវត្តិទីក្រុងស៊ីថលសម្រាប់យុត្តិធម៌សង្គម ៣:២ (ឆ្នាំ ២០០៥)៖ ទំព័រ ៧៨៥-៨៣២។

[56] Natale, "ខ្ញុំអាចមានអារម្មណ៍ថាព្រលឹងខ្ញុំហោះហើរ"។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ជាតិភាគតិចមួយចំនួនដើម្បីរំលាយសហគមន៍នោះ ចូលទៅក្នុងចំនួនប្រជាជនខ្មែរ” ដែលជាការអនុវត្តដែលត្រូវនឹងនិយមន័យអន្តរជាតិនៃអំពើប្រល័យពូជសាសន៍[57]។

ក្រុមអ្នកស្រាវជ្រាវ និងអ្នកអនុវត្តបានរិះគន់យ៉ាងចាស់ដៃលើរបៀបដែលអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានទទួលយកបទឧក្រិដ្ឋកម្មដែលទាក់ទងនឹងយេនឌ័រក្នុងន័យទូទៅ និងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងន័យដោយឡែក។ de Langis ពិនិត្យមើលវិធីសាស្ត្រតូចចង្អៀត និងមានការស្ទាក់ស្ទើរក្នុងការ_កាត់សេចក្តីលើបទឧក្រិដ្ឋខាងយេនឌ័រ រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ហើយក៏គូសបញ្ជាក់ពីស្តង់ដារអន្តរជាតិដែលធានានូវសិទ្ធិនៅក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខស្តីពីស្ត្រី សន្តិភាព និងសន្តិសុខនៅក្នុងជម្លោះ និងនៅក្រោមរបបជិះជាន់[58]។

Studzinsky ដែលបានបម្រើជាមេធាវីភាគីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាអស់រយៈពេលជាយូរមកហើយ រិះគន់ “បទប្បញ្ញត្តិនៃអាពាហ៍ពិពាហ៍” ដែលជាវាក្យស័ព្ទប្រើក្នុងដីកាដំណោះស្រាយចំពោះសំណុំរឿង ០០២ ជាជាង “អាពាហ៍ពិពាហ៍ដោយបង្ខំ” ដោយអះអាងថាវាក្យស័ព្ទបែបនេះបន្ថយភាពធ្ងន់ធ្ងរនៃ “បទឧក្រិដ្ឋកម្មយ៉ាងរង្គាលជាប្រព័ន្ធប្រឆាំងនឹងជនស៊ីវិល” ទាំងនេះ។ នាងបន្តអះអាងទៀតថា ការចាត់ថ្នាក់តាមផ្លូវច្បាប់សម្រាប់អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅខាងក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំថាជា “អំពើឃោឃៅដទៃទៀត” ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

---

[57] Braaf, “អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច” ទំព័រ x។

[58] Theresa de Langis, “ឱកាសខកខានមួយ ក្តីសង្ឃឹមចុងក្រោយ? ការកាត់ទោសឧក្រិដ្ឋកម្មផ្លូវភេទក្រោមរបបខ្មែរក្រហម” *ទិនានុប្បវត្តិច្បាប់ និងគោលនយោបាយនៃប្រទេសកម្ពុជា* ២ (ឆ្នាំ ២០១៤)៖ ទំព័រ ៣៩-៤៣។ សូមមើលផងដែរដោយអ្នកនិពន្ធដដែល “លទ្ធផលនៃការប្រមូលទិន្នន័យមូលដ្ឋានរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលការកម្ពុជាស្តីពីភាពរសើបខាងយែនឌ័រក្នុងដំណើរការតុលាការបណ្តោះអាសន្ននៅក្នុងប្រទេសកម្ពុជា” (ភ្នំពេញ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ ២០១១) ចូលអាននៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ នៅ gbvkr.org/wp-content/uploads/2013/01/Results-of-the-ECCC-Baseline-on-Gender-Sensitivity-in-Transitional-Justice-Processes-in-Cambodia-20121.pdf។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ជាតិគឺ "មិនគ្រប់គ្រាន់" និង "មិនបានពិចារណាលើគ្រប់ទិដ្ឋភាពទាំងអស់ដូចជាការបណ្តាលឱ្យមានផ្ទៃពោះ និងទាសករផ្លូវភេទ"[59]។

បញ្ហានេះគឺមិនមែនគ្រាន់តែជាការគិតគូរពិចារណាផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស សន្តិភាព និងសន្តិសុខ និងការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាទៀតផង។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនតាំងពីឆ្នាំ ២០១១ ការិយាល័យតំណាងពិសេសរបស់អគ្គលេខាធិការស្តីពីអំពើហិង្សាផ្លូវភេទក្នុងគ្រាមានជម្លោះ បានជំរុញឱ្យអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាប្រើប្រាស់ធនធានពេញលេញរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាឧក្រិដ្ឋកម្មផ្លូវភេទរួមទាំងការស៊ើបអង្កេតនិងការពង្រីកវិសាលភាពនៃការដែលអាចចោទប្រកាន់បាន ក៏ដូចជាការផ្តល់ការទទួលស្គាល់ និងសំណងគ្រប់គ្រាន់ដល់ជនរងគ្រោះ[60]។ លើសពីនេះទៀត នៅក្នុងសេចក្តីសង្កេតចុងក្រោយរបស់ខ្លួនស្តីពីរបាយការណ៍តាមដំណាក់កាលលើទីបួន និងលើកទីប្រាំរួមបញ្ចូលគ្នាស្តីពីប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៣ គណៈកម្មាធិការសម្រាប់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) បានអំពាវនាវឱ្យមានការអភិវឌ្ឍដោយរាជរដ្ឋាភិបាលកម្ពុជានូវផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ស្របតាម UN SCR 1325 និងដំណោះស្រាយពាក់ព័ន្ធរបស់វា។ គណៈកម្មាធិការនេះបានផ្តល់អនុសាសន៍នូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ជនរងគ្រោះ។ ដំណោះស្រាយនេះរួមទាំងការផ្តល់សំណង និងការធ្វើសមាហរណកម្មគ្រប់គ្រាន់នៃបញ្ហាទាំងនេះទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិដែលមានគោលបំណងដោះ

---

[59] Silke Studzinsky, "ខ្វាក់ភ្នែកម្ខាង? តើអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាជាគំរូពីរបៀបដែលបទឧក្រិដ្ឋហិង្សាផ្លូវភេទគួរតែត្រូវបានស៊ើបអង្កេតហើយដោះស្រាយ"? វិទ្យាស្ថាន Gerda Werner Institute៖ ស្ត្រីនិយម និងប្រជាធិបតេយ្យ (ឆ្នាំ ២០១២) ចូលអាននៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ នៅ www.gwi-boell.de/en/2012/04/16/blind-one-eye-icc-model-how-sexual-crimes-should-be-investigated-and-treated។

[60] របាយការណ៍របស់អគ្គលេខាធិការស្តីពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ ឯកសាររបស់អង្គការសហប្រជាជាតិ Doc.S/2014/181 (ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៤)៖ "ចាប់តាំងពីរបាយការណ៍មុនរបស់ខ្ញុំស្តីពីអំពើហិង្សាផ្លូវភេទក្នុងគ្រាមានជម្លោះ គ្មានប្រព័ន្ធរដ្ឋាភិបាលណាមួយត្រូវបានដាក់ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់ខ្ញុំដែលថា គេត្រូវកាត់ទោសជនល្មើសប្រកបដោយប្រសិទ្ធភាព។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ស្រាយអំពើហិង្សាលើស្ត្រី និងវិសមភាពយេនឌ័រនៅសម័យនេះ[61]។ ដោយសារតែវាមានរយៈពេលជាង ៣០ ឆ្នាំមកហើយចាប់តាំងពីការដួលរលំនៃរបបនេះ ក៏ដូចជាផលប៉ះពាល់ជាយូរនៃអាពាហ៍ពិពាហ៍ដោយបង្ខំទៅលើឋានៈ និងសុខុមាលភាពរបស់ស្ត្រី និងបុរសជាច្រើន នោះសំណងសម្រាប់ឧក្រិដ្ឋកម្មអាពាហ៍ពិពាហ៍ដោយបង្ខំអាចត្រូវបានរួមបញ្ចូលនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាឲ្យផ្តល់សំណង "ជាសមូហភាព និងជានិមិត្តរូប"។ សំណងក៏អាចមានទម្រង់ជាការផ្តួចផ្តើមក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយតម្រូវការរបស់ប្រជាជនដែលមានវ័យចំណាស់ឲ្យបានយ៉ាងរហ័ស ដែលមិនត្រូវបានអើពើជាយូរមកហើយពីការពិចារណាផ្នែកសន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

---

[61] សេចក្តីអង្កេតចុងក្រោយស្តីពីរបាយការណ៍តាមដំណាក់កាលលើទីបួន និងលើកទីប្រាំរួមបញ្ចូលគ្នាស្តីពីប្រទេសកម្ពុជា, CEDAW Comm., សម័យប្រជុំលើកទី ៥៦, ឯកសាររបស់អង្គការសហប្រជាជាតិ U.N. Doc. CEDAW/C/KHM/CO/4-5 at 3-4 (2013)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

## III
## វិធីសាស្ត្រ

Deleted: *Unrevised translation. A revised translation will be provided upon request.*

## ១. គោលបំណងនៃការស្រាវជ្រាវ

គោលដៅចម្បងនៃការស្រាវជ្រាវនេះគឺដើម្បីយល់ដឹងអំពីបទពិសោធន៍ និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមរបបខ្មែរក្រហមរហូតដល់សព្វថ្ងៃ ចេញពីទស្សនវិស័យជូនដំណឹងពីការប៉ះទង្គិចផ្លូវចិត្ត និងការឆ្លើយតបខាងយេនឌ័រ។

## ២. ការរចនាក្នុងការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានការចូលរួមពីអ្នកឆ្លើយសំណួរចំនួន ១០៦ នាក់ ដែលសុទ្ធតែជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។

ការស្រាវជ្រាវនេះបានប្រើប្រាស់វិធីសាស្ត្រចម្រុះសម្រាប់ការប្រមូល និងការវិភាគទិន្នន័យ ដោយរួមបញ្ចូលគ្នារវាងការស្ទង់មតិស្តង់ដារបែបបរិមាណវិស័យចំនួន ៩៣ សំណួរ (ដោយមានឱកាសតិចតួចបំផុតសម្រាប់ការឆ្លើយតបបែបគុណភាពវិស័យ) ជាមួយនឹងបទសម្ភាសន៍បែបគុណភាពវិស័យជាករណីសិក្សាចំនួនប្រាំបី។ ខណៈពេលដែលការប្រមូលទិន្នន័យបែបបរិមាណវិស័យមានគោលបំណងដើម្បីកំណត់អត្រាប្រេវ៉ាឡង់លំនាំ និងប្រភេទនៃអ្នកឆ្លើយសំណួរ ("ប៉ុន្មាន" និង "កម្រិតណា") ការប្រមូលទិន្នន័យបែបគុណភាពវិស័យមានគោលបំណងដើម្បីរៀបរាប់ស៊ីជម្រៅពីករណីពិសេស និងទិដ្ឋភាពនៅក្នុងបរិបទប្រវត្តិសាស្ត្រសង្គមទៅតាមពេលវេលា ("របៀបណា" និង "ហេតុអ្វី" និង "មានអ្វីកើតឡើងក្រោយមក")[62]។

សនិទានភាពសម្រាប់ការស្រាវជ្រាវដោយប្រើវិធីសាស្ត្រចម្រុះរួមមាន បំណងប្រាថ្នាក្នុងការបង្កើតជារូបភាពទូលំទូលាយនៃផលវិបាកពីគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងរបបខ្មែរក្រហម ជាពិសេសក្នុងបរិបទកម្ពុជា។ នេះរួមបញ្ចូលទាំងឥទ្ធិពលនៃតួនាទីយេនឌ័រ និងការអនុវត្តខាងវប្បធម៌ស្ដីពីការជំរុញផ្ទាល់ខ្លួន ការធ្វើសេចក្ដីសម្រេចចិត្ត និងការផ្ដល់អត្ថន័យ។ លើសពីនេះទៀត វិធីសាស្ត្រចម្រុះបានអនុញ្ញាតសម្រាប់ការកើតមាននៃការឆ្លើយតបដែលមិនបានរំពឹងទុក ហេតុនេះវាផ្ដល់នូវទស្សនវិស័យមួយដែលកាន់តែធំជាងអ្វីដែលអាចនឹងទទួលបាននៅក្នុងការស្ទង់មតិស្តង់ដារតាមវិធីសាស្ត្រតែមួយ និងជំរុញឲ្យមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីទីមនុស្សជាបុគ្គលក្នុងប្រព័ន្ធសរុបមួយ។ ជាចុងក្រោយ ការរចនាការស្រាវជ្រាវបែបវិធីសាស្ត្រចម្រុះបានបញ្ជាក់ពីផលប៉ះពាល់ពហុវិស័យ នៅក្នុងទម្រង់នៃការផលប៉ះពាល់ផ្នែកច្បាប់ ផ្លូវចិត្ត វប្បធម៌ និងសង្គម

Formatted: Condensed by 0.4 pt

[62] …

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ដោយរួមចំណែកទៅដល់ "សេណារីយ៉ូរូបភាពទាំងមូល" នៃអ្វីដែលរហូតមកទល់ឥឡូវនេះគឺជាចំណុច_វិភាគដែលមិនត្រូវបានស្រាវជ្រាវគ្រប់គ្រាន់ និងយល់បានតិចតួច។

ការស្រាវជ្រាវនេះបានប្រើប្រាស់គំរូតាមគោលបំណង ក្នុងចំណោមក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ ដែលបានជួបប្រទះដោយផ្ទាល់នូវអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមរបបខ្មែរក្រហម។ ភាគច្រើននៃគំរូនេះគឺជាអតិថិជនរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) និងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ជាផ្នែកមួយនៃគម្រោងរួមគ្នា[63]។ ក្នុងចំណោមអតិថិជនរបស់ TPO និងជាជនរងគ្រោះដោយផ្ទាល់ដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំសរុបចំនួន ៦៤ នាក់ អតិថិជនចំនួន ៥៩ នាក់ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការស្ទង់មតិនេះ។ ក្នុងចំណោមអតិថិជនរបស់ CDP និងជាជនរងគ្រោះដោយផ្ទាល់ ដោយអាពាហ៍ពិពាហ៍ដោយបង្ខំសរុបចំនួន ៣២ នាក់ អតិថិជនចំនួន ៣០ នាក់ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការសិក្សានេះ។ លើសពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៧ នាក់ ដែលជាជនរងគ្រោះដោយផ្ទាល់ដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែមិនបានអត្ថប្រយោជន៍ពីគម្រោងនេះក៏ត្រូវបានស្នើឱ្យចូលរួមក្នុងការសិក្សានេះដែរ។ អ្នកចូលរួមទាំងអស់ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់ដូចខាងក្រោម។

គំរូចំនួនសរុបនៃដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០៦ នាក់ត្រូវបានសុំឱ្យបំពេញកម្រងសំណួរស្ទង់មតិមួយ ដែលត្រូវបានផ្តល់ដោយអ្នកសម្ភាសន៍ដែលមានបទពិសោធន៍ និងបុគ្គលិកនៃមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ (CAS)។ ក្នុងចំណោមអ្នកឆ្លើយសំណួរទាំង ១០៦ នាក់នេះ អ្នកឆ្លើយសំណួរ ៩ នាក់ត្រូវបានជ្រើសសម្រាប់បទសម្ភាសន៍ករណីសិក្សាបែបគុណភាពវិស័យចំនួន ៨ ដោយបទសម្ភាសន៍មួយធ្វើឡើងលើទាំងប្តី និងប្រពន្ធ។ ដើម្បីកាត់បន្ថយ "ស្ថានភាពអ្នកខាងក្រៅ" ក្នុងអំឡុងពេលសម្ភាស ទើបបទសម្ភាសន៍ទាំងអស់ត្រូវបានធ្វើឡើងជាភាសាខ្មែរដោយក្រុមអ្នកស្រាវជ្រាវខ្មែរ ដោយមានក្រុមអ្នកស្រាវជ្រាវអន្តរជាតិគាំទ្រ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការរចនាឧបករណ៍ស្រាវជ្រាវ និងវិភាគលទ្ធផលនៃការស្រាវ ជ្រាវនេះ។ បទសម្ភាសន៍ករណីសិក្សា និងលទ្ធផលនៃការស្ទង់មតិត្រូវបានបកប្រែទៅជាភាសាអង់គ្លេសពីភាសាខ្មែរសម្រាប់ការវិភាគ។ អ្នកពិគ្រោះយោបល់អន្តរជាតិ និងជាផ្នែកមួយនៃក្រុមស្រាវជ្រាវនេះត្រូវបានគេចាត់ឱ្យមកសរសេររបាយការណ៍នេះដោយផ្អែកលើការរកឃើញនៃការស្រាវជ្រាវ។

Deleted: ស្រាវជ្រាវ

[63] សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោងនេះ សូមមើល៖ gbvkr.org។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

បទសម្ភាសន៍ករណីសិក្សាត្រូវបានបង្ហាញនៅក្នុងទម្រង់សំយោគ ដើម្បីលុបបំបាត់ភាពស្ទួនគ្នា និងដើម្បីបញ្ជាក់ពីចំណុចដែលមានខ្លឹមសារស្របគ្នារវាងដំណើររឿងផ្សេងៗគ្នា។ នៅកន្លែងដែលពាក់ព័ន្ធ និងអាចធ្វើទៅបានពាក្យផ្ទាល់ខ្លួនរបស់អ្នកឆ្លើយសំណួរត្រូវបានគេប្រើនៅក្នុងការដកស្រង់ចេញយ៉ាងវែងនៅក្នុងរបាយការណ៍នេះ ដើម្បីផ្ដល់ជាកិត្តិយសពេញលេញដល់ការចូលរួមចំណែករបស់ពួកអ្នកដែលបានចែករំលែករឿងរ៉ាវរបស់ពួកគេនៅក្នុងស្មារតីនៃការយល់ដឹងកាន់តែច្រើន អំពីបទពិសោធន៍អាពាហ៍ពិពាហ៍ដោយបង្ខំ។

Deleted:

ដើម្បីរួមបញ្ចូលគំរូជាតំណាងមួយ លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចូលរួមទាំង ១០៦ នាក់មានដូចខាងក្រោម៖

- ជនដែលត្រូវបានបង្ខំដោយពួកខ្មែរក្រហមឲ្យរៀបអាពាហ៍ពិពាហ៍
- ជនដែលរៀបអាពាហ៍ពិពាហ៍រួចហើយមុនរបបខ្មែរក្រហម ប៉ុន្តែត្រូវបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀតនៅក្រោមរបបខ្មែរក្រហម
- គូស្វាមីភរិយាដែលរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបន្តរស់នៅជាមួយគ្នា ឬចែកផ្លូវគ្នា ក្រោយថ្ងៃរំដោះ
    - ដោយមានកូន ឬគ្មានកូន
    - បើបានចែកផ្លូវគ្នា បានរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ឬមិនបានរៀបអាពាហ៍ពិពាហ៍ទៀត
    - ប្ដីរស់នៅបែកពីគ្នា បាត់ខ្លួន ត្រូវសម្លាប់ ស្លាប់ដោយសារមូលហេតុផ្សេងទៀត
- ជនដែលបដិសេធចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ
    - ដោយមានការផ្ដាញ់ផ្ដាលពិន័យ (ទណ្ឌកម្ម ដាក់គុក ការរំលោភសេពសន្ថវៈ ជាដើម)
    - គ្មានការផ្ដាញ់ផ្ដាលពិន័យ

លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសបទសម្ភាសន៍ករណីសិក្សាបែបគុណភាពវិស័យទាំង ៨ មានដូចខាងក្រោម៖

- បុរស ស្ត្រី គូស្វាមីភរិយា
- ករណី "ធម្មតា" ឬ "មធ្យម"
- ឧទាហរណ៍សំខាន់ៗ ករណីមិនធម្មតា ឬពិសេសប្លែក
    - ករណីធ្ងន់ធ្ងរ៖ ឧទាហរណ៍នៃករណីដែលមានលក្ខណៈធ្ងន់ធ្ងរ ឬដែលមិនធម្មតាធៀបនឹង "ករណីមធ្យម"

Deleted: *Unrevised translation. A revised translation will be provided upon request.*

- “ក្រុមដែលមានស្រាប់”៖ បទពិសោធន៍ផ្សេងៗគ្នានៃក្រុមផ្សេងៗគ្នា (ដោយផ្អែកលើជាតិសាសន៍ សាសនា ទីតាំងភូមិសាស្ត្រ ភេទ អាយុ ស្ថានភាពអាពាហ៍ពិពាហ៍មុន/នាពេលបច្ចុប្បន្នជាដើម)

ការស្រាវជ្រាវនេះបានប្រើប្រាស់ការអនុវត្តក្រមសីលធម៌ល្អបំផុត ដោយផ្តោតលើវិធីសាស្ត្រជូនដំណឹងពីការប៉ះទង្គិចផ្លូវចិត្តនៅក្នុងការស្រាវជ្រាវពីមនុស្ស ជាមួយអ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ។ អ្នកសម្ភាសន៍ករណីសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកសម្រាប់ការស្រាវជ្រាវពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រជាមធ្យោបាយនៃការកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ខណៈដែលស៊ើបអង្កេតពីប្រធានបទរសើបខ្លាំង។ អ្នកសម្ភាសន៍សម្រាប់ការស្ទង់_មតិបែបបរិមាណវិស័យត្រូវបានបង្វឹក និងត្រួតពិនិត្យដោយបុគ្គលិកអង្គការ TPO និងចិត្តវិទូអន្តរជាតិម្នាក់។ ទិន្នន័យត្រូវបានប្រមូលចន្លោះពីខែ កុម្ភៈ ដល់ខែ មេសាឆ្នាំ ២០១៤។អ្នកឆ្លើយសំណួរចំនួន១០០ នាក់សម្រាប់ការស្ទង់មតិ និងបុគ្គល ៧ នាក់សម្រាប់ករណីសិក្សាត្រូវបានសម្ភាសនៅកន្លែងអង្គការ TPO នៅក្នុងរាជធានីភ្នំពេញហើយដូច្នេះគេអាចទទួលបានការគាំទ្រផ្លូវចិត្តតាមរយៈអ្នកផ្តល់សេវាមួយដែលគួរឱ្យជឿទុកចិត្ត។លើស ពីនេះទៀត ការស្ទង់មតិចំនួន ៦ និងបទសម្ភាសន៍ករណីសិក្សាចំនួន ២ ត្រូវបានធ្វើឡើងនៅកំពត ក្នុងអំឡុងពេលមកពិនិត្យសុខភាពដែលបានកំណត់ពេលជាទៀងទាត់ដោយអង្គការ TPO ក្នុងការអនុវត្តរបស់ខ្លួននៃកម្មវិធីសម្រាប់អ្នករស់រានពីរបបខ្មែរក្រហម។ អ្នកឆ្លើយសំណួរទាំងអស់ត្រូវបានផ្តល់លេខទូរសព្ទ័ផ្តល់ជំនួយ_របស់អង្គការ TPO ក្រែងពួកគេត្រូវការការគាំទ្រផ្លូវចិត្តបន្ត។ ការព្រមព្រៀងដែលបានជូនដំណឹងត្រូវបានផ្តល់ជូននៅក្នុងករណីទាំងអស់ ដោយរក្សាការសម្ងាត់។ ដើម្បីសម្រេចគោលបំណងនេះ ត្រឹមតែអាទិសង្កេត_ប៉ុណ្ណោះដែលត្រូវបានប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកឆ្លើយសំណួរក្នុងករណីសិក្សា និងឈ្មោះរបស់បុគ្គលណាមួយដែលត្រូវបានចោទប្រកាន់ក្នុងបទសម្ភាសន៍នេះត្រូវបានដកចេញ។ ការបញ្ចូល និងវិភាគទិន្នន័យត្រូវបានធ្វើឡើងដោយប្រើកម្មវិធីកញ្ចប់ស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម (SPSS) កំណែ ១៦.០។

### ៣. ដែនកំណត់

ដោយសារអ្នកឆ្លើយសំណួរទាំងអស់ គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ការរកឃើញគឺមានភាពលម្អៀងទៅរកអ្នកដែលបានបញ្ចេញឱ្យដឹងរួចទៅហើយនូវបទពិសោធន៍របស់ពួកគេនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងអំឡុងពេលដំណើរការនៃការដាក់ពាក្យសុំធ្វើជាដើមបណ្តឹ

Formatted: Condensed by 0.4 pt

Deleted:

Formatted: Condensed by 0.4 pt

Deleted: ។ អ្នក

Formatted: Condensed by 0.4 pt

Deleted:

Formatted: Condensed by 0.4 pt

Deleted:

Deleted: ។ លើស

Deleted: *Unrevised translation. A revised translation will be provided upon request.*

ងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ក្នុងនោះភាគច្រើនបានចាត់ទុកអាពាហ៍ពិពាហ៍ដោយបង្ខំថាជាបទឧក្រិដ្ឋមួយ។ ការស្រាវជ្រាវនេះមិនបានព្យាយាមកំណត់ពីប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍ដោយបង្ខំទេ ដោយសារវាត្រូវបានអនុវត្តតែជាមួយគំរូតូចមួយ ហើយការរកឃើញពីករណីសិក្សាក៏មិនអាចប្រើតំណាងឲ្យប្រជាជនទូទៅបានដែរ។ ការស្រាវជ្រាវនេះមិនបានព្យាយាមស្វែងយល់ឲ្យបានស៊ីជម្រៅពីការប្រែប្រួលនៅក្នុងការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមរបបនោះ នៅក្នុងលក្ខខណ្ឌនៃអត្តសញ្ញាណតាមតំបន់ សាសនា ជាតិសាសន៍ ឬភាពខុសគ្នារវាងប្រជាជន "ថ្មី" ធៀបនឹងប្រជាជន "ចាស់"។

គំរូស្រាវជ្រាវនេះមិនមានតុល្យភាពតាមសមាមាត្រនៃអ្នកឆ្លើយសំណួរជាស្ត្រី និងអ្នកឆ្លើយសំណួរជាបុរស ដោយសារមានតំណាងយ៉ាងច្រើនជាស្ត្រី។ នេះគឺដោយសារតែមូលដ្ឋានអតិថិជនរបស់អង្គការ TPO និង CDP ដែលបានផ្តោតកិច្ចខិតខំប្រឹងប្រែងលើការជួយខ្លួនឯង និងការគាំទ្រដទៃទៀតដល់ជនរងគ្រោះជាស្ត្រីពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម។ ការស្រាវជ្រាវបន្ថែមគឺចាំបាច់ ដោយផ្តោតលើការឆ្លើយតបរបស់បុរសចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានទាំងការរំលោភសេពសន្ថវៈដោយបង្ខំ និងផលប៉ះពាល់មកលើអត្តសញ្ញាណយេនឌ័រ និងតួនាទីក្នុងសង្គមរបស់បុរស។

ភាគច្រើននៃអ្នកចូលរួមក្នុងការសិក្សានេះគឺជាអតិថិជនរបស់អង្គការ TPO និង CDP ក្នុងគម្រោងរួមគ្នាដែលដោះស្រាយលើអំពើហិង្សាខាងយេនឌ័រក្នុងរបបខ្មែរក្រហម។ ដូច្នេះហើយ អ្នកចូលរួមអាចមានការយល់ដឹង និងចំណេះដឹងច្រើនអំពីអាពាហ៍ពិពាហ៍ដោយបង្ខំជាងជនរងគ្រោះដោយផ្ទាល់ផ្សេងទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដូចគ្នានេះផងដែរ អ្នកចូលរួមអាចមានអារម្មណ៍ថាមានផាសុកភាពក្នុងការឆ្លើយតបទៅនឹងសំណួរ ដោយសារពួកគេបានបង្កើតឲ្យមានទំនាក់ទំនងនៃការជឿទុកចិត្តជាមួយបុគ្គលិកអង្គការ TPO រួចហើយ។ ជាលទ្ធផល ការរកឃើញនៃការសិក្សានេះមិនអាចតំណាងឲ្យជនរងគ្រោះដោយផ្ទាល់ផ្សេងទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំបានទេ។

តាមនិយមន័យ ការបកប្រែបង្ហាញពីដែនកំណត់ក្នុងការយល់ដឹង និងការឆ្លើយឆ្លងគ្នាក្នុងអត្ថន័យនៃគោលគំនិត។ ការបកប្រែត្រូវបានផ្ទៀងផ្ទាត់ និងហើយគោលគំនិតត្រូវបានពិភាក្សាតាមការចាំបាច់ ក៏ដូចជាប្រៀបធៀបទល់នឹងការស្រាវជ្រាវពីមុនដែលបានចេញផ្សាយ។ ក្រុមការងារស្រាវជ្រាវ និងវិភាគស្នូលគឺមានលក្ខណៈពហុវប្បធម៌ រួមផ្សំដោយជនជាតិអាមេរិកម្នាក់ ជនជាតិអាល្លឺម៉ង់ម្នាក់ និងជនជាតិខ្មែរពីរនាក់ ដែលទាំងអស់គ្នាសុទ្ធតែជាស្ត្រី។ អ្នកសម្ភាសន៍ CAS បានរួមបញ្ចូលទាំងបុរស និងស្ត្រីសម្រាប់បទសម្ភាសន៍ស្ទង់មតិ ខណៈដែលបុគ្គលិកជាស្ត្រីដែលបានទទួលការបណ្តុះបណ្តាលនៅអង្គការ TPO បានធ្វើការសម្ភាសករណី

Deleted: *Unrevised translation. A revised translation will be provided upon request.*

សិក្សា។ ភាពខុសគ្នាខាងយេនឌ័រ និងអត្តសញ្ញាណផ្សេងទៀតទាំងនេះមុខជាប៉ះពាល់ដល់ការវិភាគ និងការបកស្រាយលទ្ធផល។

Deleted: *Unrevised translation. A revised translation will be provided upon request.*

# IV
# លទ្ធផល

Deleted: *Unrevised translation. A revised translation will be provided upon request.*

**១. ការរកឃើញនៃការស្ទង់មតិ (បរិមាណវិស័យ)**

**ក. លក្ខណៈតាមបែបប្រជាសាស្ត្ររបស់អ្នកឆ្លើយ**

គ្រប់អ្នកឆ្លើយសំណួរទាំង ១០៦ នាក់បានរាយការណ៍ថា ពួកគេត្រូវបានស្នើឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម ដោយ ១០៣ នាក់ (៩៧,២%) រាយការណ៍ថា នៅទីបំផុតពួកគេបានរៀបការ។ អ្នកទាំងអស់គ្នាគឺជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។

អាយុជាមធ្យមនៃអ្នកឆ្លើយសំណួរគឺ ៥៨ ឆ្នាំ អ្នកដែលមានវ័យក្មេងបំផុតគឺមានអាយុ ៤៧ ឆ្នាំ ហើយអ្នកដែលមានវ័យចំណាស់បំផុតគឺមានអាយុ ៧១ ឆ្នាំ។ ភាគច្រើនបានកំណត់អត្តសញ្ញាណថាជាជនជាតិខ្មែរ (៩៣,៤%) ដោយអ្នកដែលនៅសល់ត្រូវកំណត់បានអត្តសញ្ញាណថាជាជនជាតិខ្មែរចាម (ឬឥស្លាម)។ ក្នុងចំណោមអ្នកឆ្លើយសំណួរទាំង ១០៦ នាក់ មានស្ត្រី ៨៨ នាក់ និងបុរស ១៨ នាក់។ ភាគច្រើនគឺបានរៀបការ (៦២,៣%) ប៉ុន្តែជិតមួយភាគបី (៣១,១%) រាយការណ៍ថាជាអ្នកមេម៉ាយ ឬពោះម៉ាយ។

តារាង ១. លក្ខណៈប្រជាសាស្ត្រនៃអ្នកឆ្លើយសំណួរ

- ទំហំគំរូ៖ ១០៦ នាក់
- ស្រី៖ ៨៣%
- អាយុជាមធ្យម៖ ៥៨

អ្នកឆ្លើយសំណួរបានរាយការណ៍ថារស់នៅក្នុងខេត្តចំនួន ១៤ ផ្សេងគ្នាមុនពេលដែលរបបខ្មែរក្រហមឡើងកាន់អំណាច។

| ក្រុមអាយុ | | |
|---|---|---|
| ៤៥-៥៥ | ៥៦-៦៥ | > ៦៥ |
| ២៨% | ៦៤% | ៨% |

| ជាតិសាសន៍ | |
|---|---|
| ខ្មែរ | កំពង់ចាម |
| ៩៣,៤% | ៦,៦% |

| ស្ថានភាពអាពាហ៍ពិពាហ៍ |
|---|

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

| រៀបការ | លែងលះគ្នា | ចែកផ្លូវគ្នា | មេម៉ាយ/ពោះម៉ាយ |
|---|---|---|---|
| ៦២,៣% | ២,៨% | ៣,៨% | ៣១,១% |

**ខ. អាពាហ៍ពិពាហ៍មុនពេលរបបខ្មែរក្រហម**

តារាង ២. បណ្តាខេត្តនៃអ្នកឆ្លើយសំណួរមុនពេលរបបខ្មែរក្រហមឡើងកាន់អំណាច

| | |
|---|---|
| សៀមរាប | ៦% |
| បាត់ដំបង | ៧% |
| កំពង់ធំ | ៩% |
| ពោធិ៍សាត់ | ១៣% |
| កំពង់ចាម | ១២% |
| កំពង់ឆ្នាំង | ៤% |
| កំពង់ស្ពឺ | ៣% |
| ភ្នំពេញ | ២% |
| ព្រៃវែង | ១១% |
| កណ្តាល | ៥% |
| កំពត | ១៧% |
| តាកែវ | ៤% |
| ស្វាយរៀង | ៤% |
| កំពង់សោម | ៣% |

ជាងពាក់កណ្តាលនៃអ្នកឆ្លើយសំណួរគឺជាកសិករ (៥៨,៧%) ខណៈដែលអ្នកផ្សេងទៀតបានរាយការណ៍ជាចម្បងថាមាន "មុខរបរផ្សេងទៀត" មុនពេលដល់ខែ មេសា ឆ្នាំ ១៩៧៥ ដូចជាការធ្វើការងារនៅស្រែអំបិល មើលខុសត្រូវផលិតកម្មស្រូវ ឆ្អើរត្រី ត្បាញ ធ្វើការងារផ្ទះ ឬជាព្រះសង្ឃ។

រូបភាព ១. មុខរបររបស់អ្នកឆ្លើយសំណួរមុនពេលរបបខ្មែរក្រហម

| កសិករ | មន្ត្រីរាជការ | អាជីវកម្មផ្ទាល់ខ្លួន | ផ្សេងទៀត |
|---|---|---|---|

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

| | | | |
|---|---|---|---|
| ៥៨,៧% | ៣% | ២% | ៣៦,៣% |

ភាគច្រើននៃអ្នកឆ្លើយសំណួរ (៩១,៣%) មិនមានកូនទេមុនពេលរបបខ្មែរក្រហម ដោយអ្នកឆ្លើយសំណួរចំនួន ៨២ នាក់ (៧៨,៨%) រាយការណ៍ថា ពួកគេនៅលីវនៅពេលពួកខ្មែរក្រហមឡើងកាន់អំណាច។ ក្នុងចំណោមអ្នកឆ្លើយតប ៦ នាក់ដែលបានរាយការណ៍ថាមានកូនមុនពេលរបបនេះ ភាគច្រើន (៦៦,៧%) បានរាយការណ៍ថាមានកូនពីរនាក់។

តារាង ៣. ស្ថានភាពអាពាហ៍ពិពាហ៍របស់អ្នកឆ្លើយមុនរបបខ្មែរក្រហម

| ស្ថានភាពអាពាហ៍ពិពាហ៍* | | | |
|---|---|---|---|
| នៅលីវ | រៀបការ | សុំរៀបការ | លែងលះគ្នា/ចែកផ្លូវគ្នា |
| ៨០,៨% | ៩,៦% | ៧,៧% | ១,៩% |

* ស្ថានភាពអាពាហ៍ពិពាហ៍គឺផ្អែកលើអ្នកចូលរួមចំនួន ១០៤ នាក់

ក្នុងចំណោមអ្នកឆ្លើយសំណួរ ១២ នាក់ដែលបានរៀបការមុនពេលពួកខ្មែរក្រហមឡើងកាន់អំណាច មានអ្នកឆ្លើយសំណួរ ១០ នាក់ (៨៣,៣%) រាយការណ៍ថា ការរៀបការរបស់ពួកគេត្រូវបានរៀបចំ ដោយមានត្រឹមតែ ២ នាក់ប៉ុណ្ណោះដែលរាយការណ៍ថាការរៀបការរបស់ពួកគេមិនត្រូវបានរៀបចំ។ ក្នុងចំណោមអ្នកដែលបានរៀបការតាមការរៀបចំ ៦៤,៧% រាយការណ៍ថាអាពាហ៍ពិពាហ៍នេះត្រូវបានរៀបចំឡើងដោយឪពុកនិងម្តាយ ហើយ ២៧,៣% ដោយសាច់ញាតិផ្សេងទៀត។

ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ១០ នាក់ដែលការរៀបការរបស់ពួកគេត្រូវបានរៀបចំ ច្រើនជាងពាក់កណ្តាល (៦៣,៦%) នៃអ្នកឆ្លើយសំណួរបានរាយការណ៍ថា អាពាហ៍ពិពាហ៍តាមការរៀបចំជាជម្រើសរបស់ពួកគេ ខណៈដែលអ្នកដែលបានរាយការណ៍ថាអាពាហ៍ពិពាហ៍តាមការរៀបចំគឺមិនមែនជាជម្រើសរបស់ពួកគេ ជាញឹកញាប់បំផុតបង្ហាញថា សម្ពាធក្នុងគ្រួសារជាមូលហេតុសម្រាប់អាពាហ៍ពិពាហ៍។

តារាង ៤. ជម្រើសរបស់អ្នកឆ្លើយសំណួរក្នុងការរៀបការនៅក្នុងអាពាហ៍ពិពាហ៍តាមការរៀបចំនៅមុនពេលរបបខ្មែរក្រហម

| ជម្រើសដើម្បីរៀបការជាមួយ |
|---|

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

| ជម្រើសរបស់អ្នកឆ្លើយសំណួរ | មិនមែនជាជម្រើសរបស់អ្នកឆ្លើយសំណួរ |
|---|---|
| ៦៣.៦% | ៣៦,៤% |

អ្នកឆ្លើយតបភាគច្រើន (៦៤,០%) រាយការណ៍ថាមានអាយុពី ១៨-៤៩ ឆ្នាំនៅពេលរៀបអាពាហ៍ពិពាហ៍ ខណៈដែល ៤០,០% រាយការណ៍ថាមានអាយុពី ១៣ ទៅ ១៧ ឆ្នាំ។ ដៃគូត្រូវបានគេរាយការណ៍ថាមានអាយុពី ១៨-៤៩ ឆ្នាំដោយ ៧៧,៨% នៃអ្នកឆ្លើយសំណួរ និងមានអាយុពី ១៣ និង ១៧ ឆ្នាំដោយ ២២,២ % នៃអ្នកឆ្លើយសំណួរ។

តារាង ៥. អាយុរបស់អ្នកឆ្លើយសំណួរ និងដៃគូនៅពេលរៀបការមុនពេលរបបខ្មែរក្រហម

| អាយុនៅពេលរៀបការ | | | |
|---|---|---|---|
| អ្នកឆ្លើយសំណួរ | | ដៃគូ | |
| ១៣-១៧ | ១៨-៤៩ | ១៣-១៧ | ១៨-៤៩ |
| ៤៥,៥% | ៥៤,៥% | ១៨,២% | ៨១,៨% |

ក្នុងចំណោមអ្នកដែលនៅក្នុងអាពាហ៍ពិពាហ៍តាមរៀបចំមុនពេលសម័យខ្មែរក្រហម ៦៣,៦% បានរាយការណ៍ថាបានស្គាល់ដៃគូមុនពេលរៀបការ។ នៅក្នុងសំណួរបើកចំហនៅក្នុងការស្ទង់មតិនេះ អ្នកឆ្លើយសំណួរបានរាយការណ៍ថា អាពាហ៍ពិពាហ៍របស់ពួកគេមុនពេលរបបខ្មែរក្រហមមានលក្ខណៈ "មានសុភមង្គល" និង "មានភាពសុខដុម" ដោយដៃគូមានទំនាក់ទំនងល្អ និង "រស់នៅជាមួយគ្នាដោយសន្តិភាព"។

គ្មាននរណាម្នាក់ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ១២ នាក់ដែលបានរៀបការមុនពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាច រាយការណ៍ថាបានជួបប្រទះអំពើហិង្សាពីសំណាក់ដៃគូរបស់ពួកគេទេ[64]។

**គ. អាពាហ៍ពិពាហ៍នៅក្នុងអំឡុងពេលរបបខ្មែរក្រហម**

អ្នកឆ្លើយសំណួរបានរាយការណ៍ថារស់នៅក្នុងខេត្តចំនួន ១៥ នៅពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាច។

[64] ការរំលោភបំពានក្នុងគ្រួសារទំនងជាកើតឡើងមុនរបបខ្មែរក្រហម ប៉ុន្តែវាមិនត្រូវបានរាយការណ៍ក្នុងគំរូរបស់យើង។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

តារាង ៦. ខេត្ត និងស្រុកដែលជាកន្លែងដែលអ្នកឆ្លើយសំណួររស់នៅពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាច

| | |
|---|---|
| សៀមរាប | ៦% |
| បាត់ដំបង | ៧% |
| កំពង់ធំ | ៩% |
| ពោធិ៍សាត់ | ១៣% |
| កំពង់ចាម | ១២% |
| កំពង់ឆ្នាំង | ៤% |
| កំពង់ស្ពឺ | ៣% |
| ភ្នំពេញ | ៣% |
| ព្រៃវែង | ១១% |
| កណ្ដាល | ៥% |
| កោះកុង | ២% |
| កំពត | ១៤% |
| តាកែវ | ៤% |
| ស្វាយរៀង | ៤% |
| កំពង់សោម | ៣% |

ជាងពាក់កណ្ដាលនៃអ្នកឆ្លើយសំណួរ (៥៦,៣%) បានរស់នៅជាផ្នែកមួយនៃកងចល័តនៅក្នុងអំឡុងពេលនេះ។ មានតែអ្នកឆ្លើយសំណួរចំនួន ១១ នាក់ប៉ុណ្ណោះដែលបានរាយការណ៍ថារស់នៅជាមួយក្រុមគ្រួសារ ឬសាច់ញាតិក្នុងអំឡុងពេលរបបនេះ ហើយមានតែ ៦ នាក់ដែលបានរាយការណ៍ថារស់នៅជាមួយដៃគូរបស់ខ្លួន។

រូបភាព ២. តើអ្នករស់នៅជាមួយនរណានៅក្នុងរបបខ្មែរក្រហម?

| កងចល័ត | សហករណ៍ | ក្រុមគ្រួសារ/សាច់ញាតិ | ប្ដីប្រពន្ធ/ដៃគូ | ផ្សេងទៀត |
|---|---|---|---|---|
| ៥៦,៣% | ២០,៨% | ១១,៥% | ៦,៣% | ៥,២% |

Formatted Table

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ភាគច្រើននៃអ្នកឆ្លើយសំណួរ (៨១,៧%) បានរាយការណ៍ថាធ្វើការងារជាកសិករក្រោមរបបនោះ។ ជាងពាក់កណ្តាល (៥៥,៨%) រាយការណ៍ថាត្រូវបានចែកថ្នាក់ជាប្រជាជន "ថ្មី" ក្នុងអំឡុងសម័យនោះ។ អ្នកឆ្លើយសំណួរជាជនជាតិចាមទាំងអស់បានរាយការណ៍ថាត្រូវបានគេចាត់ថ្នាក់ទៅក្នុងប្រភេទនេះ។

រូបភាព ៣. ការងារដែលធ្វើដោយអ្នកឆ្លើយសំណួរនៅក្នុងអំឡុងពេលរបបខ្មែរក្រហម

| កសិករ | គិនុប្បដ្ឋាក/យិការ | មេភូមិ | ទាហាន | ផ្សេងទៀត |
|---|---|---|---|---|
| ៨១,៧% | ៣,៨% | ១,៩% | ១,៩% | ១០,៦% |

សម្រាប់អ្នកដែលបានរៀបការមុនពេលរបបខ្មែរក្រហម ច្រើនជាងពាក់កណ្តាល (៥៧,១%) បានរាយការណ៍ថា ដៃគូត្រូវបានសម្លាប់ក្នុងអំឡុងសម័យនោះ ដោយ ១៤,៣% ផ្សេងទៀតបានរាយការណ៍ថា ដៃគូបានបាត់ខ្លួន។ តិចជាងមួយភាគបួន (២១,៤%) នៃដៃគូក្នុងចំណោមអាពាហ៍ពិពាហ៍ពីមុនរបបខ្មែរក្រហមត្រូវបានគេរាយការណ៍ថាបានរស់រានមានជីវិតពីសម័យនោះ។

តារាង ៧. ជោគវាសនារបស់ដៃគូរវាងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩

| ជោគវាសនារបស់ដៃគូ | | | |
|---|---|---|---|
| ត្រូវសម្លាប់ | រស់រានមានជីវិតពីរបបនោះ | បាត់ខ្លួន | ផ្សេងទៀត |
| ៥៧,១% | ២១,៤% | ១៤,៣% | ៧,១% |

អ្នកឆ្លើយសំណួរទាំង ១០៦ នាក់បានរាយការណ៍ថា ពួកគេត្រូវបានស្នើឲ្យរៀបការនៅក្នុងរបបខ្មែរក្រហម ហើយ ១០៣ នាក់ (៩៧,២%) បានរៀបការនៅទីបំផុត។

អ្នកឆ្លើយសំណួរបានរាយការណ៍ថា ត្រូវបានស្នើជាច្រើនដងឲ្យរៀបការ ដោយ ២២,១% បានរាយការណ៍ថាត្រូវបានស្នើច្រើនជាងបីដងឲ្យរៀបការ។

រូបភាព ៤. ចំនួនដងដែលអ្នកឆ្លើយសំណួរត្រូវបានគេស្នើឲ្យរៀបការនៅក្រោមរបបខ្មែរក្រហម

| ម្តង | ពីរដង | បីដង | ច្រើនជាងបីដង |
|---|---|---|---|
| ២៩,៤% | ៣២,៤% | ១៦,២% | ២២,១% |

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ការបដិសេធ ក្នុងកម្រិតមួយ ហាក់ដូចជារឿងធម្មតា។ ដោយមិនមានការឆ្លើយតបចំនួន ៩ អ្នកឆ្លើយសំណួរចំនួន ៧៣ នាក់ (៧០,២%) បានរាយការណ៍ថាបានបដិសេធសំណើឲ្យរៀបការ។ ក្នុងចំណោមអ្នកដែលបដិសេធមិនព្រម អ្នកឆ្លើយសំណួរ ២១ នាក់ (២៩,៤%) បានថ្លែងថាបានបដិសេធម្តង អ្នកឆ្លើយសំណួរ ២៣ នាក់ (៣១,៩%) រាយការណ៍ថា បានបដិសេធពីរដង និងស្ទើរតែមួយភាគបួន (២៣,៦%) រាយការណ៍ថាបានបដិសេធច្រើនជាងបីដង។

រូបភាព ៥. ចំនួនដងដែលអ្នកឆ្លើយតបបានបដិសេធមិនរៀបការនៅក្រោមរបបខ្មែរក្រហម

| ម្តង | ពីរដង | បីដង | ច្រើនជាងបីដង |
|---|---|---|---|
| ២៩,៤% | ៣២,៤% | ១៦,២% | ២២,១% |

ភាគច្រើននៃអ្នកឆ្លើយសំណួរបានរាយការណ៍ថាទទួលរងការគំរាមកំហែង ឬការដាក់ទណ្ឌកម្មពិតប្រាកដចំពោះការបដិសេធមិនរៀបការ។ អ្នកឆ្លើយសំណួរ ៤៨ នាក់ (៦៦,៧%) រាយការណ៍ថាបានទទួលរងការគំរាមកំហែងដោយពាក្យសម្តីសម្រាប់ការបដិសេធ ហើយ ៥ នាក់បានរាយការណ៍ថាត្រូវគេដាក់គុក និង ២ នាក់បានរាយការណ៍ថាត្រូវគេធ្វើទារុណកម្ម។

រូបភាព ៦. ផលវិបាកនៃការបដិសេធមិនរៀបការនៅក្នុងអំឡុងរបបខ្មែរក្រហម

| គ្មានសោះ | រងការគំរាមកំហែងដោយពាក្យសម្តី | ជាប់គុក | រងទារុណកម្ម | ផ្សេងទៀត |
|---|---|---|---|---|
| ១៧,៦% | ៦៩,១% | ៧,៤% | ២,៩% | ២,៩% |

ក្នុងចំណោមអ្នកដែលបានរៀបការនៅទីបំផុត អ្នកឆ្លើយសំណួរ ៨៥ នាក់ (៨៤,២%) រាយការណ៍ថាមានអាយុពី ១៨-៤៩ ឆ្នាំនៅពេលរៀបការ។ ១៥ នាក់ (១៤,៩%) រាយការណ៍ថាមានអាយុពី ១៣ ទៅទៅ ១៧ ឆ្នាំ។ អ្នកឆ្លើយសំណួរម្នាក់បានរាយការណ៍ថាបានរៀបការនៅអាយុ ១២ ឆ្នាំ ឬក្មេងជាងនេះ។

ក្នុងចំណោមអ្នកឆ្លើយសំណួរជាជនជាតិចាម ៧ នាក់ មានម្នាក់បានរាយការណ៍ថាត្រូវបានស្នើឲ្យរៀបការជាមួយជនជាតិខ្មែរ។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

អ្នកឆ្លើយសំណួរ ៤៤ នាក់ (៤៣,៦%) បានរាយការណ៍ថាត្រូវបានគេ "ហៅទៅប្រជុំ" នៅការដ្ឋានរបស់ពួកគេ និងដឹងថាពួកគេត្រូវរៀបការ។ មួយចំនួនធំ (អ្នកឆ្លើយតប ៣៤ នាក់) ត្រូវបានជូនដំណឹងជាឯកជន។ អ្នកឆ្លើយសំណួរ ១៥ នាក់មិនបានដឹងមុនពេលនីតិវិធីរៀបការទេថា ពួកគេនឹងត្រូវរៀបការ។

រូបភាព ៧ តើអ្នកដឹងថាអ្នកនឹងត្រូវរៀបការតាមរបៀបណា?

| គេហៅប្រជុំ | គេជូនដំណឹងជាឯកជន | មិនបានដឹងជាមុន | គេប្រកាសជាសាធារណៈ | ផ្សេងទៀត |
|---|---|---|---|---|
| ៤៤,៧% | ៣៥,១% | ១៦% | ២,១% | ២,១% |

ដោយមិនមានការឆ្លើយតប ៥ ករណី អ្នកឆ្លើយសំណួរ ៤៧ នាក់ (៤៦,៥%) រាយការណ៍ថាបានស្គាល់មនុស្សនោះ ឬដឹងអំពីមនុស្សនោះមុនពេលរៀបអាពាហ៍ពិពាហ៍ ដោយប្រជាជន "ថ្មី" មិនសូវស្គាល់ពីមនុស្សដែលពួកគេត្រូវបានចាត់តាំងឱ្យទៅរៀបការជាមួយ (២៩,៧% នៃប្រជាជន "ថ្មី" មិនបានស្គាល់ដៃគូដែលត្រូវបានចាត់តាំងរបស់ពួកគេបើធៀបនឹង ២៣,៨% នៃប្រជាជន "ចាស់")។

អ្នកឆ្លើយសំណួរ ៩៨ នាក់ ឬ ៩៧,0% បានរាយការណ៍ថាវាមិនមែនជាជម្រើសរបស់ពួកគេទេដែលត្រូវរៀបការ ដោយប្រជាជន "ចាស់" ទំនងជារាយការណ៍ថាវាជាជម្រើសរបស់ពួកគេច្រើនជាងបន្តិច (២,១% បើធៀបនឹង 0.0% សម្រាប់ប្រជាជន "ថ្មី")។

តារាង ៨. ជម្រើសរបស់អ្នកឆ្លើយសំណួរក្នុងការរៀបការដែលរៀបចំដោយពួកខ្មែរក្រហម

| ជម្រើសក្នុងការរៀបការ | |
|---|---|
| ជម្រើសរបស់អ្នកឆ្លើយសំណួរ | មិនមែនជាជម្រើសរបស់អ្នកឆ្លើយសំណួរ |
| ៣% | ៩៧% |

អ្នកឆ្លើយសំណួរ ៧២ នាក់ (៧៥.0%) រាយការណ៍ថាត្រូវបានបង្ខំឱ្យរៀបការបើទោះបីវាមិនមែនជាជម្រើសរបស់ពួកគេ ដោយសារតែការគំរាមកំហែងដោយពាក្យសម្តី។ ១៨ នាក់ទៀត (១៨,៨%) រាយការណ៍ថាមានអារម្មណ៍រងសម្ពាធដោយការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម។ ៥ នាក់ទៀត (៦,២%) រាយការណ៍ថាត្រូវបានបង្ខំឱ្យរៀបការតាមរយៈអំពើហិង្សាផ្លូវកាយ។

រូបភាព ៨. តើអ្នកត្រូវបានបង្ខំឱ្យរៀបការតាមរបៀបណា?

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

| ការគំរាមកំហែងដោយពាក្យសម្តី | ការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម | អំពើហិង្សាផ្លូវកាយ |
|---|---|---|
| ៧៥% | ១៨,៨% | ៦,២% |

ដោយមិនមានការឆ្លើយតប ៥ ករណី អ្នកផ្តល់បទសម្ភាសន៍បានថ្លែងថា នីតិវិធីរៀបមង្គលការត្រូវបានរៀបចំភាគច្រើនដោយពួកកម្មាភិបាលខ្មែរក្រហម (៧០,៣%) ។

តារាង ៩. តើនរណាជាអ្នករៀបចំពិធីមង្គលការ?

| ភ្នាក់ងារដែលរៀបចំពិធីមង្គលការ* | | | | |
|---|---|---|---|---|
| កម្មាភិបាលខ្មែរក្រហម | កងជីវពល (ឈ្លប) | ជនស៊ីវិល | ប្រធានកងចល័ត | ទាហានខ្មែរក្រហម |
| ៧០,៣% | ១២,៧% | ៨,៥% | ៧,៥% | ១% |

* ភ្នាក់ងារគឺផ្អែកលើអ្នកចូលរួម ១០១ នាក់

អ្នកឆ្លើយសំណួរ ៨៩ នាក់ (៨៨,១%) រាយការណ៍ថាមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យរួមភេទបន្ទាប់ពីពិធីមង្គលការនេះ ដោយមិនមានការឆ្លើយតប ៥ ករណី។ ៤២ នាក់ (៤៧,២%) បានរាយការណ៍ថាត្រូវបានបង្ខំតាមរយៈការគំរាមកំហែងដោយពាក្យសម្តី និងអ្នកឆ្លើយសំណួរ ៣០ នាក់ផ្សេងទៀត (៣៣,៧%) បានរាយការណ៍ថាមានអារម្មណ៍ថាត្រូវគេបង្ខំដោយត្រូវបានតាមដានដោយភ្នាក់ងារខ្មែរក្រហម។ អ្នកឆ្លើយសំណួរ ១៤ នាក់ (១៥,៧%) រាយការណ៍ថាភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម ហើយ ៣ នាក់ (៣,៤%) រាយការណ៍ថាត្រូវបានបង្ខំតាមរយៈកម្លាំងផ្លូវកាយ។

រូបភាព ៩. ហេតុអ្វីបានជាអ្នកមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យរួមភេទបន្ទាប់ពីពិធីមង្គលការនោះ?

| ការគំរាមកំហែងដោយពាក្យសម្តី | ការត្រួតពិនិត្យ/តាមដាន | ការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម | កម្លាំងផ្លូវកាយ |
|---|---|---|---|
| ៤៨,៨% | ៣២,៦% | ១៦,៣% | ២,៣% |

អ្នកឆ្លើយសំណួរជាច្រើន (៤២,៨%) រាយការណ៍ថាភ័យខ្លាចបាត់បង់ជីវិតទាក់ទងនឹងពិធីមង្គលការដោយពួកខ្មែរក្រហម។ ១៥,៣% ថ្លែងថា ពួកគេមិនស្រឡាញ់ដៃគូរបស់ពួកគេ ឬគ្មានអារម្មណ៍ចង់រួមភេទនៅក្នុងទំនាក់ទំនងនេះទេ។ ៣៣,៨% បានរាយការណ៍ថាមាអារម្មណ៍អន្ទះសា និងខកចិត្តអំពីពិធីមង្គលការនេះ

Deleted: *Unrevised translation. A revised translation will be provided upon request.*

ហើយ ៨,២% នៃអ្នកឆ្លើយសំណួរបានរៀបរាប់ជាក់លាក់ថាអវត្តមាននៃឪពុកម្តាយជាប្រភពចម្បងនៃការខកចិត្តអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ។

រូបភាព ១០. តើអ្នកមានអារម្មណ៍បែបណាអំពីអាពាហ៍ពិពាហ៍នៅពេលនោះ?

| ភ័យខ្លាចស្លាប់ | អន្ទះសា/ខកចិត្ត | មិនមានអារម្មណ៍ស្រឡាញ់/គ្មានអារម្មណ៍ចង់រួមភេទ | ខកចិត្តដោយឪពុកម្តាយមិនមានវត្តមាន |
|---|---|---|---|
| ៤២,៨% | ៣៣,៧% | ១៥,៣% | ៨,២% |

អ្នកឆ្លើយសំណួរជាច្រើន (៣៥ នាក់ ឬ ៣៩,៣%) រាយការណ៍ថាបានជួបដៃគូរបស់ពួកគេបន្ទាប់ពីពិធីមង្គលការក្នុងអំឡុងរបបខ្មែរក្រហមបានតែម្តងប៉ុណ្ណោះក្នុងមួយខែ ដោយ ១៧ នាក់ (១៩,១%) រាយការណ៍បានជួបគ្នារៀងរាល់សប្តាហ៍ និង ១៥ នាក់ (១៦,៩%) រាយការណ៍ថាបានជួបគ្នាជារៀងរាល់ថ្ងៃ។ អ្នកឆ្លើយសំណួរ ១៣ នាក់ បានជួបដៃគូបានតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយ ៩ នាក់បានរាយការណ៍ថាមិនដែលបានជួបដៃគូម្តងទៀតទេបន្ទាប់ពីពិធីមង្គលការ។

នៅក្នុងសំណួរបើកចំហ អ្នកឆ្លើយសំណួរមានការឆ្លើយតបជាវិជ្ជមាន និងអវិជ្ជមានចំពោះទំនាក់ទំនងជាមួយនឹងដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងអំឡុងរបបខ្មែរក្រហម។ អ្នកខ្លះបានរាយការណ៍ថា "មានអារម្មណ៍ស្រឡាញ់" និង "គោរព" ហើយស្វាមីត្រូវបានលើកឡើងថាបានផ្តល់ការគាំទ្រដល់ភរិយាក្នុងអំឡុងពេលមានផ្ទៃពោះ។ ចិត្តអាណិតអាសូរ និងការថែរក្សាគ្នាទៅវិញទៅមកក៏ត្រូវបានលើកឡើងផងដែរក៏ដូចសមភាពក្នុងអាពាហ៍ពិពាហ៍ថាជាលក្ខណៈវិជ្ជមាននៃទំនាក់ទំនង៖ "យើងទាំងពីរយោគយល់គ្នា និងចុះសម្រុងគ្នា"។

របាយការណ៍នៃអារម្មណ៍អវិជ្ជមានមានច្រើនជាង រួមទាំងការខ្វះក្តីស្រឡាញ់ ខ្វះការប្រាស្រ័យទាក់ទងមិនសូវមានអារម្មណ៍ចង់រួមភេទជាមួយ ឬសូម្បីតែមិនសូវមានភាពត្រូវគ្នា៖ "ខ្ញុំមិនចូលចិត្តគាត់ទេ"។ អ្នកឆ្លើយសំណួរបានរាយការណ៍ពីទំនាក់ទំនងដែលមិនចុះសម្រុងគ្នា និងគ្មានអារម្មណ៍ស្និទ្ធស្នាលជាមួយដៃគូរបស់ពួកគេដែលគេបង្ខំឱ្យរៀបការជាមួយ៖ "ជាញឹកញាប់ ខ្ញុំបដិសេធមិនរួមភេទជាមួយដៃគូរបស់ខ្ញុំដែលគេបង្ខំឱ្យរៀបការជាមួយ"។ ការឆ្លើយតបបានសំដៅយ៉ាងជាក់លាក់ដល់ការរំលោភបំពានដោយដៃគូ៖ "ខ្ញុំពិតជាមានការភ័យខ្លាចក្នុងការរស់នៅជាមួយដៃគូរបស់ខ្ញុំដែលគេបង្ខំឱ្យរៀបការជាមួយ"។ "ប្តីខ្ញុំបានប្រព្រឹត្តអំពើហិង្សាដាក់ខ្ញុំ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ដោយរំលោភបំពានទាំងកាយ និងផ្លូវចិត្ត ហើយគាត់ចោទខ្ញុំថាមិនមានភាពស្មោះត្រង់"។ "ខ្ញុំមិនមានអារម្មណ៍ល្អចំពោះប្ដីខ្ញុំទេ ដោយសារតែគាត់តែងតែចង់ខ្ញុំរួមភេទជាមួយគាត់"។ អ្នកឆ្លើយសំណួរម្នាក់បានរាយការណ៍ថាមានអារម្មណ៍ជាប់ផុងនៅក្នុងការទំនាក់ទំនងនេះ៖ "ខ្ញុំមិនស្រឡាញ់ដៃគូរបស់ខ្ញុំទេ ហើយខ្ញុំចង់ចែកផ្លូវជាមួយគាត់"។

ក្នុងចំណោមស្ត្រីដែលរាយការណ៍ថាមានផ្ទៃពោះដោយសារការបង្ខំឱ្យរៀបការ អ្នកឆ្លើយសំណួរ ៦៩ នាក់ (៩២%) រាយការណ៍ថាមិនបានប៉ុនប៉ងរំលូតកូនទេ។ របាយការណ៍នៃការប៉ុនប៉ងរំលូតកូនក្នុងចំណោមអ្នកឆ្លើយសំណួរ ៦ នាក់ដែលនៅសល់ រួមមានការបង្ករបួសដោយខ្លួនឯងដូចជាការលើករបស់ធ្ងន់ ការរត់ និងប៉ុនប៉ងឱ្យដួល ដោយមួយចំនួនតូចរាយការណ៍ថាបានប្រើថ្នាំបុរាណជាមធ្យោបាយសម្រាប់ការជំរុញឱ្យរលូតកូន។

ជិតមួយភាគបួននៃអ្នកឆ្លើយសំណួរ (២៤,៥%) បានរាយការណ៍ពីការរំលោភបំពានពីសំណាក់ដៃគូក្នុងអំឡុងរបបនោះជាផ្នែកមួយនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ក្នុងចំណោម ២៨ នាក់ដែលបានរាយការណ៍ថាបានជួបប្រទះការរំលោភបំពានពីសំណាក់ដៃគូក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ អ្នកឆ្លើយសំណួរ ១០ នាក់ (៣៥,៧%) រាយការណ៍ពីអំពើហិង្សាផ្លូវកាយ ដោយ ៦ នាក់ (២១,៤%) ផ្សេងទៀតរាយការណ៍ពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ។ ក្នុងចំណោមអ្នកដែលជួបប្រទះការរំលោភបំពាន មួយភាគបួន (អ្នកឆ្លើយសំណួរ ៧ នាក់ ឬ ២៥%) បានជួបប្រទះវាជារៀងរាល់ថ្ងៃ ខណៈដែល ៦ នាក់ (២១,៤%) បានជួបប្រទះវាតិចជាងម្ដងក្នុងមួយឆ្នាំ ដែលភាគច្រើនទំនងជាដោយសារតែដៃគូដែលត្រូវបានបង្ខំឱ្យរៀបការជាមួយត្រូវបានបំបែកពីគ្នាឱ្យទៅធ្វើការងារ (សូមមើលខាងក្រោម)។ ចំនួនស្មើគ្នានៃអ្នកឆ្លើយសំណួរ (១៧,៩%) បានរាយការណ៍ថាអំពើហិង្សាពីសំណាក់ដៃគូបានកើតមានឡើងពីមួយទៅបីដងក្នុងមួយសប្ដាហ៍ ឬក្នុងមួយខែ ឬម្ដងក្នុងមួយឆ្នាំ។

រូបភាព ១១. ប្រភេទនៃការរំលោភបំពានពីសំណាក់ដៃគូក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងអំឡុងរបបខ្មែរក្រហម

| អំពើហិង្សាផ្លូវកាយ | ការរំលោភបំពានដោយពាក្យសម្ដី | ការរំលោភសេពសន្ថវៈ/អំពើហិង្សាផ្លូវភេទ | ការគំរាមកំហែងដោយពាក្យសម្ដី | ផ្សេងទៀត |
|---|---|---|---|---|
| ៣៥,៧% | ២៥% | ២១,៤% | ១៤,៣% | ៣,៦% |

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

នៅក្នុងសំណួរបើកចំហ អ្នកឆ្លើយសំណួរបានរៀបរាប់ពីការរំលោភបំពាននៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួននៅក្នុងអំឡុងពេលរបបនោះ។ អ្នកខ្លះបានរៀបរាប់ពីការរំលោភបំពានផ្លូវភេទ និងការរំលោភសេពសន្ថវៈដែលបានចាប់ផ្ដើមនៅយប់នៃពិធីអាពាហ៍ពិពាហ៍នេះ៖ "បន្ទាប់ពីពិធីមង្គលការ ប្ដីខ្ញុំបានបង្ខំឱ្យខ្ញុំដោះសម្លៀកបំពាក់របស់ខ្ញុំ ហើយបង្ខំខ្ញុំឱ្យរួមភេទជាមួយគាត់។ គាត់បាននិយាយថា បើខ្ញុំបដិសេធ នោះគាត់នឹងសម្លាប់ខ្ញុំ"។ ស្ត្រីម្នាក់បានរំលឹកថាត្រូវបានរំលោភដោយប្ដីរបស់នាងនៅអាយុ ១៥ ឆ្នាំ។ នារីម្នាក់ទៀតបាននិយាយថា "គាត់តែងតែបង្ខំខ្ញុំឱ្យរួមភេទជាមួយគាត់ ហើយបើខ្ញុំមិនចង់ គាត់នឹងទះកំផ្លៀងខ្ញុំ ហើយបន្ទាប់ពីការរួមភេទ ខ្ញុំខ្សោយ និងស្លេកស្លាំង"។ អ្នកឆ្លើយសំណួរផ្សេងទៀតបានរៀបរាប់អំពីការវាយដំលើរាងកាយ និងការរំលោភបំពានដោយពាក្យសម្ដីដែលបានកើតឡើងនៅទូទាំងរយៈពេលនៃអាពាហ៍ពិពាហ៍នេះ។

ភាគច្រើននៃអ្នកឆ្លើយសំណួរ (៧៧ នាក់ ឬ ៧៦,២%) បានរាយការណ៍ថាមានកូនដោយសារការបង្ខំឱ្យរៀបការ ដោយអ្នកឆ្លើយសំណួរ ៣៥ នាក់ (៤៤,៩%) រាយការណ៍ថាមានកូនច្រើនជាងបួននាក់ ហើយ ២៨ នាក់ (៣៥,៩%) រាយការណ៍ថាមានកូនតែម្នាក់។

តារាង ១០. ចំនួនកូននៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ

| ភ្នាក់ងារដែលរៀបចំពិធីមង្គលការ* | | | | |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | > ៤ |
| ៣៥,៩% | ៧,៧% | ៣,៨% | ៧,៧% | ៤៤,៩% |

* ចំនួនកូនគឺផ្អែកលើអ្នកចូលរួមចំនួន ១០៦ នាក់

ភាគច្រើននៃដៃគូ (៨២,០%) បានប្រាប់អ្នកដទៃអំពីអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេនៅក្នុងអំឡុងរបបខ្មែរក្រហម។ ក្នុងចំណោមអ្នកដែលបានរក្សាចំណងអាពាហ៍ពិពាហ៍របស់ពួកគេជារឿងសម្ងាត់ច្រើនជាងពាក់កណ្ដាល (៥២,៦%) បានរាយការណ៍ថាខ្មាស់អៀនដោយសារអាពាហ៍ពិពាហ៍នេះ ដោយ ៣៦,៨% ផ្សេងទៀតរាយការណ៍ពីការភ័យខ្លាចចំពោះការមាក់ងាយ និងការរើសអើង។

តារាង ១១. មូលហេតុដែលអ្នកឆ្លើយសំណួរមិនប្រាប់នរណាម្នាក់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ

| មូលហេតុអាពាហ៍ពិពាហ៍មិនបានបង្ហាញដោយបង្ខំ | | |
|---|---|---|
| អារម្មណ៍ខ្មាស់អៀន | ភ័យខ្លាចចំពោះការមាក់ងាយ និងការ | ផ្សេងទៀត |

Deleted: *Unrevised translation. A revised translation will be provided upon request.*

| | | |
|---|---|---|
| | រើសអើង | |
| ៥២,៦% | ៣៦,៨% | ១០% |

**ឃ. អាពាហ៍ពិពាហ៍ក្រោយពេលរបបខ្មែរក្រហម (ពេលគឺនៅក្រោយខែ មករា ឆ្នាំ ១៩៧៩)**

ភាគច្រើននៃអ្នកឆ្លើយសំណួរ (៦៨,១%) រាយការណ៍ថា ដៃគូរបស់ពួកគេបានរួចជីវិតពីរបបនោះ ដោយ ៧ នាក់ (៦,៩%) បានឆ្លើយតបថា ពួកគេមិនបានដឹងថាដៃគូរបស់ខ្លួនបានរួចជីវិត ឬយ៉ាងណានោះទេ។ ក្នុងចំណោមអ្នកឆ្លើយសំណួរ ៦៤ នាក់ដែលបានរាយការណ៍ថាដៃគូបានរួចជីវិតពីរបបនោះ ច្រើនជាងពាក់កណ្តាល (៥៣,១%) នៅតែនៅក្នុងអាពាហ៍ពិពាហ៍បន្ទាប់ពីរបបនោះ ហើយច្រើនជាងមួយភាគបួន (២៦,៦%) រាយការណ៍ថារស់នៅជាមួយដៃគូយ៉ាងហោចណាស់អស់មួយរយៈ។ អ្នកឆ្លើយសំណួរ ១២ នាក់ (២០,៣%) បានរាយការណ៍ពីការរស់នៅបែកពីគ្នាដោយសារតែការស្លាប់របស់ដៃគូ ឬមូលហេតុផ្សេងទៀត។

តារាង ១២. ស្ថានភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំបន្ទាប់ពីរបបខ្មែរក្រហម

| ស្ថានភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំបន្ទាប់ពីរបបខ្មែរក្រហម* | | |
|---|---|---|
| រស់នៅជាមួយគ្នា | រស់នៅជាមួយគ្នាមួយរយៈ | ចែកផ្លូវគ្នា/ដៃគូស្លាប់ |
| ៥៣,១% | ២៦,៦% | ២០,៣% |

* ស្ថានភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំបន្ទាប់ពីរបបខ្មែរក្រហមគឺផ្អែកលើលើអ្នកចូលរួម ១០២ នាក់

ចំពោះអ្នកឆ្លើយសំណួរដែលចែកផ្លូវពីដៃគូរបស់ខ្លួន ពាក់កណ្តាល (៥០,០%) បានធ្វើដូច្នេះមុនពេល ឬភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបនោះនៅឆ្នាំ ១៩៧៩ ដោយអ្នកឆ្លើយសំណួរ ១១ នាក់ (៣៤,៤%) រាយការណ៍ថាចែកផ្លូវគ្នារវាងពីឆ្នាំ ១៩៨០ ដល់ឆ្នាំ ១៩៨៣។ អ្នកឆ្លើយសំណួរ ៥ នាក់ (១៥,៦%) រាយការណ៍ថាចែកផ្លូវគ្នាបន្ទាប់ពីឆ្នាំ ១៩៨៣។

ចំនួនស្មើគ្នា (២៩,៤%) នៃអ្នកឆ្លើយសំណួរបានរាយការណ៍ពីការចែកផ្លូវពីដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយសារពួកគេមិនចុះសម្រុងគ្នា ឬដោយសារតែការស្លាប់។ មូលហេតុផ្សេងទៀតដែលបានផ្តល់ឲ្យសម្រាប់ការចែកផ្លូវគ្នារួមបញ្ចូលទាំងសម្ពាធពីក្រុមគ្រួសារ ឬសាច់ញាតិ (១៧,៦%), ការបោះបង់ចោល ឬការបាត់ខ្លួនរបស់ដៃគូ (៨,៨%), ការស្វែងរកដៃគូថ្មី (៨,៨%) និងការផ្លាស់ទីត្រឡប់ទៅខេត្តជាស្រុកកំណើតវិញ (៥,៩%)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

រូបភាព ១២. មូលហេតុរបស់អ្នកឆ្លើយសំណួរសម្រាប់ការចែកផ្លូវពីដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំ

| | |
|---|---|
| មិនចុះសម្រុងគ្នា | ២៩,៤% |
| ស្លាប់ | ២៩,៤% |
| សម្ពាធពីក្រុមគ្រួសារ/សាច់ញាតិ | ១៧,៦% |
| ដៃគូថ្មី | ៨,៨% |
| បោះបង់ចោល/បាត់ខ្លួន | ៨,៨% |
| ត្រឡប់ទៅខេត្តជាស្រុកកំណើត | ៥,៩% |

ក្នុងចំណោមអ្នកដែលចែកផ្លូវពីដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេ ៧០% បានរៀបការជាថ្មីម្តងទៀត ដោយមួយភាគបី (៣០,០%) រាយការណ៍ថាមិនបានរៀបការជាមួយថ្មីម្តងទៀតទេ។ ជិតពាក់កណ្តាលនៃអ្នកឆ្លើយសំណួរ (៤៥,២%) បានរាយការណ៍ថា សេចក្តីស្រឡាញ់ជាកត្តាជំរុញលើកទឹកចិត្តសំខាន់បំផុតក្នុងការរៀបការម្តងទៀត។ អ្នកសល់ពីនេះបានរាយការណ៍ថាបានរៀបការជាថ្មីម្តងទៀតដោយសារតែសម្ពាធគ្រួសារ (២១,៤%) ស្ថានភាពសេដ្ឋកិច្ច ឬសង្គមកាន់តែខ្ពស់ (១៤,៣%) ឬមានមូលហេតុមួយចំនួនផ្សេងទៀត។ ការឆ្លើយតបមួយបានរាយការណ៍ថាបានរៀបការតាមបំណងកូន។

រូបភាព ១៣. មូលហេតុរបស់អ្នកឆ្លើយសំណួរសម្រាប់ការរៀបការឡើងវិញបន្ទាប់ពីរបបខ្មែរក្រហម

| | |
|---|---|
| សេចក្តីស្រឡាញ់ | ៤៥,២% |
| សម្ពាធគ្រួសារ | ២១,៤% |
| ស្ថានភាពសេដ្ឋកិច្ច ឬសង្គមកាន់តែខ្ពស់ | ១៤,៣% |
| បំណងរបស់កូន | ២,៤% |
| ផ្សេងទៀត | ១៦,៧% |

សម្រាប់អ្នកដែលមិនបានរៀបការជាថ្មីម្តងទៀត ភាគច្រើន (៧២,២%) រាយការណ៍ពីចំណង់ចំណូលចិត្តថាមិនរៀបការដោយសារតែបញ្ហាទំនាក់ទំនង ដែលបានជួបប្រទះនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ។ ៥,៦ % ផ្សេងទៀតបានរាយការណ៍ថាមិនអាចរកដៃគូបាន ដោយសារតែពួកគេបានរៀបការរួចទៅហើយ ហើយ

Deleted: *Unrevised translation. A revised translation will be provided upon request.*

១១,១% បានរាយការណ៍ថាការមិនអាចរកដៃគូថ្មីដោយសារតែ “ចាស់ពេក”។ អ្នកឆ្លើយសំណួរ ៥,៦% រាយការណ៍ថាមិនបានរៀបការដើម្បីស្របតាមបំណងកូន។

រូបភាព ១៤. មូលហេតុរបស់អ្នកឆ្លើយសំណួរចំពោះការមិនបានរៀបការឡើងវិញបន្ទាប់ពីរបបខ្មែរក្រហម

| | |
|---|---|
| ចំណង់ចំណូលចិត្តមិនរៀបការ | ៧២,២% |
| “ចាស់ពេក” | ១១,១% |
| មិនអាចរកដៃគូបាន | ៥,៥% |
| បំណងប្រាថ្នារបស់កូន | ៥,៦% |
| ផ្សេងទៀត | ៥,៦% |

ច្រើនជាងពាក់កណ្ដាល (៥២,៥%) នៃអ្នកឆ្លើយសំណួរបានយកកូនមកចិញ្ចឹមបន្ទាប់ពីការរស់នៅបែកគ្នា ឬការស្លាប់របស់ដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយ ៤៥,៨% រាយការណ៍ថា មនុស្សម្នាក់ ផ្សេងទៀតដែលមិនមែនជាដៃគូបានយកកូនទៅចិញ្ចឹម។ អ្នកឆ្លើយសំណួរបានរៀបរាប់ពីទំនាក់ទំនងល្អជាមួយកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមានលក្ខណៈពោរពេញដោយ “ក្ដីស្រឡាញ់” និង “ក្ដីអាណិតអាសូរ"។ អ្នកឆ្លើយសំណួរតែម្នាក់គត់បានរាយការណ៍ពីទំនាក់ទំនងមិនល្អជាមួយនឹងកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយ ២ នាក់បានរាយការណ៍ថាគ្មានទំនាក់ទំនងជាមួយកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ ប៉ុន្តែ ជារួម ៩២,១% នៃអ្នកឆ្លើយសំណួរទាំងអស់បានរៀបរាប់ពីទំនាក់ទំនងកក់ក្ដៅ និងជិតស្និទ្ធជាមួយនឹងកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ។

ក្នុងចំណោមអ្នកដែលចែកផ្លូវគ្នា ពាក់កណ្ដាលនៃអ្នកឆ្លើយសំណួរ (៥០,៨%) រាយការណ៍ពីទំនាក់ទំនងកក់ក្ដៅ និងជិតស្និទ្ធជាមួយនឹងកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងដៃគូចាស់ ដោយមួយភាគបី (៣៤,០%) រាយការណ៍ពីការទំនាក់ទំនងមិនល្អ និង ១៥,៣% បានរាយការណ៍ពីទំនាក់ទំនងអព្យាក្រឹត ។ ភាគច្រើននៃអ្នកឆ្លើយសំណួរ (៧៥,០%) មិនបានបន្តទំនាក់ទំនងជាមួយជាអតីតដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំទេ។

អ្នកឆ្លើយសំណួរបានរាយការណ៍ពីផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានដែលជាលទ្ធផលនៃការស្លាប់ ឬការចែកផ្លូវពីដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅក្នុងសំណួរបើកចំហនៃការស្ទង់មតិនេះ អ្នកឆ្លើយសំណួរបានរាយការណ៍ថាមានអារម្មណ៍ល្អប្រសើរ និងមានសុខភាពផ្លូវចិត្តល្អជាងមុន បន្ទាប់ពីអាពាហ៍ពិពាហ៍បាន

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

បែកបាក់ដោយសារតែ “ការរៀបការត្រូវបានបង្ខំ ដូច្នេះដៃគូរបស់ខ្ញុំមិនបានស្រឡាញ់ខ្ញុំទេ”។ អ្នកផ្សេងទៀតបានរាយការណ៍ថារីករាយ ដោយមានសេរីភាពក្នុងការជ្រើសរើសដៃគូអាពាហ៍ពិពាហ៍របស់ខ្លួន។ អស់អ្នកដែលជួបប្រទះការរំលោភបំពានក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ បានរាយការណ៍ថាមានអារម្មណ៍ធូរស្បើយដោយសារ “ដោយគ្មានដៃគូពីអាពាហ៍ពិពាហ៍ដោយបង្ខំ គឺគ្មាននរណាប្រមាថខ្ញុំទេ” និង “គ្មាននរណាម្នាក់ធ្វើទារុណកម្មខ្ញុំទៀតទេ ឬបង្ខំឱ្យខ្ញុំរួមភេទទេ”។

ថ្វីបើការរស់នៅបែកគ្នាបាននាំឱ្យមានលទ្ធផលជាវិជ្ជមាន ក៏វាត្រូវបានរាយការណ៍ថាបាននាំមកនូវផលប៉ះពាល់អវិជ្ជមានផងដែរ។ ផលប៉ះពាល់ធ្ងន់ធ្ងរបំផុតពាក់ព័ន្ធនឹងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងភាពក្រីក្រដោយគ្មានសមត្ថភាព ឬជំនួយក្នុងការអនុវត្តភារកិច្ចធ្វើកសិកម្មហើយ ការលំបាកក្នុងការការគ្រប់គ្រងក្នុងគ្រួសារ ខណៈដែលដើរតួនាទីជាម្ដាយ និងឪពុក និងកង្វះការគាំទ្រទូទៅ ទាំងការគាំទ្រសង្គម និងហិរញ្ញវត្ថុ។ ការឆ្លើយតបមួយចំនួនបានចង្អុលបង្ហាញពីផលប៉ះពាល់យេនឌ័រនៃការចែកផ្លូវគ្នាបន្ទាប់ពីអាពាហ៍ពិពាហ៍ដោយបង្ខំទៅលើស្ត្រីជាពិសេស ដែលមានតួនាទីក្នុងសង្គមរបស់ខ្លួនត្រូវបានផ្ដោតទៅលើការរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារសម្រាប់ប្ដី និងកូន៖ “ក្នុងនាមជាស្ត្រីមេម៉ាយ ខ្ញុំលឺពាក្យអាក្រក់ និងការមាក់ងាយពីអ្នកជិតខាងរបស់ខ្ញុំ”។ “ខ្ញុំរងទុក្ខវេទនា និងមានទុក្ខព្រួយជាច្រើនដោយត្រូវបាត់បង់ប្ដី និងកូនរបស់ខ្ញុំក្នុងរបបនោះ”។ “ខ្ញុំបានជួបការលំបាកជាច្រើនដោយសារតែខ្ញុំគ្មាននរណាគាំទ្រដល់ខ្ញុំ”។ “ខ្ញុំមានការខកចិត្តដែលត្រូវរស់នៅឯកោ”។ “ជីវិតរបស់ខ្ញុំគឺទទេស្អាត”។

ក្នុងចំណោមអ្នកឆ្លើយសំណួរ ៥២ នាក់ដែលបានរាយការណ៍ថារស់នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំច្រើនជាងពាក់កណ្ដាល (៥៥,៨%) រាយការណ៍ថាធ្វើដូច្នេះដោយសារតែសេចក្ដីស្រឡាញ់។ ការលើកទឹកចិត្តយ៉ាងខ្លាំងក្លាបន្ទាប់ក្នុងការរស់នៅជាមួយគ្នា (៣៦,៥%) គឺការមានកូនជាមួយគ្នាចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។ សម្ពាធនៃក្រុមគ្រួសារ ក៏ដូចជាវប្បធម៌ប្រពៃណី (ដូចជាការយល់ឃើញថា ស្ត្រីដែលចែកផ្លូវគ្នាគឺមិនល្អ ឬមិនគោរពប្ដីរបស់ពួកគេ) ក៏ត្រូវបានបានលើកឡើងផងដែរថាជាមូលហេតុដែលគូស្វាមីភរិយាមិនបែកបាក់។

តារាង ១៣. កត្តាជំរុញរបស់អ្នកឆ្លើយសំណួរសម្រាប់ការរស់នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ

| កត្តាជំរុញរបស់អ្នកឆ្លើយសំណួរសម្រាប់ការរស់នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ | | | |
|---|---|---|---|
| ទំនាក់ទំនងជិតស្និទ្ធ/សេចក្ដីស្រឡាញ់ | មានកូនជាមួយដៃគូចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ | សម្ពាធពីឪពុកម្ដាយ/ក្រុមគ្រួសារ | ប្រពៃណី/វប្បធម៌ |

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

| | | | |
|---|---|---|---|
| ៥៥,៨% | ៣៦,៥% | ៣,៨% | ៣,៨% |

នៅក្នុងសំណួរបើកចំហនៃការស្ទង់មតិនេះ អ្នកឆ្លើយសំណួរដែលបន្តរស់នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងថ្លែងថាមានទំនាក់ទំនងជាវិជ្ជមានបានរៀបរាប់ពីស្ថានភាពនៃការគាំទ្រ និងគោរពគ្នាទៅវិញទៅមក ("ដៃគូខ្ញុំចេះយល់ចិត្តខ្ញុំ"។ យើងចេះអត់អោនឲ្យគ្នាដើម្បីឲ្យគ្រួសារបានសុខ")។ អ្នកខ្លះទៀតរៀបរាប់ពីទំនាក់ទំនងដែលទាក់ទងដោយផ្ទាល់ទៅការចែករំលែកបទពិសោធន៍នៃអំពើប្រល័យពូជសាសន៍ ("ខ្ញុំមិនសូវជាមានសេចក្តីស្រឡាញ់ណាស់ណានោះទេ ប៉ុន្តែខ្ញុំមានចិត្តអាណិតខ្លាំងសម្រាប់ដៃគូខ្ញុំ"។ "ខ្ញុំមានសេចក្តីស្រឡាញ់ខ្លាំងណាស់ចំពោះដៃគូខ្ញុំ ព្រោះនាងមានរាងកាយទន់ខ្សោយ និងបាត់បង់សាច់ញាតិអស់")។

អ្នកឆ្លើយសំណួរមួយចំនួនបានរាយការណ៍ពីទំនាក់ទំនងអវិជ្ជមាន នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់៖ ការរំលោភបំពានផ្លូវកាយ ដោយពាក្យសម្តី និងសេដ្ឋកិច្ច, ការរត់ចោលរបស់ដៃគូ (បញ្ជាក់ថាជាស្វាមី) អស់ពេលជាយូរ ដោយទុកឲ្យដៃគូដែលនៅសល់ត្រូវថែទាំ និងគាំទ្រកុមារតែម្នាក់ឯង, ការផឹកស្រា និងមិនស្មោះត្រង់ ("គាត់ជាញឹកញាប់ប្រមាថក្រុមគ្រួសាររបស់ខ្ញុំនៅពេលដែលគាត់ស្រវឹង", "ដៃគូខ្ញុំមិនបានធ្វើល្អដាក់ខ្ញុំទេ ដោយសារតែគាត់ដៃគូផ្សេងទៀត", ប្តីខ្ញុំទុកឲ្យខ្ញុំនៅជាមួយកូនតែឯង")។ ទំនាក់ទំនងអវិជ្ជមាននេះប្រហែលជាបង្ហាញយ៉ាងល្អបំផុតនៅក្នុងពាក្យរបស់អ្នកឆ្លើយសំណួរម្នាក់៖ "យើងមានអារម្មណ៍ថានៅឆ្ងាយពីគ្នា"។

ពេលដែលអ្នកឆ្លើយសំណួរត្រូវបានសុំឲ្យវាយតម្លៃទំនាក់ទំនងរបស់ខ្លួនជាមួយដៃគូ ចេញពីអាពាហ៍ដោយបង្ខំ ៦៥,៣% បានរាយការណ៍ពី "ទំនាក់ទំនងជិតស្និទ្ធ និងកក់ក្តៅ"។ អ្នកឆ្លើយសំណួរមួយភាគបី (៣៤,៨%) បានរៀបរាប់ពីទំនាក់ទំនងអវិជ្ជមាន ខណៈពេលដែល ១៨,៤% បានរាយការណ៍ថាគ្មានទំនាក់ទំនងជាមួយដៃគូ ឬមានទំនាក់ទំនងព្រងើយកន្តើយ និងចំនួនស្មើគ្នា (៨,២%) បានរាយការណ៍ពីអន្តរកម្មតែនៅពេលដែលចាំបាច់ ឬទំនាក់ទំនងជាជម្លោះ។

ក្នុងចំណោមអ្នកឆ្លើយសំណួរនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់ ច្រើនជាងពាក់កណ្តាល (៥២,៩%) បានរាយការណ៍ពីការរំលោភបំពានពីសំណាក់ដៃគូបន្ទាប់ពីរបបខ្មែរក្រហមរហូតដល់សព្វថ្ងៃនេះ ដែលភាគច្រើនបានរាយការណ៍ថាជាអំពើហិង្សាផ្លូវកាយ (៤៤,៤%), ការរំលោភបំពានដោយពាក្យសម្តី (៤៤,៤%), និងការគំរាមកំហែងដោយពាក្យសម្តី (៧,៤%)។ អ្នកឆ្លើយសំណួរម្នាក់បានរាយការណ៍ពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទជាផ្នែកមួយនៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

រូបភាព ១៥. ប្រភេទនៃការរំលោភបំពានពីសំណាក់ដៃគូនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់បន្ទាប់ពីរបបខ្មែរក្រហម

| អំពើហិង្សាផ្លូវកាយ | ការរំលោភបំពានដោយពាក្យសម្តី | ការគំរាមកំហែងជាពាក្យសម្តី | ការរំលោភសេពសន្ថវៈ/អំពើហិង្សាផ្លូវភេទ |
|---|---|---|---|
| ៤៤,៤% | ៤៤,៤% | ៧,៤% | ៣,៧% |

ក្នុងចំណោមអ្នកដែលជួបប្រទះការរំលោភបំពានពីសំណាក់ដៃគូ ស្ទើរតែពាក់កណ្តាល (៤៨,១%) បានរាយការណ៍ថាត្រូវបានគេរំលោភបំពានមួយទៅបីដងក្នុងមួយខែ ១១,១% បានរាយការណ៍ពីការរំលោភបំពានជារៀងរាល់ថ្ងៃ និង ២២,២% ហោចណាស់ម្តងក្នុងមួយឆ្នាំ។ ស្ទើរតែមួយភាគបួននៃអ្នកឆ្លើយសំណួរ (២២,២%) បានរាយការណ៍ថាការរំលោភបំពានចុងក្រោយបំផុតបានកើតឡើងនៅក្នុងខែចុងក្រោយនេះ។ អ្នកឆ្លើយសំណួរ ១៨ នាក់ (៦៦,៧%) បានរាយការណ៍ថាបទពិសោធន៍ចុងក្រោយបំផុតនៃការរំលោភបំពានគឺកើតឡើងលើសពីមួយឆ្នាំកន្លងទៅ ខណៈដែល ២២,២% បានរាយការណ៍ថាការរំលោភបំពានចុងក្រោយបំផុតបានកើតឡើងនៅក្នុងខែកន្លងមកនេះ ៧,៤% បានរាយការណ៍ពីការរំលោភបំពាននៅក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះ ហើយ ៣,៧% បានរាយការណ៍ពីការរំលោភបំពានកាលពីឆ្នាំមុន។

រូបភាព ១៦. ភាពញឹកញាប់នៃការរំលោភបំពានពីសំណាក់ដៃគូនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់បន្ទាប់ពីរបបខ្មែរក្រហម

| រាល់ថ្ងៃ | ១-៣ ដងក្នុងមួយសប្តាហ៍ | ១-៣ ដងក្នុងមួយខែ | ម្តងក្នុងមួយឆ្នាំ | តិចជាងម្តងក្នុងមួយឆ្នាំ |
|---|---|---|---|---|
| ១១,១% | ៣,៧% | ៤៨,១% | ២២,២% | ១៤,៨% |

នៅក្នុងសំណួរបើកចំហនៃការស្ទង់មតិនេះអំពីធម្មជាតិនៃការរំលោភបំពានពីសំណាក់ដៃគូ អ្នកឆ្លើយសំណួរម្នាក់បានរៀបរាប់ថា៖ "ស្ទើរតែរាល់ថ្ងៃ ប្តីខ្ញុំប្រើអំពើហិង្សាផ្លូវភេទលើខ្ញុំ"។ ទម្រង់ផ្សេងទៀតនៃការរំលោភបំពានផ្លូវកាយដែលត្រូវបានរាយការណ៍រួមមានត្រូវបានវាយដំ ចាក់ និងទះ ដោយអ្នកឆ្លើយម្នាក់បានរាយការណ៍ពីការរងរបួសក្បាល ដោយសារការរំលោភបំពានពីសំណាក់ដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមិនបែកបាក់។ ការរំលោភបំពានដោយពាក្យសម្តី និងផ្នែកអារម្មណ៍រួមមានការគំរាមកំហែងដោយកាំបិត ការ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ប្រមាថ ការស្តីបន្ទោស និងការចោទប្រកាន់ថាមានសាហាយ។ ការឆ្លើយតបមួយនៃការរំលោភបំពានផ្នែកសេដ្ឋកិច្ចថ្លែងថា៖ "ប្តីខ្ញុំមិនឲ្យលុយខ្ញុំទេ" ដែលជារឿងសំខាន់ ព្រោះថាប្រពន្ធជាធម្មតាជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុក្នុងគ្រួសារនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងការរៀបរាប់ពីធម្មជាតិនៃទំនាក់ទំនងរបស់ខ្លួនជាមួយនឹងកូនរបស់ពួកគេ នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់ ភាគច្រើនបំផុត (៩៥,២%) បានរាយការណ៍ពីទំនាក់ទំនងកក់ក្តៅ និងជិតស្និទ្ធ។ នៅក្នុងការកំណត់ពីទំនាក់ទំនងរវាងកូន និងដៃគូចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ ៧៦,៧% បានរាយការណ៍ថាមានទំនាក់ទំនងកក់ក្តៅ និងជិតស្និទ្ធ ដោយ ១៨,៦% ផ្សេងទៀតបានរាយការណ៍ពីទំនាក់ទំនងអព្យាក្រឹត និង ៤,៧% បានរាយការណ៍ពីទំនាក់ទំនងមិនល្អ។ នៅក្នុងសំណួរបើកចំហនៃការស្ទង់មតិ នេះ អ្នកឆ្លើយសំណួរបានរៀបរាប់ពីទំនាក់ទំនងរវាងកូន និងដៃគូថាជាសេចក្តីស្រឡាញ់ គោរព និងគាំទ្រ ("ពួកគេស្រឡាញ់គ្នាខ្លាំងណាស់ ហើយពេលឪពុកពួកគេឈឺ ពួកគេមើលថែគាត់"។ "ពួកគេគាំទ្រគ្នាយ៉ាងខ្លាំង"។ "ពួកគេជាញឹកញាប់មានភាពសប្បាយរីករាយជាមួយគ្នា")។ ការរៀបរាប់អវិជ្ជមានពីទំនាក់ទំនងរវាងកូន និងដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំរួមមានអារម្មណ៍ថាមិនជិតស្និទ្ធ កង្វះការទំនាក់ទំនង និង "ឆាប់ខឹងនឹងគ្នា"។ អ្នកឆ្លើយសំណួរម្នាក់បានរាយការណ៍ថា "កូនខ្ញុំស្អប់ឪពុកពួកគេ ដោយសារពួកគេជាញឹកញាប់ឃើញគាត់វាយម្តាយពួកគេ"។

ពេលដែលអ្នកឆ្លើយសំណួរត្រូវបានសួរនៅក្នុងសំណួរបើកចំហ ថាតើពួកគេពេញចិត្តជាមួយនឹងអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់នៅពេលសព្វថ្ងៃនេះទេ ការឆ្លើយតបជាវិជ្ជមានរួមមានសារៈសំខាន់នៃគូស្វាមីភរិយាក្នុងការជួយគ្នា ការថែរក្សាក្រុមគ្រួសារ និងការរកប្រាក់ចំណូលខ្ពស់ជាងមុនសម្រាប់គ្រួសារ។ ការឆ្លើយតបនៃការមិនសប្បាយចិត្ត ដែលមានកាន់តែច្រើនជាបរិមាណរួមមាន "ខ្ញុំមិនស្រឡាញ់ដៃគូខ្ញុំទេ" "ខ្ញុំមិនចង់នៅជាមួយគាត់ទេ" "យើងមិនស្គាល់គ្នា ដូច្នេះយើងមិនគាំទ្រគ្នាទេ" "ដៃគូខ្ញុំមិនយល់ចិត្តខ្ញុំទេ" "ដៃគូខ្ញុំមានអាយុច្រើនជាងខ្ញុំឆ្ងាយ"។

ការឆ្លើយតបក៏បង្ហាញពីការខកចិត្តចំពោះការមិនបានធ្វើពិធីសាសនា នៅក្នុងពិធីមង្គលការតាមប្រពៃណី៖ "ខ្ញុំខកចិត្តណាស់ចំពោះអាពាហ៍ពិពាហ៍នេះ ព្រោះខ្ញុំមិនមានពិធីរៀបអាពាហ៍ពិពាហ៍បែបប្រពៃណី" "ឪពុកម្តាយខ្ញុំមិនបានចូលរួមក្នុងថ្ងៃមង្គលការខ្ញុំទេ" "ខ្ញុំគ្មានឱកាសជ្រើសរើសដៃគូខ្លួនឯង"។ ការឆ្លើយតបទាំងនេះក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរនៅក្នុងបទសម្ភាសន៍ករណីសិក្សា ដែលអ្នកឆ្លើយសំណួរបានផ្សារភ្ជាប់ភាពជោគជ័យ និងសំណាងល្អនៃអាពាហ៍ពិពាហ៍ទៅនឹងពិធីសាសនានៃពិធីមង្គលការ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

### ង. ផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ

ផលប៉ះពាល់រយៈពេលវែងនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគេរាយការណ៍នៅគ្រប់វិសាលគមទាំងអស់ មិនថាអាពាហ៍ពិពាហ៍នោះមិនបែកបាក់ ឬបែកបាក់ក៏ដោយ មិនថាអាពាហ៍ពិពាហ៍ដែលមិនបែកបាក់នោះត្រូវគេចាត់ទុកថាពេញចិត្ត ឬខកចិត្តក៏ដោយ។

ខណៈដែលភាគច្រើននៃអ្នកឆ្លើយសំណួរ (៨៧,៦%) បានរាយការណ៍ថាគ្មានបញ្ហាផ្នែកផ្លូវកាយដែលជាលទ្ធផលនៃអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏អ្នកដែលមានបញ្ហានោះបានរាយការណ៍អំពីរបួសខាងផ្លូវបន្តពូជ និងគ្រោះថ្នាក់ផ្សេងៗទៀត ដោយសារការរំលោភបំពាន វាយដំ និងការរំលោភផ្លូវភេទពីសំណាក់ដៃគូ។ ច្រើនជាងមួយភាគបួនបន្តិចនៃអ្នកឆ្លើយសំណួរទាំងអស់ (២៧,៨%) បានរាយការណ៍ពីមុខងារផ្លូវភេទអវិជ្ជមានរួមមានបញ្ហារោគស្ត្រី ការបាត់បង់ចំណង់ផ្លូវភេទ និងកង្វះកត្តាជំរុញឲ្យមានចំណង់ផ្លូវភេទ និងការភ័យខ្លាចមិនហ៊ានរួមភេទជាមួយដៃគូទីពីរ។ អ្នកឆ្លើយសំណួរម្នាក់បាននិយាយថា “ខ្ញុំមានអារម្មណ៍មិនស្រួលទេចំពោះការមានទំនាក់ទំនងផ្លូវភេទណាមួយ នៅពេលដែលខ្ញុំនឹកឃើញអតីតកាលរបស់ខ្ញុំ”។

ច្រើនជាងពីរភាគបីនៃអ្នកឆ្លើយសំណួរទាំងអស់ (៧០,២%) បានរាយការណ៍អំពីបញ្ហាសុខភាពផ្លូវចិត្តដែលកើតមានជាហូរហែរ ដោយរៀបរាប់អំពីបញ្ហាទាំងនេះនៅក្នុងសំណួរបើកចំហថា “មិនពេញចិត្តនឹងជីវិត” និងការខកចិត្តធ្ងន់ធ្ងរពីអាពាហ៍ពិពាហ៍ដោយបង្ខំ ជាពិសេសនៅពេលដែល “ចូលរួមពិធីមង្គលការ ឬឃើញភ្លេងការបែបប្រពៃណី”។ អ្នកខ្លះបានរាយការណ៍ពីការឆាប់ខឹង អ្នកផ្សេងទៀតរាយការណ៍ពីអាការៈស្រើត ហើយនៅមានអ្នកផ្សេងទៀតដែលរាយការណ៍ថានៅជាប់នូវការប៉ះទង្គិចផ្លូវចិត្តនៅពេលដែលពួកគេនឹកដល់ពិធីមង្គលការនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ រោគសញ្ញាដែលគេលើកឡើងរួមមាន “ញ័រក្នុងខ្លួន” “ភាពក្រៀមក្រំ និងការឈឺចាប់” និងការយល់សប្តិអាក្រក់ជាញឹកញាប់ដដែលៗ ជាពិសេសអំពីការរំលោភពីសំណាក់ដៃគូក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

មួយភាគបីនៃអ្នកឆ្លើយសំណួរ (៣៥,៤%) ក៏បានថ្លែងថាបានទទួលរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលជាលទ្ធផលនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ចំពោះអ្នកឆ្លើយសំណួរមួយចំនួន ផលប៉ះពាល់ទាំងនេះត្រូវបានចាត់ទុកថាធ្ងន់ធ្ងរណាស់ ជាពិសេសនៅពេលដែលដៃគូនៃអាពាហ៍ពិពាហ៍ដោយបង្ខំនោះមិនបានរួមចំណែកផ្គត់ផ្គង់ដល់គ្រួសារ ឬនៅពេលដែលដៃគូណាម្នាក់បែកចេញពីគ្រួសារ ដូច្នេះរាល់ការចំណាយ និងទំនួលខុសត្រូវលើគ្រួសារទាំងអស់បានធ្លាក់ទៅលើដៃគូដែលបន្តនៅក្នុងគ្រួសារ។ យ៉ាងហោចណាស់មានអ្នកឆ្លើយសំណួរម្នាក់បានលើកឡើងពីការដកខ្លួនចេញពីការងារសហគមន៍ និងដែលដូច្នេះវិតត្បិតលើការរកប្រាក់ចំណូលរបស់នាង

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ដោយសារតែអារម្មណ៍អាម៉ាស់ និងការព្រួយបារម្ភថា នាងនឹងត្រូវនរណាម្នាក់នៅក្នុងអតីតកាលខ្មែរក្រហមចំណាំនាងបាន។

តាមពិតទៅ ច្រើនជាងមួយភាគបួននៃអ្នកឆ្លើយសំណួរ (២៥,៧%) បានរាយការណ៍ថាបានជួបប្រទះនឹងបញ្ហាសង្គមដែលជាលទ្ធផលនៃអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានអារម្មណ៍អាម៉ាស់ដោយសារតែពិធីមង្គលការតាមប្រពៃណីមិនត្រូវបានអនុវត្តតាម ឬត្រូវដកចេញពីពិធីមង្គលការព្រោះ "ដូនតារបស់ខ្ញុំ [មិនត្រូវបានគេ] ជូនដំណឹងអំពីអាពាហ៍ពិពាហ៍របស់ខ្ញុំទេ"។ អ្នកឆ្លើយសំណួរបានរាយការណ៍ថា គូស្វាមីភរិយាដែលគេបង្ខំឱ្យរៀបការនោះត្រូវបានសហគមន៍មាក់ងាយ និងរើសអើង ដោយមានអ្នកឆ្លើយសំណួរម្នាក់បាននិយាយថា "មានការរើសអើងចំពោះក្រុមគ្រួសាររបស់ខ្ញុំច្រើនណាស់ ព្រោះខ្ញុំត្រូវបានគេបង្ខំឱ្យរៀបការក្នុងអំឡុងរបបខ្មែរក្រហម"។

សម្រាប់ ១២% នៃអ្នកឆ្លើយសំណួរ បញ្ហាសង្គមដែលបណ្តាលមកពីអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានរាយការណ៍ថាមានផលប៉ះពាល់ទៅលើកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយកូនត្រូវបានគេបដិសេធមិនឱ្យធ្វើជាអ្នកកំដរកូនក្រមុំកូនកំលោះក្នុងពិធីមង្គលការ និងប្រឈមមុខនឹងការរើសអើងជាទូទៅបន្ថែមទៀតនៅក្នុងសហគមន៍ "ដោយសារតែពួកគេគិតថា កូនរបស់ខ្ញុំមានឪពុកម្តាយដែលមិនបានរៀបការតាមត្រឹមត្រូវ"។

**រូបភាព ១៧៖ ផលប៉ះពាល់ពីអាពាហ៍ពិពាហ៍ដោយបង្ខំលើអ្នកនៅរស់រានមានជីវិត**

| បញ្ហាផ្លូវកាយ | បញ្ហាផ្លូវចិត្ត | បញ្ហាជាមួយនឹងមុខងារផ្លូវភេទ | បញ្ហាសេដ្ឋកិច្ច | បញ្ហាសង្គម |
|---|---|---|---|---|
| ១២,៨% | ៧០,២% | ២៧,៨% | ៣៥,៤% | ២៥,៧% |

## ២. ការរកឃើញនៃករណីសិក្សា (គុណភាពវិស័យ)

បទសម្ភាសន៍ករណីសិក្សាផ្តល់សុពលភាព និងពង្រីកពីការរកឃើញនៃពិធីមង្គការដោយបង្ខំនៅក្នុងរបបខ្មែរក្រហមដូចដែលបានរៀបរាប់នៅក្នុងការពិនិត្យឡើងវិញនៃការសិក្សាពីមុនៗ និងនៅក្នុងលទ្ធផលបែបបរិមាណវិស័យនៃការសិក្សានេះ។ អាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំភាគច្រើនធ្វើឡើយដោយមិនមានជម្រើស ជាញឹកញាប់បំផុតដោយគ្មានការយល់ព្រម និងដោយការបង្ខំតាមរយៈការគំរាមកំហែង ឬការដាក់ទណ្ឌកម្មពិតប្រាកដ រួមទាំងអំពើហិង្សាផ្លូវភេទផងដែរ។ ខណៈដែលការរកឃើញ

Deleted: *Unrevised translation. A revised translation will be provided upon request.*

ដែលផ្អែកលើគំរូនៃករណីសិក្សាដ៏តូចក្នុងពេលបច្ចុប្បន្នមិនអាចតំណាងភាពទូទៅបាន ក៏ការរកឃើញទាំងនេះពិតជាបានផ្តល់នូវព័ត៌មានលម្អិតកាន់តែស៊ីជម្រៅអំពីអត្ថន័យ និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ទាំងនេះក្នុងរយៈពេលខ្លី និងវែង។

ទន្ទឹមគ្នានេះដែរ ករណីសិក្សាបានពង្រីកការរកឃើញដែលបានបង្កើតឡើងរួចហើយនៅក្នុងការស្រាវជ្រាវមុន។ ការរកឃើញទាំងនេះបង្ហាញថា អ្នកដឹកនាំតាមមូលដ្ឋានអាចនឹងត្រូវបានជំរុញទឹកចិត្តដោយមហិច្ឆិតានយោបាយនៅក្នុងការអនុវត្តគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ដែលមកមកវិញបង្ហាញថាពួកមេដឹកនាំជាន់ខ្ពស់បានដឹងពីគោលនយោបាយនេះ និងជំរុញឲ្យមានការអនុវត្តគោលនយោបាយនេះថែមទៀតផង។ បទសម្ភាសន៍បង្ហាញថា ប្តីត្រូវបានគេបង្ខំឲ្យរំលោភប្រពន្ធរបស់ខ្លួនដើម្បីបំពេញអាពាហ៍ពិពាហ៍។ ពួកវាបានផ្តល់នូវព័ត៌មានលម្អិតអំពីការរំលោភបំពានក្នុងគ្រួសារក្នុងកម្រិតខ្ពស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំ ការកើនឡើងនៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលមានការរំលោភបំពានបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម និងរបៀបដែលអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានគេឆ្លងកាត់ និងចងភ្ជាប់ជាមួយនឹងផលវិបាកផ្សេងៗសម្រាប់បុរស និងស្ត្រីនៅក្នុងបរិបទសង្គមវប្បធម៌។

គំរូករណីសិក្សាបានចាប់យកសាច់រឿងធម្មតា (ឬ "មធ្យម") ព្រមទាំងករណីធ្ងន់ធ្ងរ និងជាករណី "ក្រុមដែលមានស្រាប់" ដោយផ្អែកលើអត្តសញ្ញាណជនជាតិ-សាសនា។ ការវិភាគខាងក្រោមនេះគឺផ្អែកលើបទសម្ភាសន៍ចំនួនប្រាំបីដោយមានអ្នកឆ្លើយសំណួរចំនួនប្រាំបួននាក់ ក្នុងនោះមានទាំងប្តីប្រពន្ធមួយគូផង ដែលត្រូវបានសម្ភាសជាមួយគ្នា។ ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងប្រាំបួននាក់ ពីរនាក់ជាបុរស ក្នុងនោះមានទាំងប្តីរបស់គូស្វាមីភរិយាមួយគូ, ប្រាំបីនាក់ត្រូវបានកំណត់អត្តសញ្ញាណជាជនជាតិខ្មែរ ខណៈដែលមានម្នាក់ជាមូស្លីមចាម។ អ្នកទាំងអស់ត្រូវបានគេឲ្យចូលរួមនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានរៀបចំដោយរបបនោះ។ ស្ទើរតែគ្រប់គ្នាបានជំទាស់ មួយចំនួនបានព្យាយាមដើម្បីប្រឆាំង ហើយស្ត្រីម្នាក់បានបដិសេធទាំងស្រុង។ ពីរនាក់ក្នុងចំណោមស្ត្រីទាំងអស់បានរៀបការមុនពេលរបបនោះ។ ក្រោយពីប្តីពួកគេត្រូវសម្លាប់ ពួកគេត្រូវបានបញ្ជាឲ្យរៀបការជាថ្មីម្តងទៀត។ បទសម្ភាសន៍ពីរគ្របដណ្តប់នូវអាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់ មួយគឺសប្បាយរីករាយ ហើយមួយផ្សេងទៀតគឺពោរពេញដោយការរំលោភបំពានធ្ងន់ធ្ងរ។ លើសពីនេះទៀត អ្នកឆ្លើយសំណួរពីរនាក់គឺកូនក្រមុំជាកុមារ (អ្នកទាំងពីរមានអាយុជាង ១៥ ឆ្នាំ) ដោយម្នាក់បានរៀបការមុនពេលរបបខ្មែរក្រហម និងម្នាក់ទៀតបានរៀបការនៅក្នុងអំឡុងរបបនោះ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Deleted: *Unrevised translation. A revised translation will be provided upon request.*

[01037064-01037080]

## ខ. អាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងរបស់សហព័ទ្ធដែលត្រូវបានបង្ខំក្រោមរបបខ្មែរក្រហម

រាល់អ្នកផ្តល់បទសម្ភាសន៍ករណីសិក្សាទាំងអស់ត្រូវបានសុំឱ្យរៀបការដោយពួកខ្មែរក្រហម ហើយទីបំផុតពួកគេបានយល់ព្រម ដោយមានករណីលើកលែងនៃស្ត្រីពីរនាក់ដែលត្រូវបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរសម្រាប់ការបដិសេធរបស់ពួកគេ គឺពួកគេទាំងពីរត្រូវបានគេចាប់រំលោភ ហើយម្នាក់ជាទាសករផ្លូវភេទ។ ជាទូទៅ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានគេចាត់ទុកជាសរុបថាជាជម្រើសដែលគ្មានអត្ថន័យ ឬការយល់ព្រម និងដោយបង្ខំតាមរយៈការគំរាមកំហែងដាក់ទណ្ឌកម្ម ឬការដាក់ទណ្ឌកម្មពិតប្រាកដ។

### ពិធីប្តេជ្ញាចិត្ត និងការចាត់តាំងអាពាហ៍ពិពាហ៍

ពិធីអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានរៀបចំឡើងដោយពួកខ្មែរក្រហម ត្រូវបានគេរៀបរាប់ថាផ្ទុយគ្នាស្រឡះទៅនឹងពិធីអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណី និងគួរតែហៅថាជានីតិវិធីមង្គលការ។ ក.ន ជាជនជាតិមូស្លីមម្នាក់ រៀបរាប់នៅក្នុងបទសម្ភាសន៍របស់នាងថា ពិធីទាំងនោះត្រូវបានគេហៅថា "ពិធីប្តេជ្ញាចិត្ត" ជាជាងពិធីមង្គលការ[65]។ នីតិវិធីមង្គលការដោយបង្ខំរបស់ពួកខ្មែរក្រហមត្រូវបានរៀបរាប់ដោយគំរូថាជាព្រឹត្តិការណ៍ធំមួយដែលមានគូស្វាមីភរិយារហូតដល់ទៅរាប់រយគូ។ នីតិវិធីមង្គលការទាំងអស់ត្រូវបានរៀបចំ និងមានការចូលរួមជាអធិបតីភាពដោយភ្នាក់ងារសំខាន់ៗរបស់ពួកខ្មែរក្រហមនៅគ្រប់ជាន់ថ្នាក់ រួមទាំងថ្នាក់ដឹកនាំផងដែរ[66]។ គូស្វាមីភរិយាបានដោះដូរសម្បថខ្លីមួយថាមានភក្តីភាពចំពោះគ្នា និងចំពោះ*អង្គការ*។ នៅក្នុងនីតិវិធីមួយក្នុងចំណោមនីតិវិធីមង្គលការទាំងឡាយដែលបានរៀបរាប់ដោយអ្នកផ្តល់បទសម្ភាសន៍ គូស្វាមីភរិយាបាននិយាយពាក្យសម្បថម្តងហើយម្តងទៀតយ៉ាងច្បាស់ៗ ដោយលើកឡើងពីកាតព្វកិច្ចក្នុងការមានកូន

[65] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រី ជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។

[66] បទសម្ភាសន៍ជាមួយករណីសិក្សាទី ២, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤) ប្រាប់ថាត្រូវបានគេបញ្ជាឱ្យរៀបការដោយ "ប្រធាន" ដែលទទួលខុសត្រូវត្រួតពិនិត្យមើលមនុស្សរាប់រយនាក់។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

និងបន្តពូជ[67]។ នីតិវិធីមង្គលការដោយបង្ខំភាគច្រើននៅក្នុងចំណោមគំរូបានកើតឡើងនៅពេលយប់ បន្ទាប់ពីថ្ងៃធ្វើការ និងមានរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ[68]។

ភាគច្រើននៃអ្នកឆ្លើយសំណួរមិនបានទទួលការជូនដំណឹងជាមុនអំពីនិតិវិធីមង្គលការនោះទេ ឬគ្រាន់តែត្រូវបានប្រាប់ (ដោយកម្មាភិបាល ឬភ្នាក់ងារខ្មែរក្រហមផ្សេងទៀត) តែប៉ុន្មានម៉ោងប៉ុណ្ណោះមុនពិធីនេះ។ នៅក្នុងឧទាហរណ៍ផ្ទុយគ្នាមួយ ប្ដីប្រពន្ធដែលបានផ្ដល់បទសម្ភាសន៍ត្រូវបានគេជូនដំណឹងមួយពីរបីថ្ងៃមុន និងជាសាធារណៈនៅឯកិច្ចប្រជុំរៀងរាល់យប់នៅកន្លែងធ្វើការដាច់ដោយឡែករបស់ខ្លួន ដែលបង្ហាញថា អាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំមួយចំនួនអាចនឹងត្រូវរៀបចំឡើង ដោយការផ្សំផ្គុំជាមួយជំរំការងារក្បែរខាងជាទ្រង់ទ្រាយធំ។ អ្នកផ្ដល់បទសម្ភាសន៍ភាគច្រើនបានឡើងពីវាលស្រែដោយផ្ទាល់តែម្ដងមកកន្លែងធ្វើនីតិវិធីមង្គលការរបស់ពួកគេ ក្នុងសំលៀកបំពាក់ធ្វើការរហែកៗនៃឯកសណ្ឋានធម្មតារបស់ពួកខ្មែរក្រហម ពោលគឺអាវ និងខោ/សំពត់ពណ៌ខ្មៅ និងប្រហែលជាមានក្រមាមួយផង [កន្សែងបង់កប្រពៃណី]។ អ្នកផ្សេងទៀតត្រូវបានគេកុហក និងប្រាប់ថា ពួកគេនឹងទៅកន្លែងណាផ្សេងមុនពេលដែលត្រូវគេនាំទៅដល់កន្លែងពិធីនោះ។ ព.ស. បានរៀបរាប់អំពីរបៀបដែលនាងបានដឹងថា នាងនឹងចូលរួមពិធីមង្គលការរបស់នាងក្នុងអំឡុងពេលមួយដែលប្រជាជនទាំងអស់កំពុងតែធ្វើការហួសកម្លាំង និងស្រេកឃ្លានយ៉ាងខ្លាំងថា៖

> *"ខ្ញុំមិនបានដឹងថាខ្ញុំត្រូវបានគេបង្ខំឲ្យរៀបការនោះទេ។ ខ្ញុំកំពុងតែរែកអាចម៍គោមកចាក់នៅក្នុងវាលស្រែនៅថ្ងៃនោះនៅកន្លែងការងារ។ ពួកគេមិនបានប្រាប់ខ្ញុំទេ ខ្ញុំគ្រាន់តែឃើញមនុស្សម្នាដើរជាគូៗចូលទៅក្នុងរោង ហើយខ្ញុំក៏បានសួរកម្មាភិបាលថា "មិត្តបង [សមមិត្តច្បង] ហេតុអ្វីបានជាមានមនុស្សច្រើនម្ល៉េះចូលក្នុងកន្លែងនោះ?" នាងបានឆ្លើយថា "ឯងក៏ត្រូវតែទៅជាមួយគេដែរ។ ខ្ញុំបានសួរថាហេតុអ្វី ហើយនាងបានឆ្លើយថា "ទៅកន្លែងនោះ ឯងនឹងអាចហូបបានឆ្អែត""[69]។*

---

[67] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤); បទសម្ភាសន៍ជាមួយករណីសិក្សាទី ៣, ប្ដីប្រពន្ធ (ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤)។

[68] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)៖ "កម្មាភិបាល Y និង X បានពិភាក្សាជាមួយគ្នាថា "យើងមិនចាំបាច់ឲ្យឈប់សម្រាកពេញមួយថ្ងៃដើម្បីរៀបការនោះទេ។ ឲ្យពួកគេធ្វើការតាមធម្មតាទៅបានហើយ ហើយយើងនឹងរៀបចំពិធីមង្គលការតែម្ដងបន្ទាប់ពីធ្វើការរួច"។

[69] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

អ្នកផ្តល់បទសម្ភាសន៍ករណីសិក្សាមួយចំនួនបានរៀបរាប់ពីភាពខុសគ្នារវាងពិធី ដែលបានធ្វើឡើងសម្រាប់ប្រជាជន "ចាស់" ឬប្រជាជន "ថ្មី"។ ហ.ក. បានរៀបរាប់ពីភាពខុសគ្នានៅក្នុងជំរំការងាររបស់នាងនៅខេត្តបាត់ដំបងរវាងនីតិវិធីមង្គលការរបស់ប្រជាជន "មូលដ្ឋាន" និងប្រជាជន "ថ្មី" ដោយសម្រាប់ប្រជាជនថ្មី អាពាហ៍ពិពាហ៍ត្រូវរៀបចំឡើងនៅថ្ងៃធ្វើការងារ ត្រូវបានអនុញ្ញាតឱ្យធ្វើពិធីសាសនាតាមបែបប្រពៃណីមួយចំនួន ("ខ្ញុំឱ្យប្តីរបស់ខ្ញុំហូបបាយមុន" និងមានទាជាអាហារបន្ទាប់ពីពិធីនោះរួចដើម្បីរក្សាឱ្យគូស្វាមីភរិយាដំបូងៗនៅក្នុងភូមិនេះសប្បាយចិត្ត")។ នៅពេលសួរថា ហេតុអ្វីបានជាពួកខ្មែរក្រហមនៅភូមិរបស់នាងបង្ខំប្រជាជនឱ្យរៀបការ នាងបានឆ្លើយថា៖ "តាមការពិត ពួកគេចង់ទាក់ទាញការចាប់អារម្មណ៍ពីអ្នកមេដឹកនាំរបស់ពួកគេដើម្បីឱ្យពួកគេបានឡើងឋានៈ។ ប្រហែលជាពួកគេអាចនឹងទទួលបានការដំឡើងឋានៈដោយបង្ហាញពីចំនួននៃគូស្វាមីភរិយាដែលបានរៀបការនៅក្នុងភូមិរបស់ពួកគេ"[70]។ នេះបង្ហាញថា ពួកមេដឹកនាំថ្នាក់លើបានដឹង និងផ្តល់រង្វាន់ដល់ការអនុវត្តគោលនយោបាយនេះ។

នៅគ្រប់ទិដ្ឋភាពនៃជីវិត *អង្គការ*បានចាប់យកតួនាទីជាឪពុកម្តាយ ដោយតម្រូវឱ្យមានភាពស្មោះត្រង់ និងការស្តាប់បង្គាប់តាមទាំងស្រុង[71]។ តួនាទីនេះបានពង្រីកទៅដល់អាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រង់នេះឪពុកម្តាយមិនត្រឹមតែត្រូវបានគេដកចេញប៉ុណ្ណោះទេ ប៉ុន្តែតួនាទីរបស់ខ្លួនក៏ត្រូវបានគេដណ្តើម និងបង្ខូចដោយរដ្ឋថែមទៀតផង។ គូស្វាមីភរិយាមិនតម្រូវឱ្យត្រៀមអ្វីច្រើនដើម្បីរៀបការនោះទេ ព្រោះពួកគេត្រូវបានចាត់តាំងឱ្យទទួលយកនីតិវិធីប្តេជ្ញាចិត្តនានាដែលសម្របសម្រួលដោយរដ្ឋ។ គូស្វាមីភរិយាភាគច្រើនដែលរៀបចំឡើងដោយ*អង្គការ* ត្រូវបានគេចាត់ទុកនៅក្នុងគំរូថាជាការផ្សំផ្គុំតាមអំពើចិត្តរវាងប្រជាជន "ថ្មី" ទៅនឹងប្រជាជន "ថ្មី" និងរវាងប្រជាជន "ចាស់" ទៅនឹងប្រជាជន "ចាស់"។ គូស្វាមីភរិយាត្រូវបានគេកត់សម្គាល់ថាខុសគ្នានៅក្នុងលក្ខខណ្ឌនៃភាពត្រូវគ្នា (ដែលជាញឹកញាប់ទាក់ទងនឹងការអប់រំ សាវតាសង្គម ឬរូបសម្រស់ខាងក្រៅ)។ ក.

---

[70] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៦, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

[71] បទសម្ភាសន៍ជាមួយករណីសិក្សាទី ១, ប្រុស (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤)៖ "ពួកយើងគឺជាកូនចៅរបស់អង្គការហើយឥឡូវ។ មិនបាច់ត្រូវការឪពុកម្តាយទៀតនោះទេ"។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ន. បានរៀបរាប់ពីរបៀបដែល "ជនជាតិអ៊ីស្លាមត្រូវបានលាយជាមួយនឹងជនជាតិខ្មែរ" នៅក្នុងគូស្វាមីភរិយាដែលគេចាត់តាំង[72]។

ការផ្លាស់ប្តូរទាំងស្រុងនៃពិធីអាពាហ៍ពិពាហ៍ ជាពិសេសបំផុតនៅក្នុងការដកចេញនូវតួនាទីរបស់ឪពុកម្តាយ និងពិធីសាសនានានា ត្រូវបានលើកឡើងនៅគ្រប់បទសម្ភាសន៍ទាំងអស់ថាជាការបាត់បង់ដ៏ធ្ងន់ធ្ងរ និងដ៏ឈឺចាប់។ ខណៈដែលការបដិសេធនឹងត្រូវពិភាក្សាកាន់តែពេញលេញបន្ថែមទៀតខាងក្រោម ច.ផ. បានរៀបរាប់ពីក្តីអាម៉ាស់ចំពោះសេចក្តីថ្លៃថ្នូរ ដែលនាងបានទទួលយកការរៀបចំធ្វើពិធីអាពាហ៍អាពាហ៍ពិពាហ៍ដោយបង្ខំរបស់របបនោះថា៖ "ខ្ញុំបានបដិសេធមិនព្រមទទួល ព្រោះពិធីនោះគ្មានឪពុកម្តាយ គ្មានភ្លេងគ្មានសាច់ញាតិ គ្មានអាចារ្យ គ្មានសំលៀកបំពាក់ ឬការតុបតែង ហើយប្តីរបស់ខ្ញុំគឺជាមនុស្សដែលខ្ញុំមិនដែលស្គាល់។ ខ្ញុំបានត្រឹមតែស្គាល់ឈ្មោះរបស់គាត់ ហើយបន្ទាប់មកគេសុំឱ្យខ្ញុំរៀបការជាមួយគាត់"[73]។

បុរសត្រូវបានលើកឡើងនៅក្នុងបទសម្ភាសន៍ករណីសិក្សាជាច្រើនថាអាចស្នើសុំដៃគូ ដែលខ្លួនចង់បានដោយធ្វើតាមទំនៀមទម្លាប់ប្រពៃណី។ ប៉ុន្តែ *អង្គការ*ជាអ្នកក្តោបក្តាប់អំណាចចុងក្រោយក្នុងការរៀបចំដៃគូ និងសម្រេចឱ្យមានអាពាហ៍ពិពាហ៍ឡើង។ ហ.អ. បានប៉ាន់ស្មានថា ប្រហែលជាពាក់កណ្តាលនៃគូស្វាមីភរិយានៅក្នុងកងរបស់នាងត្រូវបានគេរៀបចំឱ្យទាំងស្រុងដោយ*អង្គការ* ដែលសល់ពីនេះគឺពាក់ព័ន្ធនឹងការស្នើសុំពីខាងបុរសសម្រាប់ភរិយាជាក់លាក់ណាម្នាក់។ ហ.អ. បានបានរៀបរាប់ថា ស្ត្រីមិនត្រូវបានគេអនុញ្ញាតឱ្យធ្វើការស្នើសុំបែបនេះឡើយ។ នាងបានរៀបរាប់ថា៖

*"បុរសនៅពេលនោះបានធ្វើការស្នើសុំទៅកម្មាភិបាល។ មានកម្មាភិបាលម្នាក់សម្រាប់ក្រុមស្ត្រី និងម្នាក់សម្រាប់ក្រុមបុរស ដែលគ្រប់គ្រងមនុស្សចន្លោះពី ៥០ ទៅ ១០០ នាក់។ នៅពេលដែលមានបុរសម្នាក់ធ្វើសំណើសុំ មេដឹកនាំនៃក្រុមយុវជននោះធ្វើបញ្ជីឈ្មោះរបស់បុរស និងស្ត្រីនោះ ហើយបន្ទាប់មកពួកគេបញ្ជូនសំណើនោះទៅមេដឹកនាំក្រុមយុវនារី ហើយបន្ទាប់មកនៅក្នុងកិច្ចប្រជុំ នាងនឹងប្រកាសថា "អ្ន*

---

[72] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រីជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។ នៅក្នុងឧទាហរណ៍នេះ ប្តីអ្នកកាន់ពុទ្ធសាសនាខ្មែរដែលគេចាត់តាំងឱ្យនាងនៅទីបំផុតបានប្តូរទៅជាសាសនាអ៊ីស្លាម និងត្រូវបានស្រូបចូលក្នុងសហគមន៍របស់នាង ប៉ុន្តែអ្នកផ្តល់បទសម្ភាសន៍បានរៀបរាប់ពីរបៀបដែលស្ត្រីជនជាតិអ៊ីស្លាមមួយចំនួនត្រូវបានគេបង្ខំឱ្យជ្រើសរើសរវាងប្តីអ្នកកាន់ពុទ្ធសាសនាខ្មែរ និងសហគមន៍សាសនារបស់ពួកគេ (រួមទាំងគ្រួសារនៃប្រភពដើម) នៅក្នុងអាពាហ៍ពិពាហ៍ចម្រុះទាំងនោះ។

[73] បទសម្ភាសន៍ជាមួយករណីសិក្សាទី ២, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*! មិត្ត ក [សមមិត្ត ក] មានបុរសម្នាក់បានស្នើសុំរៀបការជាមួយមិត្ត ... ឥឡូវនេះអង្គការនឹងរៀបការមិត្តឱ្យទៅបុរសម្នាក់នេះហើយ"។ បុរសមិនអាចចេះតែស្នើសុំស្ត្រីណា ម្នាក់ឡើយ។ អង្គការត្រូវតែអនុញ្ញាតដល់ការស្នើសុំនោះ ហើយពួកគេបានមើលទៅលើប្រវត្តិ និងសាវតារបស់គ្រួសាររបស់យើងដើម្បីធ្វើឱ្យប្រាកដថា វាមានលក្ខណៈស្រដៀងគ្នាមុននឹងពួកគេយល់ព្រម។ ប្រសិនបើយើងមានសាច់ញាត្តិដែលអង្គការបានសម្លាប់ នោះយើងគឺជាខ្មាំង [សត្រូវ] ហើយ។ ឧទាហរណ៍ នៅក្នុងករណីរបស់ខ្ញុំ អង្គការបានសម្លាប់ឪពុករបស់ខ្ញុំ ដូច្នេះខ្ញុំមានសាវតាអាក្រក់ដោយសារតែខ្ញុំមានការពាក់ព័ន្ធជាមួយខ្មាំង។ បុរសម្នាក់ដែលបានស្នើសុំខ្ញុំឱ្យរៀបការជាមួយនោះក៏ជាប់ពាក់ព័ន្ធនឹងខ្មាំងដែរ ដូច្នេះពួកគេក៏យល់ព្រមនឹងសំណើនេះទៅ។ បែបនេះគេហៅថា "ប្រវត្តិត្រូវគ្នា"។*

ប៉ុន្តែ ទោះបីជាមួយនឹងអ្វីដែលហាក់ដូចជាមានឱកាសសម្រាប់ឱ្យជ្រើសរើសក៏ដោយ ក៏សំណើរបស់បុរសត្រូវបានគេបកស្រាយជាញឹកញាប់ថាជាការសម្រេចចិត្តជាយុទ្ធសាស្ត្រ នៅក្នុងបរិបទមួយដែលបុគ្គលម្នាក់ៗចុងក្រោយត្រូវបង្ខំចិត្តឱ្យគេចាត់តាំងដៃគូឱ្យដដែល។ ជាសំខាន់ បទសម្ភាសន៍ករណីសិក្សាក៏បានបង្ហាញពីភាពខ្លាំងនៃចំណងគ្រួសារ និងសាច់ញាតិដែរ សូម្បីតែស្ថិតនៅក្រោមកាលៈទេសៈបន្ទាន់បែបនេះក្តី។ ខណៈដែលគូស្វាមីភរិយាជាញឹកញាប់បំផុតជាជនប្លែកមុខ ហើយមិនបានស្គាល់គ្នាទៅវិញទៅមកដោយផ្ទាល់ផងនោះ បណ្តាញក្រៅផ្លូវការនានាត្រូវបានគេប្រើដើម្បីស្វែងយល់បន្ថែមអំពីដៃគូដែលគេចាត់តាំងឱ្យ ដោយរក្សាធាតុនៃមនុស្សធម៌មួយចំនួននៅក្នុងប្រព័ន្ធមួយដែលផ្ទុយទៅវិញអមនុស្សធម៌ ដូចដែលគេបានរៀបរាប់នៅក្នុងបទសម្ភាសន៍។ គូស្វាមីភរិយាមួយគូអាចនឹងធ្លាប់បានធ្វើការក្បែរគ្នានៅកន្លែងការងារ ឬពួកគេអាចនឹងធ្លាប់ស្គាល់គ្នាតាំងពីភូមិកំណើតមកម្ល៉េះ ប៉ុន្តែមិនដែលនិយាយរកគ្នា[74]។ ហ.អ. បានរៀបរាប់ថា៖

*"យុវជនប្រហែលជាបានឃើញស្ត្រីម្នាក់នោះ ឬស្គាល់ឈ្មោះរបស់នាងដោយសារពួកគេធ្វើការជាមួយគ្នា ឬពួកគេមានសាច់ញាតិ ឬបងប្អូនដែលធ្វើការជិតស្និទ្ធជាមួយស្ត្រីនោះ ហើយបងប្អូនរបស់គាត់អាចនឹងនិយាយថា "អូ ឯងគួរតែស្នើសុំស្ត្រីម្នាក់នេះទៅ នាងល្អអញ្ចេះ ល្អអញ្ចោះ" ... បុរសម្នាក់អាចស្គាល់ស្ត្រីម្នាក់តាមរយៈបណ្តាញនេះ។ ក្នុងករណីរបស់ខ្ញុំ បងប្អូនជីដូនមួយរបស់ប្តីខ្ញុំធ្វើការជាមួយខ្ញុំ ហើយ*

---

[74] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៣, ប្តីប្រពន្ធ, ប្រពន្ធ (ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*នាងប្រាប់ប្ដីរបស់ខ្ញុំថា "បងគួរតែស្នើសុំរៀបការជាមួយនាងទៅ នាងទន់ភ្លន់ និងជាអ្នកធ្វើការបានល្អណាស់។ ដូច្នេះ គាត់ក៏ស្នើសុំរៀបការជាមួយខ្ញុំទៅ"*[75] ។

ហ.ក. បានរៀបរាប់ពីការស្នើសុំរៀបការជាច្រើនពីសាច់ញាតិជាស្ត្រីរបស់ប្ដីដែលត្រូវបានគេបង្ខំឱ្យរៀបការចុងក្រោយរបស់នាង។ រឿងរបស់នាងបានបង្ហាញពីរបៀបដែលបណ្ដាញសាច់ញាតិអាចនឹងត្រូវបានប្រើប្រាស់ដើម្បីដាក់ទម្ងន់បន្ថែមទៅលើប្រព័ន្ធបង្ខំយ៉ាងគាបសង្កត់ ព្រមទាំងបង្ហាញពីរបៀបដែលស្ត្រីដែលមិនទាន់រៀបការមានអំណាចតិចបំផុតនៅក្នុងគម្រោងអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។

*"ក បានស្នើសុំខ្ញុំឱ្យរៀបការជាមួយក្មួយប្រុសរបស់គាត់។ ខ្ញុំបានបដិសេធនឹងគាត់តែម្ដងប៉ុណ្ណោះ ហើយគាត់ក៏មិនបានបង្ខំខ្ញុំដែរ ព្រោះគាត់ក៏ជាប្រជាជនថ្មីដូចខ្ញុំដែរ។ បន្ទាប់មក ខ្ញុំបានទៅផ្ទះបាយ ធ្វើការ ហើយប្អូនស្រីរបស់ ក គឺនៅទីនោះ ហើយក៏សុំឱ្យខ្ញុំរៀបការ។ ខ្ញុំបានបដិសេធជាថ្មីម្ដងទៀត ប៉ុន្តែការបដិសេធលើកទីបីរបស់ខ្ញុំមិនបានផលទេ ព្រោះនាងនិយាយថា សំណើនេះត្រូវបានរៀបចំដោយអង្គការរួចហើយ។ នាងនិយាយជាមួយខ្ញុំថា "ប្រសិនបើឯងមិនយល់ព្រមទេ ឯងនឹងត្រូវគេសម្លាប់ហើយ។ ខ្ញុំនៅចាំថា ខ្ញុំចង់ជួបជុំក្រុមគ្រួសាររបស់ខ្ញុំវិញ និងចង់មើលឃើញថាតើប្រទេសនេះអភិវឌ្ឍយ៉ាងដូចម្ដេចខ្លះ ហើយខ្ញុំមិនចង់ស្លាប់ទេ។ ទីបំផុត ខ្ញុំបានយល់ព្រមរៀបការជាមួយប្ដីរបស់ខ្ញុំដោយសារតែខ្ញុំគិតថា អ្នកគ្រប់គ្នាងាយស្លាប់ណាស់នៅពេលនោះ ហើយខ្ញុំក៏អាចរត់ចេញឆ្ងាយពីប្ដីរបស់ខ្ញុំបានដែរបន្ទាប់ពីរបបខ្មែរក្រហមបញ្ចប់ទៅនោះ"។*

មិនមែនបុរសទាំងអស់សុទ្ធតែស្នើសុំប្រពន្ធសម្រាប់ពួកគេនោះទេ។ ស.ប.ច. បានរៀបរាប់អំពីរបៀបដែលមេក្រុមរបស់គាត់ប្រាប់ដំណឹងដល់គាត់នៅយប់មួយថា "មិត្ត រៀបចំរបស់របរទៅ ព្រោះមិត្តនឹងទៅជួយក្នុងសមូរភូមិមួយទៀត"។ បន្ទាប់ពីធ្វើដំណើរបានពីរបីគីឡូម៉ែត្រ គាត់បានមកដល់កន្លែងពិធីដែលបានចាប់ផ្ដើមរួចទៅហើយ។ ស.ប.ច. បានសួរឈ្លបថា "តើមិត្តនាំខ្ញុំមកទីនេះដើម្បីរៀបការមែនទេ?" ស.ប.ច. បានជំទាស់ដោយនិយាយថា គាត់មិនទាំងស្គាល់ដៃគូដែលគេរៀបចំឱ្យគាត់នោះផង ហើយឈ្លបបានឆ្លើយថា "បើទោះបីជា

[75] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។ សូមមើលបទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

មិត្តមិនស្គាល់នាងក៏ដោយ ក៏*អង្គការ*បានរៀបចំអាពាហ៍ពិពាហ៍នេះសម្រាប់មិត្តរួចទៅហើយ ហើយមិត្តត្រូវតែទទួលយក”[76]។

ការនៅរស់រានមានជីវិត ត្រូវបានគេចាត់ទុកថាជាការលើកទឹកចិត្តដ៏ធំធេងបំផុតសម្រាប់ការទទួលយកអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះ។ ការដាក់ទណ្ឌកម្ម ឬការគំរាមកំហែងថានឹងដាក់ទណ្ឌកម្មគឺជាការពិតដែលមានពិតប្រាកដក្នុងពេលនោះ។ ហ.អ. បានលើកឡើងដូចនឹងបទសម្ភាសន៍ផ្សេងៗទៀតដែរ (ដែលមួយចំនួនត្រូវបានដកស្រង់សម្ដីនៅខាងលើ) ថា៖ “បើទោះជាខ្ញុំមិនយល់ព្រមនៅពេលនោះ ក៏ខ្ញុំគ្មានជម្រើសដែរ ព្រោះខ្ញុំប្រហែលជានឹងមានគ្រោះថ្នាក់ប្រសិនបើខ្ញុំបដិសេធ ដូច្នេះខ្ញុំមានតែស៊ូទ្រាំប៉ុណ្ណោះ [ប៉ុន្តែ] គាត់មិនមែនជាប្ដីដែលខ្ញុំធ្លាប់សង្ឃឹមចង់បាននោះទេ”[77]។ ការលើកទឹកចិត្តផ្សេងៗទៀតសម្រាប់ការទទួលយកសំណើសុំរៀបការដោយបង្ខំរួមមាន ការអាចសុំនៅ ឬផ្លាស់ទីតាំងទៅកាន់ភូមិដែលស្ថិតនៅជិតគ្រួសារជាងបាន[78]។

អ្វីដែលគួរឱ្យចាប់អារម្មណ៍ អ្នកផ្ដល់បទសម្ភាសន៍ប្រាំមួយនាក់ក្នុងចំណោមប្រាំបីនាក់ត្រូវបានបង្ខំឱ្យរៀបការនៅផ្នែកក្រោយនៃរបបខ្មែរក្រហម អ្នកខ្លះគឺនៅតែប៉ុន្មានខែមុនពេលដួលរលំនៃរបបនេះប៉ុណ្ណោះ ដែលចង្អុលបង្ហាញអំពីការកើនឡើងដល់ចំណុចកំពូលដែលអាចទៅរួចក្នុងការធ្វើពិធីការប្ដេជ្ញាចិត្ត ដែលត្រូវបានរៀបចំឡើងនៅចុងឆ្នាំ ១៩៧៨[79]។

**ទំនាក់ទំនងរបស់សហព័ទ្ធដែលត្រូវបានបង្ខំ និងការរំលោភសេពសន្ថវៈ**

ការរួមភេទដោយបង្ខំគឺជាផ្នែកមួយនៃគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ។ បន្ទាប់ពីពិធីប្ដេជ្ញាចិត្តរបស់ពួកខ្មែរក្រហមរវាងប្ដីប្រពន្ធដែលគេចាត់តាំងឱ្យ អ្នកផ្ដល់បទសម្ភាសន៍បានពន្យល់ថា គូស្វាមីភរិយានៅតែនៅជាមួយគ្នាក្នុងរយៈពេលពីរបីថ្ងៃ ហើយត្រូវបានគេរំពឹងថានឹងបំពេញអាពាហ៍ពិពាហ៍ ដែលជាញឹកញាប់បំផុតគឺស្ថិតនៅក្រោមការតាមដានពីសំណាក់កម្មាភិបាល ឬភ្នាក់ងារខ្មែរក្រហមដទៃទៀត។ អ្នកផ្ដល់បទសម្ភាសន៍ជាច្រើនបានលើកឡើងអំពីខ្ទម ឬបន្ទប់តូចៗ ដែលជាញឹកញាប់មានលក្ខណៈឯកជនតិចតួច ដែលត្រូវ

---

[76] បទសម្ភាសន៍ជាមួយករណីសិក្សាទី ១, ប្រុស (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤)។

[77] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

[78] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៣, ប្ដីប្រពន្ធ (ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤)។

[79] ត្រូវបានលើកឡើងនៅក្នុងករណីសិក្សាទី ១, ២, ៣, ៤, ៥ និង ៨។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

បានសាងសង់ដោយពួកខ្មែរក្រហម សម្រាប់ប្រើក្នុងគោលបំណងឱ្យបំពេញអាពាហ៍ពិពាហ៍ដោយបង្ខំ។ ហ.អ. បានរៀបរាប់ថា៖

> *"បន្ទប់ទាំងនោះគឺនៅជាប់ៗគ្នាពីមួយទៅមួយ តូចប៉ុនកន្ទេល ហើយគេប្រើស្លឹកត្នោតមកធ្វើជាជញ្ជាំង ហើយរោងនោះវែងខ្លាំងណាស់ ដែលមានកម្រាលធ្វើពីឬស្សី។ យើងអាចមើលឃើញពីបន្ទប់មួយទៅមួយតាមជញ្ជាំង ហើយបន្ទប់ទាំងនោះមិនបានបិទបាំងជិតនោះទេ។ បន្ទាប់ពីពិធីអាពាហ៍ពិពាហ៍ហើយ គេបាននាំយើងទៅបន្ទប់នោះ ហើយយាមពួកយើង អង្កេតមើលពួកយើងដើម្បីឱ្យប្រាកដថា យើងចុះសម្រុងនឹងគ្នា"*[80]។

ភាគច្រើននៃអ្នកផ្តល់បទសម្ភាសន៍ជាស្ត្រីបានរៀបរាប់អំពីអារម្មណ៍អាម៉ាស់ ដែលពួកគេមាននៅក្នុងបន្ទប់ទាំងនោះ គួបផ្សំនឹងភាពភ័យខ្លាចដែលនឹងត្រូវរួមភេទជាលើកដំបូងនៅក្នុងបរិបទនៃ "អាពាហ៍ពិពាហ៍" មួយដែលល្អបំផុតគឺដែលគួរឱ្យសង្ស័យ។ ពួកគេភាគច្រើនមានការយល់ដឹងតិចតួចអំពីការរួមភេទ ដោយការរក្សាព្រហ្មចារី និងភាពបរិសុទ្ធនៃស្ត្រី ដែលត្រូវបានរំពឹងនៅក្រោមក្រមវប្បធម៌នៃ*ច្បាប់ស្រី*។ ហ.អ. បានចែករំលែកថា៖ "នៅពេលនោះ ពួកយើង [ស្ត្រី] មិនបានដឹងថាតើនឹងមានអ្វីកើតឡើងនៅយប់ថ្ងៃរៀបការទេ។ យុវជននៅពេលនោះមិនដឹងអ្វីទាំងអស់អំពីអាពាហ៍ពិពាហ៍"[81]។ អ្នកឆ្លើយសំណួរជាស្ត្រីនៅក្នុងករណីសិក្សាជាច្រើនបានរៀបរាប់ថា ខ្លួនត្រូវបានគេបំបាក់មុខនៅពេលជួបនឹងប្តីរបស់ពួកគេជាលើកដំបូង ដែលជាធម្មតាគឺជាជនប្លែកមុខទាំងស្រុង ដែលធ្វើឱ្យខ្លួនយល់ថាមិនសមនឹងសម្លឹងមើលមុខគាត់ ឬកាន់ដៃគ្នានៅពេលដែលគេតម្រូវឱ្យធ្វើនៅក្នុងនិតីវិធីមង្គលការនោះ។ ហ.ក. បានគូសបញ្ជាក់ថា "យប់នោះ ប្តីរបស់ខ្ញុំបានស្ទាបដៃរបស់ខ្ញុំ ហើយខ្ញុំមិនបានដឹងថាគាត់ចង់ធ្វើអ្វីឡើយ"[82]។ អ្នកឆ្លើយសំណួរដែលជាស្ត្រីជាច្រើននាក់បានរៀបរាប់ជាពិសេសថា ខ្លួនច្រឡំ និងស្រពេចស្រពិលអំពីស្ថានភាពរបស់ពួកគេថាបានរៀបការរួច។ ក.ន. បានចែករំលែកថា "ខ្ញុំមិនបានដឹងទេថាតើគាត់ជាប្តីរបស់ខ្ញុំមែន ឬមិនមែននោះ ប៉ុន្តែខ្ញុំមិនដឹងថាតើខ្ញុំអាចធ្វើអ្វីទៀតបាននោះទេ

---

[80] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

[81] ដូចឯកសារខាងលើ។

[82] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៦, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

។ គ្មានក្ដីស្រឡាញ់អ្វីបន្តិចសោះ មានតែការរួមភេទ ប៉ុន្តែខ្ញុំមិនអាចបដិសេធបាន”[83]។ នាងបានរៀបរាប់អំពីយប់ដំបូងៗរបស់នាងក្នុងនាមជាប្រពន្ធ និងថ្ងៃបន្ទាប់ៗមកថា៖

*“វាជាការចម្លែកនៅក្នុងរបបនោះ។ ខ្ញុំខ្លាចណាស់ដោយសារតែខ្ញុំមិនស្គាល់ប្ដីរបស់ខ្ញុំ ហើយខ្ញុំភ័យព្រោះខ្ញុំជាស្ត្រី ប៉ុន្តែខ្ញុំយល់ព្រមព្រោះខ្ញុំមិនចង់ត្រូវគេសម្លាប់នោះទេ។ គេផ្ដល់បន្ទប់ឱ្យយើងមួយនៅក្នុងរោងបាយ។ គេបានសង់បន្ទប់សម្រាប់យើង។ វាធ្វើពីឈើ និងកៀកជិតបន្ទប់ផ្សេងៗទៀត ប៉ុន្តែមិនកៀកជិតល្មមនឹងមើលគ្នាឃើញនោះទេ។ ប្ដីរបស់ខ្ញុំបានសួរខ្ញុំថា “អ្នកបានបេជ្ញាចិត្តចំពោះខ្ញុំ តើអ្នកស្រឡាញ់ខ្ញុំ ឬអត់?” យើងបានយល់ព្រមនឹងគ្នា ដោយសារតែយើងមិនចង់ឱ្យគេសម្លាប់។ ប្ដីរបស់ខ្ញុំបាននិយាយថា “ប្រសិនបើយើងមិនយល់ព្រមទេ យើងនឹងត្រូវគេសម្លាប់ ព្រោះឈ្លបកំពុងតែតាមដានយើងឥឡូវនេះ”។ ខ្ញុំខ្លាចការរួមភេទណាស់ ព្រោះខ្ញុំមិនដឹងថាតើគេធ្វើដូចម្ដេចផង។ យើងបានស្នាក់នៅជាមួយគ្នាអស់រយៈពេលមួយសប្ដាហ៍ ហើយបន្ទាប់មកគេបំបែកយើងឱ្យទៅធ្វើការនៅកន្លែងផ្សេងគ្នា ហើយដូច្នេះ យើងអាចជួបគ្នាបានតែម្ដងប៉ុណ្ណោះក្នុងមួយខែ’[84]។*

ដូចដែលសម្រង់សម្ដីនេះបានបង្ហាញ គូស្វាមីភរិយាបានយល់ព្រមរួមភេទជាមួយគ្នាទៅវិញទៅមកដើម្បីអាចនៅរស់រានមានជីវិត។ ហ.អ. បានពន្យល់ថា៖ “តើឱ្យយើងចែកផ្លូវគ្នាយ៉ាងដូចម្ដេច? យើងយល់ព្រមនឹងគ្នាថារស់នៅជាប្ដីប្រពន្ធ ព្រោះយើងមិនអាចធ្វើអ្វីផ្សេងទៀតបានឡើយ។ ស្រឡាញ់ ឬមិនស្រឡាញ់ យើងត្រូវនៅជាមួយគ្នាដើម្បីកុំឱ្យគេសម្លាប់”[85]។ ការមានផ្ទៃពោះគឺជាការភ័យខ្លាចជាប់ជានិច្ចសម្រាប់ស្ត្រីនៅក្នុងបរិយាកាសនៃការរួមភេទដោយបង្ខំ ឱ្យគួបផ្សំនឹងស្ថានភាពរស់នៅដ៏យ៉ាប់យ៉ឺនបំផុតនេះ។ ក.ន. បានរៀបរាប់ថា៖

*“យើងគ្មានអ្វីហូបទេ ដូច្នេះខ្ញុំមិនចង់បានកូនឡើយ ប៉ុន្តែតើយើងអាចធ្វើអ្វីទៀតបាន? ប្រសិនបើខ្ញុំចង់រំលូតកូន តើខ្ញុំអាចធ្វើបានដោយរបៀបណា? ខ្ញុំព្រួយបារម្ភថា អង្គការនឹងដឹង ហើយគ្មានគ្រូពេទ្យ គ្មាន*

---

[83] ដូចឯកសារខាងលើ។

[84] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រីជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។

[85] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*ថ្នាំពន្យាកំណើតនោះទេ។ ខ្ញុំដឹងថា យើងនឹងមានកូនបើសិនជាយើងរួមភេទ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវធ្វើអ្វីនោះទេ។ ខ្ញុំមានកូនបីនាក់ជាមួយគាត់"[86]។*

គូស្វាមីភរិយាក៏បានព្រមព្រៀងនឹងគ្នាថាមិនរួមភេទដែរ ដែលជាទម្រង់នៃឧបាយកលមួយប្រឆាំងនឹងការតាមដានរបស់ពួកខ្មែរក្រហម។ ប្ដីប្រពន្ធទាំងពីរនាក់ដែលផ្ដល់បទសម្ភាសន៍បានរៀបរាប់អំពីថ្ងៃដំបូងៗនៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេ។ ពួកគេមិនបានរួមភេទនឹងគ្នានោះទេ រហូតដល់ក្រោយការដួលរលំនៃរបបខ្មែរក្រហម ដោយស៊ូទ្រាំនឹងការគ្រប់គ្រងដ៏គាបសង្កត់របស់រដ្ឋ។ ការព្រមព្រៀងនេះគឺរវាងគ្នាទៅវិញទៅមកទេ ប៉ុន្តែជំរុញដោយប្រពន្ធ ដែលប្រឈមនឹងហានិភ័យពីរ នៅក្នុងលក្ខខណ្ឌនៃការប្រឆាំងនឹងរំពឹងទុកខាងវប្បធម៌ដែលថា កូនស្រីល្អមិនរៀបការដោយគ្មានការយល់ព្រមពីឪពុកម្ដាយរបស់នាងឡើយ ប៉ុន្តែថាភរិយាល្អត្រូវមានកាតព្វកិច្ចរួមភេទជាមួយប្ដីរបស់នាង។ បន្ថែមពីលើនេះ គូស្វាមីភរិយាទាំងអស់ត្រូវបានពួកខ្មែរក្រហមរំពឹងទុកថាបំពេញអាពាហ៍ពិពាហ៍ ទាំងបង្ខំដោយមានការដាក់ពិន័យធ្ងន់ធ្ងរ។ អាទិសង្កេតត្រូវបានប្ដូរចំពោះឈ្មោះក្រោយអាពាហ៍ពិពាហ៍ ដើម្បីជួយដល់អ្នកអានក្នុងសម្រង់សម្ដីខាងក្រោម។

ប្រពន្ធ៖ *ទីមួយ ខ្ញុំខ្លាចថាកម្មាភិបាលនឹងដឹងថាយើងមិនដេកជាមួយគ្នា។ ទីពីរ ខ្ញុំខ្លាចថាប្ដីរបស់ខ្ញុំនឹងបង្ខំខ្ញុំឱ្យរួមភេទជាមួយគាត់។*

ប្ដី៖ *ខ្ញុំមិនហ៊ានដេកក្បែរប្រពន្ធរបស់ខ្ញុំទេ។*

អ្នកសម្ភាសន៍៖ *ហេតុអ្វី?*

ប្ដី៖ *ព្រោះខ្ញុំមិនដែលស្គាល់នាង ឬសូម្បីតែនិយាយជាមួយនាងពីមុនមកផង។*

ប្រពន្ធ៖ *បន្ទាប់មក មេក្រុមម្នាក់ឈ្មោះ X បានចោទខ្ញុំថាមិនបានរួមភេទជាមួយប្ដីខ្ញុំ។ ខ្ញុំបានតបថា៖ "តើអ្នកកំពុងនិយាយអំពីអ្វីហ្នឹង?" គាត់បាននិយាយថា គាត់អាចមើលដឹងថាខ្ញុំមិនបានរួមភេទជាមួយប្ដីរបស់ខ្ញុំដោយគ្រាន់តែសម្លឹងមើលរាងកាយរបស់ខ្ញុំ។*

ប្ដី៖ *មេក្រុមក៏បានសួរខ្ញុំ ហើយគាត់បានសួរថា "តើទំនាក់ទំនងរបស់មិត្តជាមួយនឹងប្រពន្ធរបស់មិត្តយ៉ាងម៉េចដែរ?" ខ្ញុំគ្រាន់តែឆ្លើយថា៖ "ល្អ"។*

ភ្នាក់ងារខ្មែរក្រហមរំពឹងថា ប្ដីគ្រប់រូបនឹងធានាថាទំនាក់ទំនងផ្លូវភេទបានកើតឡើង ហើយប្ដីត្រូវដាក់សម្ពាធលើប្រពន្ធរបស់ខ្លួនតបមកវិញ នេះបើយោងតាមការសម្ភាសន៍ករណីសិក្សា។ ស.ប.ច. បានរំលឹកដល់

---

[86] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រីជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ភាពអៀនខ្មាសរបស់ប្រពន្ធរបស់គាត់នៅខែដំបូងៗក្រោយរៀបការ ដោយមានក្តីអាម៉ាស់ និងភ្ញាក់ផ្អើលដែលត្រូវបានស៊ើបការណ៍ដោយឈ្លបរាល់យប់ ហើយភ្ញាក់ឡើងឲ្យលឿនជាងគាត់ ធ្វើដូច្នេះអ្នកទាំងពីរនឹងមិនភ្ញាក់ដឹងខ្លួននៅលើគ្រែតែមួយ។ នៅពីរបីខែដំបូង ពួកគេមិនមានទំនាក់ទំនងផ្លូវភេទនោះទេ ប៉ុន្តែបានត្រឹមតែដេកម្ខាងម្នាក់តែប៉ុណ្ណោះ។ បន្ទាប់ពីប៉ុន្មានខែនោះមក កម្មាភិបាលម្នាក់បានព្រមានគាត់ថា "ខ្ញុំដឹងថាមិត្តមិនស្រឡាញ់ប្រពន្ធរបស់មិត្តទេ ហើយខ្ញុំមើលឃើញថា មិត្តមានកំហុសឆ្គងច្រើន។ ប្រសិនបើមិត្តមិនគោរពតាមមាគ៌ារបស់*អង្គការ*ទ ត្រូវប្រយ័ត្នប្រយែងខ្លួនផង"។ នៅពេលដែល ស.ប.ច. ត្រូវបានគេព្រមានជាលើកទីពីរ គាត់ក៏បាន "ជជែកគ្នាត្រង់ៗ" ជាមួយប្រពន្ធរបស់គាត់ឲ្យរួមភេទជាមួយគ្នាដើម្បី "រក្សាជីវិតរបស់ពួកគេ"។ នាងនៅតែបន្តបដិសេធយ៉ាងដាច់ខាត ប៉ុន្តែចុងក្រោយពួកគេក៏បានរួមភេទ។ ស.ប.ច. នៅចាំបានថា "ខ្ញុំគិតថា ប្រពន្ធរបស់ខ្ញុំនឹងមិនដេកជាមួយខ្ញុំទេ លុះត្រាតែនាងស្រឡាញ់ខ្ញុំ។ ខ្ញុំមិនមានអារម្មណ៍ចង់រួមភេទជាមួយនាងទេ ឬសូម្បីតែទុកនាងជាប្រពន្ធរបស់ខ្ញុំ ព្រោះខ្ញុំមិនបានស្រឡាញ់នាងទាល់តែសោះ"[87]។

ពាក់កណ្តាលនៃបទសម្ភាសន៍ករណីសិក្សាជាមួយនឹងស្ត្រីបានរៀបរាប់ថា ខ្លួនត្រូវបានប្តីរបស់ខ្លួនចាប់រំលោភ។ នៅក្នុងករណីរបស់ ផ.ស. ការចាប់រំលោភរបស់នាងត្រូវបានជួយ និងជំរុញដោយកម្មាភិបាលខ្មែរក្រហម។ ក្នុងនាមជាកូនក្រមុំជាកុមារ នាងត្រូវបានគេបង្ខំឲ្យរៀបការនៅវ័យអាយុ ១៥ ឆ្នាំ មុនពេលដែលនាងបានចាប់ផ្តើមមានរដូវទៅទៀត។ ប្តីដែលគេចាត់តាំងឲ្យនាងគឺបុរសដែលមានអាយុលើសនាងជិតពីរដង គឺអាយុ ២៨ ឬ ២៩ ឆ្នាំ។ ឪពុក និងពូរបស់នាងធ្លាប់ធ្វើជាទាហានជាមួយរដ្ឋាភិបាលមុន ដែលត្រូវបានសម្លាប់នៅថ្ងៃដំបូងៗនៃរបបខ្មែរក្រហមមកម្ល៉េះ ហើយ ផ.ស. ត្រូវបានគេចាត់ទុកថាជាប្រជាជន "ថ្មី" ដែលមានជាប់ពាក់ព័ន្ធនឹងខ្មាំង។ នាងបានរៀបរាប់អំពីអាពាហ៍ពិពាហ៍ និងយប់ដំបូងៗនៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់នាងថា៖

> *"នៅពេលដែលខ្ញុំឃើញមនុស្សចាប់ផ្តើមកាន់ដៃគ្នា ខ្ញុំព្យាយាមដើរចេញ។ ខ្ញុំនិយាយថា ខ្ញុំមិនចង់ធ្វើដូចនោះទេ ខ្ញុំគ្មានម្តាយ ខ្ញុំនៅក្មេង ខ្ញុំមិនចង់ធ្វើបែបនោះទេ។ ខ្ញុំបានព្យាយាមរត់ចេញ ហើយកម្មាភិបាលម្នាក់ក៏បានបាញ់មួយគ្រាប់ទៅលើមេឃ។ ពួកគេបានប្រាប់ខ្ញុំថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ គេបញ្ជាឲ្យខ្ញុំអង្គុយទល់មុខប្តីរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដែលស្គាល់គាត់ទេ គាត់ចាស់ជាងខ្ញុំឆ្ងាយណាស់ ហើយជាមនុស្សមាឌធំទៀត។ ខ្ញុំមិនហ៊ានសម្លឹងមើលគាត់ទេ។ គេបានបញ្ជាឲ្យយើងចាប់ដៃគ្នា*

---

[87] បទសម្ភាសន៍ជាមួយករណីសិក្សាទី ១, ប្រុស (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

*ហើយខ្ញុំក៏ប្រកែក ដូច្នេះគេក៏យកកាំភ្លើងមកគំរាមខ្ញុំម្តងទៀត។ ខ្ញុំបានយំ ហើយសុំអង្វរគេថា "ខ្ញុំនៅក្មេងណាស់ ហើយខ្ញុំមិនទាន់ពេញវ័យនឹងរៀបការបានទេ"។ ខ្ញុំមិនយល់ថាស្នេហាគឺជាអ្វីឡើយ។ ហើយខ្ញុំគ្មានម្តាយនៅក្បែរដើម្បីពន្យល់ខ្ញុំពីការមករដូវរបស់ស្ត្រីនោះទេ រឿងបែបនោះទេ។ ខ្ញុំមិនបាននៅជាមួយឪពុកម្តាយទេ មិនបានទទួលការមើលថែទាំ និងការពារពីពួកគេឡើយ ... [បន្ទាប់ពីរៀបការរួច] ពួកគេបាននាំពួកយើងទៅផ្ទះមួយដែលមានបន្ទប់តូចៗជាច្រើន។ ខ្ញុំមិនចង់និយាយពីរឿងនោះទេ។ ប្តីរបស់ខ្ញុំបានព្យាយាមបង្ខំខ្ញុំឱ្យរួមភេទជាមួយគាត់ចំនួនបីយប់ ប៉ុន្តែខ្ញុំបានបដិសេធ។ ប្តីរបស់ខ្ញុំបានព្យាយាមស្រាតខោអាវខ្ញុំ ប៉ុន្តែខ្ញុំបានវាយបកគាត់វិញ ខ្ញុំបានទាត់គាត់នៅពេលដែលគាត់ព្យាយាមស្រាតខោអាវខ្ញុំ។ តាមរបៀបនេះ យប់ដំបូងក៏បានឆ្លងផុតទៅ ... នៅយប់ទីបី ខ្ញុំបានគេចខ្លួនទៅសហករណ៍មួយផ្សេងទៀត ប៉ុន្តែឈ្លបបាននាំប្តីរបស់ខ្ញុំមករកខ្ញុំ ... អ្នកយាមបាននិយាយថា វាស្ទើរតែមួយសប្តាហ៍ហើយ ហើយយើងនៅតែមិនបានដេកជាមួយគ្នាទៀត ដូច្នេះយប់នេះយើងត្រូវតែរួមភេទជាមួយគ្នា។ ខ្ញុំមិនយល់ព្រមទេ។ ខ្ញុំបាននិយាយថា ខ្ញុំមិនខ្វល់ថាខ្ញុំស្លាប់ ឬរស់នោះទេ។ អ្នកយាមមានពីរនាក់ ម្នាក់ក្នុងចំណោមពួកគេគឺនៅរស់រហូតដល់សព្វថ្ងៃនេះ។ ពួកគេបានចងដៃចងជើងខ្ញុំជាប់ជាមួយគ្រែ ហើយបន្ទាប់មកពួកគេក៏ដើរចេញឆ្ងាយពីគ្រែ។ ហើយប្តីចង្រៃនោះក៏រំលោភខ្ញុំ គាត់ហែកខោរបស់ខ្ញុំ ហើយអ្នកយាមពីរនាក់នោះក៏ឈរមើលនៅក្បែរ នោះផងដែរ។ ប្តីរបស់ខ្ញុំបានរំលោភខ្ញុំ ហើយធ្វើអ្វីដែលគាត់ចង់ធ្វើមកលើខ្ញុំ។ គាត់បានហែកខោអាវរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍អាម៉ាស់យ៉ាងខ្លាំង។ ពូរបស់ខ្ញុំក៏នៅក្នុងបន្ទប់ជាប់នោះដែរ គាត់បានមើលឃើញរឿងដែលកើតឡើងចំពោះខ្ញុំ តែបានត្រឹមតែគ្រវីក្បាលប៉ុណ្ណោះ។ ពូរបស់ខ្ញុំមិនអាចទ្រាំឈរមើលបានទេ ប៉ុន្តែគាត់ធ្វើអ្វីមិនកើត។ បន្ទាប់ពី [ប្តីខ្ញុំ] រំលោភខ្ញុំរួច គាត់មិនចង់ដោះលែងខ្ញុំទេ គាត់នៅតែចង់ចងខ្ញុំ ព្រោះគាត់ចង់រំលោភខ្ញុំម្តងទៀត ... ខ្ញុំស្រែកយំឱ្យគេជួយ ហើយសុំគាត់កុំឱ្យធ្វើបែបនេះទៀត! ប៉ុន្តែ [ប្តីខ្ញុំ] បាននិយាយថា គាត់មិនអាចជួយខ្ញុំបានទេ ព្រោះគាត់ត្រូវធ្វើតាមអង្គការ។ ពួកគេបាននិយាយថា ពួកគេបានរៀបការឱ្យពួកយើងដើម្បីបង្កើតកូនឱ្យអង្គការ'[88]។*

ការរំលោភនោះបានធ្វើឱ្យមានឈាមហូរយ៉ាងច្រើនពីទ្វារមាស ដែលសម្រាប់បញ្ហានេះ ផ.ស. ត្រូវបានគ្រូពេទ្យណែនាំក្រៅផ្លូវការថាឱ្យប្រើថ្នាំស្មៅ ដោយសារតែគ្មានមន្ទីរពេទ្យណាដំណើរការឡើយ។ បន្ទាត់ចុង

---

[88] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ក្រោយនៃសម្រង់សម្ដីនេះបានបង្ហាញថា ប្ដីរបស់នាងប្រហែលជាគាត់ខ្លួនឯងក៏មានអារម្មណ៍ថាត្រូវគេបង្ខំឱ្យរំលោភនាងដែរ ដោយមានវត្តមានរបស់កម្មាភិបាលផងនោះ ដើម្បីឱ្យគាត់នៅរស់រានមានជីវិត ឬយ៉ាងហោចណាស់ គាត់ប្រើប្រាស់គោលនយោបាយរដ្ឋជាមូលហេតុមួយដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃការរំលោភនោះដែរ។

ក.ល. ក៏ត្រូវប្ដីដែលគេចាត់តាំងឱ្យនោះរំលោភដែរនៅយប់ថ្ងៃរៀបការដោយបង្ខំរបស់ពួកគេនោះ ហើយនាងក្រោយមកក៏ត្រូវទទួលរងនូវទំនាក់ទំនងមួយដែលមាន "ការវាយធ្វើបាប និងឈ្លោះប្រកែកគ្នា" នៅពេញមួយរយៈពេលនៃរបបនោះរហូតមកដល់សព្វថ្ងៃ។ ដំណើររឿងរបស់នាងបានបង្ហាញពីរបៀបដែលគោលនយោបាយឃោរឃៅនៃរបបនេះអាចត្រូវបានគេប្រើយ៉ាងងាយស្រួល ដើម្បីបន្តការរំលោភបំពានផ្លូវភេទក្នុងអាពាហ៍ពិពាហ៍ និងពង្រឹងទង្វើនេះ។

*"ល្ពបតែងតែឃ្លាំមើលប្ដីរបស់ខ្ញុំ និងខ្ញុំរាល់យប់។ ប្រសិនបើខ្ញុំមិនយល់ព្រមរួមភេទជាមួយប្ដីរបស់ខ្ញុំទេ ខ្ញុំនឹងត្រូវគេបញ្ជូនទៅ "អប់រំឡើងវិញ" ដូច្នេះខ្ញុំមិនដែលបដិសេធនឹងប្ដីរបស់ខ្ញុំទេ ហើយខ្ញុំមានតែបណ្ដោយឱ្យប្ដីរបស់ខ្ញុំធ្វើអ្វីដែលគាត់ចង់ធ្វើប៉ុណ្ណោះ។ ទំនាក់ទំនងរវាងប្ដីខ្ញុំ និងខ្ញុំគឺមិនសូវជាល្អទេ ដោយសារតែប្ដីរបស់ខ្ញុំមិនមែនជាបុរសចិត្តទូលាយ និងមិនយល់ពីភាពជាដៃគូ។ ខ្ញុំបានរស់នៅជាមួយគាត់ដោយគ្មានសុភមង្គលសោះឡើយ និងសូម្បីតែសព្វថ្ងៃនេះ យើងនៅតែនៅជាមួយគ្នាដដែល។ ខ្ញុំនៅតែរស់នៅជាមួយគាត់ ព្រោះខ្ញុំមានអារម្មណ៍អាណិតកូនៗរបស់ខ្ញុំ ហើយខ្ញុំមិនចង់ឱ្យកូនៗរបស់ខ្ញុំក្លាយទៅជាក្មេងកំព្រានោះឡើយ"*[89] ។

យោងតាមអ្នកផ្ដល់បទសម្ភាសន៍ករណីសិក្សា អាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងរបស់សហព័ទ្ធដែលត្រូវបានបង្ខំ ដែលគេបង្កើតឡើងនៅក្រោមរបបខ្មែរក្រហម បានបង្កើតជាវប្បធម៌មួយនៃការរំលោភសេពសន្ថវៈ ដែលប្ដីត្រូវបានបង្ខិតបង្ខំឱ្យបំពានផ្លូវភេទ និងផ្លូវកាយមកលើប្រពន្ធដោយគ្មានការដាក់ទោស នៅចំពេលដែលទង្វើនោះត្រូវបានគាំទ្រដោយផ្ទាល់ពីសំណាក់កម្មាភិបាលខ្មែរក្រហម និងក្នុងករណីមួយចំនួន វាអាចសន្មត់បានថាគឺធ្វើឡើងដើម្បីរស់រានមានជីវិត។ ស្ត្រីជាប្រពន្ធមិនមានទីពំនឹងពីខាងមន្ទីរពេទ្យ ប៉ូលីស ឬវិធានច្បាប់ដើម្បីការពារសិទ្ធិរបស់ពួកគេនោះទេ។ មនុស្សជាច្រើនបានព្យាយាមជំទាស់ គូស្វាមីភរិយាមួយចំនួនប៉ុណ្ណោះដែលធ្វើពុតថាបានរួមភេទ ហើយអ្នកផ្សេងទៀតបានចុះចាញ់ទៅនឹងការទាមទារនៃរបបនេះក្រោមការឃ្លាំមើល

---

[89] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៦, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ជាប់ជានិច្ចពីសំណាក់ឈ្លប និងត្រូវបានជំរុញទឹកចិត្តជាញឹកញាប់បំផុតដោយបំណងប្រាថ្នាដើម្បីរស់រានមានជីវិត។

**ការជំទាស់ និងទណ្ឌកម្ម**

ករណីសិក្សាទាំងអស់បានលើកឡើងអំពីទម្រង់នៃការជំទាស់ និងឧបាយកលមួយចំនួនជុំវិញអាពាហ៍ពិពាហ៍ដោយបង្ខំ។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួនតូចបានប្រាប់ថា ខ្លួនបានច្រានចោលនូវសំណើសុំរៀបការដោយបង្ខំដោយភ្នាក់ងារខ្មែរក្រហមជាច្រើនលើកច្រើនសារ ប៉ុន្តែក្រោយមកត្រូវបានគេគំរាមថានឹងដាក់ទណ្ឌកម្ម ឬសម្លាប់ចោលប្រសិនបើចុងក្រោយពួកគេមិនព្រមទទួលយក។ ក.ន. បានពន្យល់ថា "ខ្ញុំបាននិយាយពីរដងថា ខ្ញុំនឹងមិនរៀបការទេ ប៉ុន្តែចុងក្រោយនៅពេលដែលខ្ញុំយល់ព្រម ពួកគេបាននិយាយថា "[បដិសេធ] ម្តង ឬពីរដងមិនអីទេ តែលើកទីបី មិត្តមិនអាចបដិសេធបានទេ"[90]។ ហ.អ. បានរៀបរាប់ថា៖ "កម្មាភិបាលបានប្រាប់ខ្ញុំថា "មិត្ត នៅថ្ងៃនេះ មិត្តត្រូវរៀបការហើយ ហើយប្តីរបស់មិត្តគឺបុរសម្នាក់នេះ។ មិត្តមិនអាចបដិសេធបានទេ។ បើទោះបីជាមិត្តមិនចង់រៀបការក៏ដោយ ក៏មិត្តត្រូវតែរៀបការដែរ។ ដោយសារតែ*អង្គការ*បានរៀបចំឲ្យមិត្ត មិត្តមិនអាចបដិសេធបានទេ"[91]។

វប្បធម៌នៃការរំលោភសេពសន្ថវៈក៏បានពង្រីកខ្លួនទៅរកការដាក់ទណ្ឌកម្មផងដែរ ដែលអាចនាំមកនូវអំពើហិង្សាផ្លូវភេទ។ អ្នកឆ្លើយសំណួរជាស្ត្រីពីរនាក់ដែលបានរៀបការនៅមុនរបបនេះបានសង្ស័យថា ការការកាត់ទោសសម្លាប់ប្តីរបស់ពួកគេគឺទាក់ទងទៅនឹងបុរសផ្សេងទៀត ពោលគឺ ភ្នាក់ងារខ្មែរក្រហមដែលចង់រៀបការជាមួយពួកគេ[92]។ ស្ត្រីទាំងពីរនាក់ត្រូវបានចាប់ដាក់គុក និងត្រូវបានគេរំលោភសេពសន្ថវៈដោយសារតែពួកនាងបដិសេធមិនព្រមរៀបការ។ ប្តីរបស់ ស.អ. ត្រូវបានសម្លាប់ដោយបងប្រុសថ្លៃរបស់នាង ដែលជាទាហានខ្មែរក្រហម ពីបទធ្វើការនៅក្នុងជួរកងទ័ពរបស់រដ្ឋាភិបាលមុន។ នាងមានផ្ទៃពោះផងនៅពេលនោះ។ ពេលដែលកូនទីមួយរបស់នាងបានអាយុប្រាំមួយខែ បងប្រុសថ្លៃរបស់នាងម្នាក់ទៀត ដែលត្រូវជាប្តីរបស់បងស្រីដែលបានស្លាប់ទៅរបស់នាង បានសុំនាងរៀបការ។ នាងសង្ស័យថា បងថ្លៃទាំងពីរផ្សំគំនិតគ្នា។ បងប្រុសថ្លៃដែលសុំនាង

[90] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រីជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។

[91] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

[92] បទសម្ភាសន៍ជាមួយករណីសិក្សាទី ២, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤); បទសម្ភាសន៍ជាមួយករណីសិក្សាទី ៧, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

រៀបការនោះគឺជាប្រធានផ្នែកភស្តុភាប្រចាំស្រុក ដែលជាតំណែងមួយដ៏មានអនុភាពទទួលបន្ទុកត្រួតពិនិត្យមើលរបបអង្ករ និងរបបអាហារ។ ពេលនាងបដិសេធមិនទទួលយកសំណើនោះ នាងត្រូវបានគេបញ្ជូនទៅដាក់គុក។ នាងត្រូវបានគេដោះលែងនៅប្រាំខែក្រោយមកដោយសារបងប្រុសថ្លៃដដែលនេះ ហើយត្រូវគេបញ្ជូនទៅកាន់ផ្ទះរបស់ម្តាយនាង។ នៅទីនោះ គាត់បានប៉ុនប៉ងរំលោភនាង ហើយនៅពេលដែលពាក្យខ្សឹបខ្សៀវបានចាប់ផ្តើមលេចលឺនៅជុំវិញភូមិនោះ គាត់ក៏សុំខ្ញុំរៀបការ (ដែលបង្ហាញថា យ៉ាងហោចណាស់នៅកម្រិតណាមួយនោះ ភ្នាក់ងារខ្មែរក្រហមមានសេរីភាពក្នុងការជ្រើសរើសគូអាពាហ៍ពិពាហ៍របស់ពួកគេ)។ នាងបានបដិសេធបីដង ទីមួយដោយហេតុថា នាងទើបនឹងក្លាយជាស្ត្រីមេម៉ាយ ហើយគាត់គឺជាមន្ត្រីខ្មែរក្រហមដែលមិនបានទទួលការអប់រំឡើយ (“ហើយថា ពួកខ្មែរក្រហមបានសម្លាប់ប្រជាជនកម្ពុជា”)។ ម្តាយរបស់នាងបានព្យាយាមបញ្ចុះបញ្ចូលនាងឲ្យទទួលយកអាពាហ៍ពិពាហ៍នោះដើម្បីរក្សាជីវិតខ្លួនឯង និងជីវិតរបស់កូនតូចរបស់នាង។ សម្រាប់សំណើសុំរៀបការលើកទីបួនរបស់គាត់ បងប្រុសថ្លៃនោះតាមមកជាមួយនឹងបុរសពីរនាក់ ដែលម្នាក់ជាមន្ត្រីភូមិ ។ ស.អ. បានរៀបរាប់ដូច្នេះថា៖

*គាត់បាននិយាយថា “រៀបការជាមួយខ្ញុំទៅណា ហើយមិត្តនឹងអាចរស់នៅបានស្រួល”។ ខ្ញុំបានឆ្លើយថា “ហ៊ឹម... ប្តីខ្ញុំទើបនឹងស្លាប់ ដូច្នេះខ្ញុំមិនអាចរៀបការជាមួយមិត្តបានទេ”។ គាត់បានបន្តទៀតថា “មិត្តអាចជួបបញ្ហាជាច្រើន បើមិត្តមិនព្រមរៀបការជាមួយខ្ញុំ”។ គាត់ថែមទាំងបានសួរខ្ញុំថា “តើមិត្តមិនខ្លាចស្លាប់ទេឬ? ខ្ញុំបានឆ្លើយថា “ខ្ញុំមិនខ្លាចស្លាប់ទាល់តែសោះ។ ខ្ញុំមិនខ្វល់ទេ។ បើខ្ញុំស្លាប់ ហើយគ្មាននរណាមើលថែទាំកូនប្រុសខ្ញុំ ទុកឲ្យវាស្លាប់តាមខ្ញុំទៅ”។ នៅយប់នោះ គាត់បានបញ្ជាឲ្យទាហានវ័យក្មេងប៉ុន្មាននាក់មកផ្ទះខ្ញុំ ហើយចាប់ខ្ញុំចង។ វាគឺនៅម៉ោងប្រហែល ៨ យប់ នៅពេលដែលខ្ញុំកំពុងរៀបចំដេក។ ពេលដែលម្តាយខ្ញុំសួរ [ហេតុអ្វីបានជាពួកគេចាប់ខ្ញុំយកទៅ] ពួកគេបានឆ្លើយថា “កូនស្រីមឹងធ្វើខុស”។ ម្តាយខ្ញុំបានបន្តទៀតថា “តើនាងធ្វើខុសអ្វីខ្លះ? ពួកគេឆ្លើយថា “នាងបដិសេធមិនព្រមរៀបការ”។ ខ្ញុំដឹងយ៉ាងច្បាស់ថា បងថ្លៃប្រុសរបស់ខ្ញុំគឺជាអ្នកបញ្ជាឲ្យធ្វើរឿងនេះ។ បន្ទាប់ពីពួកគេបានចងខ្ញុំរួច ពួកគេបានយកខ្ញុំទៅដាក់លើត្រាក់ទ័រមួយដែលនៅទីនោះមានស្ត្រីជាច្រើននាក់រួចទៅហើយ”*[93] ។

ស្ត្រីទាំងនោះត្រូវបានគេនាំទៅវត្តមួយនៅក្បែរនោះដែលគេប្រើធ្វើជាគុក ដែលនៅទីនោះពួកគេត្រូវបានគេដាក់ច្រវ៉ាក់ និងនាំយកទៅបន្ទប់មួយដែលមានមនុស្សប្រុសស្រី ១០ នាក់ផ្សេងទៀត។

---

[93] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៧, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

*“មានទាហានវ័យក្មេងពីប្រាំទៅប្រាំពីរនាក់ដែលបានមករំលោភអ្នកទោសថ្មីៗ រួមទាំងខ្ញុំផងដែរដោយប្រើមេជើងរបស់ពួកគេ។ ពួកទាហានទាំងនោះមានអាយុប្រហែល ២០ឆ្នាំ ឬតិចជាងនេះ។ ពួកគេបានស្រែកសម្លុតខ្ញុំ និងស្ត្រីផ្សេងៗទៀតឱ្យស្រាតសំពត់ចេញ ហើយពួកគេបានចាប់ផ្ដើមរុញមេជើងរបស់គេចូលក្នុង [ទ្វារមាសរបស់យើង]។ ពួកគេតែងតែធ្វើបែបនេះដាក់អ្នកទោសថ្មីៗ”*[94] ។

ច.ផ. ក៏បានជួបប្រទះនឹងទណ្ឌកម្មធ្ងន់ធ្ងរផងដែរ ដោយរៀបរាប់អំពីរបៀបដែលនាងត្រូវបានគេទុកជាទាសករផ្លូវភេទនៅក្នុងគុកពេស្យាចារមួយ ដោយសារតែនាងបដិសេធមិនព្រមរៀបការជាមួយអ្នកសម្លាប់ប្ដីនាង។ នាងមានផ្ទៃពោះបីខែនៅពេលនោះ។ នាងបានរៀបរាប់ថា៖

*“ចាស ប្រធាន ជ បានស្រឡាញ់ខ្ញុំ ហើយប្ដីខ្ញុំត្រូវបានគេសម្លាប់ដោយសារតែរឿងនោះដែរ ... នៅពេលដែលខ្ញុំបានដឹងរឿងនោះ ខ្ញុំបានស្រែកយ៉ាងខ្លាំង ហើយនិយាយថា “សូមយកប្ដីខ្ញុំមកឱ្យខ្ញុំវិញមក !” បន្ទាប់មក ខ្ញុំត្រូវបានគេដាក់ច្រវ៉ាក់ និងនាំទៅដាក់គុកទាំងយប់។ នៅព្រឹកបន្ទាប់នោះ ប្រធាន ជ បានដោះលែងខ្ញុំ។ ខ្ញុំត្រូវបានកម្មាភិបាលប៉ុន្មាននាក់នាំទៅសាលារៀនភាសាចិន ហើយប្រាប់ថា ខ្ញុំនឹងទៅដាំដំឡូង។ នៅពេលដែលខ្ញុំទៅដល់ មានមនុស្សស្រីប្រុសប្រាំបួនគូ រួមទាំងខ្ញុំដែរ។ ខ្ញុំបានសួរថា “មិត្តនាំខ្ញុំមកដាំដំឡូង មែនទេ?” កម្មាភិបាលឆ្លើយថា “ទេ មិត្តមកទីនេះដើម្បីរៀបការជាមួយប្រធាន ជ”។ ពេលឮដូចនោះ ខ្ញុំក៏យំ។ ខ្ញុំបានតាំងចិត្តរួចហើយថា ខ្ញុំនឹងមិនរៀបការទេ។ មួយគូៗត្រូវបានគេប្រាប់ឱ្យចាប់ដៃគ្នា ហើយនៅពេលដែលដល់វេនខ្ញុំ ខ្ញុំបាននិយាយថា “ទេ ខ្ញុំមិនដឹងថានេះគឺជាប្ដីរបស់នរណាគេទេ! ខ្ញុំមិនរៀបការទេ ទោះជាសម្លាប់ខ្ញុំពេលនេះក៏ដោយ ក៏ខ្ញុំមិនរៀបការដែរ! ខ្ញុំមិនដឹងថាឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំនៅឯណានោះទេ! ប្រធាន ជ បានទះកំផ្លៀងខ្ញុំ ហើយគាត់បានប្រើស្បែកជើងមកវាយក្បាលខ្ញុំជាច្រើនដង។ គាត់បានសួរថា “រៀបការ ឬអត់? ខ្ញុំនៅតែនិយាយថា “ទេ ទេ!” ... ប្រធាន ជ បាននិយាយប្រាប់អ្នកយាមថា “នាំនាង [ត្រឡប់ទៅគុក] ទៅវិញទៅ ហើយខ្ញុំនឹងរំលោភនាងនៅពេលក្រោយ”។*

*នៅក្នុងគុក គេបានស្រាតខោអាវរបស់ខ្ញុំ និងដាក់ច្រវ៉ាក់ខ្ញុំ ... ពេលណាដែលខ្ញុំកាន់តែរើ ខ្សែច្រវ៉ាក់នោះកាន់តែតឹងឡើង ... បន្ទាប់មក ពួកទាហានវ័យក្មេង អាយុប្រហែល ១៦ ឬ ១៦ ឆ្នាំ បានប្រើស្បែកជើងរបស់ពួកគេមកប៉ះទ្វារមាសរបស់ខ្ញុំ ហើយពួកគេបានច្របាច់សុដន់របស់ខ្ញុំ ហើយថើបខ្ញុំរហូតដល់ខ្ញុំ*

[94] ដូចឯកសារខាងលើ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

*សន្លប់ ... នៅពេលដែលខ្ញុំភ្ញាក់ឡើងនៅពេលព្រឹក ខ្ញុំបានឃើញប្រធាន ជ នៅក្បែរខ្ញុំ។ គាត់និយាយថា "ឃើញទេ? ប្រសិនបើអ្នកយល់ព្រមរៀបការជាមួយខ្ញុំនោះ អ្នកនឹងមិនមានបញ្ហាដូចពេលឥឡូវនេះទេ។ ប៉ុន្តែ បើទោះជាអ្នកមិនយល់ព្រមក៏ដោយ ក៏ខ្ញុំបានអ្នករួចទៅហើយ"។ ហើយរៀងរាល់យប់ ខ្ញុំមិនបានដឹងថា ពួកទាហានវ័យក្មេងទាំងនោះមកពីណាទេ ប៉ុន្តែពួកគេនាំគ្នាមកវាយខ្ញុំ ហើយរំលោភខ្ញុំរហូតដល់ខ្ញុំសន្លប់ ហើយនៅពេលដែលខ្ញុំភ្ញាក់ឡើង ខ្ញុំឃើញប្រធាន ជ នៅក្បែរខ្លួនខ្ញុំ"។*

ច.ផ. បានរៀបរាប់អំពីរបៀបដែលការដាក់ទណ្ឌកម្មមកលើនាងមិនមែនជារឿងដាច់ដោយឡែកនោះទេ និងរបៀបដែលអំពើហិង្សាផ្លូវភេទគឺជាផ្នែកមួយនៃការដាក់ទណ្ឌកម្មសម្រាប់ការបដិសេធមិនព្រមទទួលយកអាពាហ៍ពិពាហ៍ដោយបង្ខំ។

*"ខ្ញុំមិនមែនមានតែម្នាក់ឯងនៅទីនោះទេ។ មានមនុស្សពី ២០ ទៅ ៥០ នាក់ទៀត ដែលសុទ្ធជាស្ត្រីទាំងអស់។ ករណីខ្លះ ស្ត្រីទាំងនោះត្រូវបានគេនាំមកទីនេះដោយសារតែពួកនាងបដិសេធមិនព្រមរៀបការដូចករណីរបស់ខ្ញុំដែរ។ ពួកគេបានចាប់រំលោភស្ត្រីទាំងនោះ។ ដោយប្រើលិង្គរបស់ពួកគេដាក់ចូលក្នុងមាត់របស់យើង ឬប៉ះផ្ទាល់លើមុខរបស់យើង។ ខ្ញុំមិនដឹងទេថាតើមានមនុស្សប៉ុន្មាននាក់បានរំលោភខ្ញុំក្នុងមួយយប់នោះ។ ពួកគេបានចាប់រំលោភស្រីៗនៅនឹងមុខពួកយើង ហើយខ្ញុំមានតែបិទភ្នែករបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំញ័រខ្លួនទទ្រើត។ ខ្ញុំយំទាំងថ្ងៃ ទាំងយប់។ ស្ត្រីផ្សេងទៀតដែលនៅទីនោះក៏ស្រែក ហើយយំដូចគ្នា។ មានក្មេងស្រីម្នាក់ នាងស្រស់ស្អាតខ្លាំងណាស់ ប៉ុន្តែនាងបានស្លាប់បន្ទាប់ក្នុងពេលតែមួយយប់ដោយសារតែពួកគេបានចាប់រំលោភនាងរហូតដល់ស្លាប់"[95]។*

អាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានផ្តួចផ្តើមដោយរបបខ្មែរក្រហមគឺជារឿងឈឺចាប់សម្រាប់គ្រប់ដំណើររឿងនៅក្នុងករណីសិក្សា។ ជម្រើសត្រូវបានលុបចោលភាគច្រើន លើកលែងតែក្នុងករណីដែលប្តីត្រូវបានគេគាំទ្រឲ្យជ្រើសរើសដើម្បីបំពាន ឬរំលោភប្រពន្ធជាលក្ខណៈវប្បធម៌ជាក់ស្តែងតែម្តងនៃការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ដោយនិទណ្ឌភាព។ ការយល់ព្រមត្រូវបានបង្ហាញថាគ្មានន័យនៅក្នុងបរិយាកាសនៃការដាក់ទណ្ឌកម្មពិតប្រាកដ និងដោយគំរាមកំហែង។ អំពើហិង្សាផ្លូវភេទ ជាពិសេសមកលើស្ត្រី ត្រូវបានគេប្រើដើម្បីបំពេញអាពាហ៍ពិពាហ៍ ព្រមទាំងជាការដាក់ទណ្ឌកម្មលើអ្នកណាដែលមិនគោរពតាមអាពាហ៍ពិពាហ៍ដោយបង្ខំ និងអនុវត្តគោលនយោបាយទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំរបស់អង្គការ។ ការផ្តួចផ្តើម

95 បទសម្ភាសន៍ជាមួយករណីសិក្សាទី ២, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៥)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ឲ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំដូចដែលបានរៀបរាប់នេះ គឺជាការប្រមាថគួរឲ្យអាម៉ាស់លើភាពថ្លៃថ្នូររបស់មនុស្ស និងជាបទល្មើសប្រឆាំងនឹងគោលការណ៍វប្បធម៌ដ៏សំខាន់មួយ។

**គ. អាពាហ៍ពិពាហ៍ក្រោយរបបខ្មែរក្រហម**

ពេលដែលរបបខ្មែរក្រហមបានដួលរលំដោយកងកម្លាំងលុកលុយរបស់វៀតណាម នៅឆ្នាំ ១៩៧៩ គេមើលឃើញទិដ្ឋភាពមួយនៃការរងទុក្ខដ៏ច្រើនលើសលប់របស់មនុស្ស ជាមួយនឹងក្រុមគ្រួសារដែលប៉ងចង់ជួបជុំសមាជិកគ្រួសារដែលនៅមានជីវិតឡើងវិញ និងការបាត់បង់ទ្រព្យសម្បត្តិ និងទឹកដីកំណើត។ បន្ថែមពីលើនេះគឺមានសង្គ្រាមស៊ីវិលមួយ ដោយសារតែកងកម្លាំងសន្តិសុខរបស់រដ្ឋបានព្យាយាមបង្ក្រាបការបះបោរខ្មែរក្រហមដ៏អូសបន្លាយ។ បទសម្ភាសន៍បានលើកឡើងពីការយល់ច្រឡំនៅក្នុងរយៈពេលនេះជុំវិញស្ថានភាពអាពាហ៍ពិពាហ៍ដែលបានធ្វើឡើងនៅក្រោមរបបនេះ។ គូស្វាមីភរិយាបង្ខំចិត្តត្រូវសម្រេចថាតើពួកគេគួរនៅជាមួយគ្នាទៀត ឬបែកគ្នាដោយផ្អែកលើមួយករណីៗ និងជាផ្នែកមួយទៅលើការគិតគូរផ្សេងៗទៀតអំពី ថាតើត្រូវរស់នៅឲ្យបានល្អបំផុតដោយរបៀបណានៅក្នុងការបំផ្លិចបំផ្លាញក្រោយរបបនេះ។ បទសម្ភាសន៍ករណីសិក្សាមួយចំនួនតូចជាមួយនឹងអ្នកដែលត្រូវបានបង្ខំឲ្យរៀបការបានលើកឡើងពីអាពាហ៍ពិពាហ៍ដែលខ្លួននៅតែរស់នៅជាមួយគ្នាយ៉ាងហោចណាស់អស់មួយរយៈ បន្ទាប់ពីការដួលរលំនៃរបបនេះ។ ប្តីប្រពន្ធពីរគូនៅតែបន្តនៅជាមួយគ្នារហូតដល់សព្វថ្ងៃនេះ ដែលមួយគូមានភាពចុះសម្រុងគ្នាល្អ ឯមួយគូទៀតស្ថិតក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងបំពានដែលមិនអាចគេចចេញបាន។ អាពាហ៍ពិពាហ៍ដោយបង្ខំផ្សេងទៀតត្រូវបានបែកបាក់ដោយសារការស្លាប់ការលែងលះ ការចែកផ្លូវគ្នា ឬបោះបង់ចោលគ្នា។

ប្តីប្រពន្ធដែលបានផ្តល់បទសម្ភាសន៍មិនមានគម្រោងរស់នៅជាមួយគ្នាទេពីដំបូងឡើយ ហើយបទសម្ភាសន៍របស់ពួកគេបានបង្ហាញពីរបៀបដែលគូស្វាមីភរិយាគួរណាស់តែនៅជាមួយគ្នា ទៅតាមសភាពការណ៍ជាក់ស្តែងដែលត្រូវប្រឈមមុខនឹងបណ្តាញសង្គម និងគ្រួសារដែលរងការបំផ្លិចបំផ្លាញនៅក្រោយរបបនោះ។ អ.ប.ច. និង ស.ច. បានរៀបរាប់អំពីថ្ងៃដំបូងៗបន្ទាប់ពីការដួលរលំនៃរបបនេះ នៅពេលដែលមនុស្សម្នាកំពុងស្វែងរកសមាជិកគ្រួសារដែលនៅរស់រានមានជីវិត ដែលបានលាក់ខ្លួននៅក្នុងព្រៃគេចពីកម្មាភិបាលខ្មែរក្រហម ឬដោយសារភ័យខ្លាចនឹងកងកម្លាំងលុកលុយរបស់វៀតណាម។ សមាជិកគ្រួសារដែលមានសាច់ញាតិច្រើនមានតួនាទីរក្សាចំណងអាពាហ៍ពិពាហ៍មិនឲ្យបែកបាក់ ដែលបញ្ជាក់ថា ទំនៀមទម្លាប់រៀបអាពាហ៍ពិពាហ៍ជាប្រពៃណីបានរស់ឡើងវិញ យឺតៗ ក្នុងអំឡុងពេលនោះ។ ក្នុងបទសម្ភាសន៍ជាច្រើន រួមទាំងបទសម្ភាសន៍មួយនេះផង សោកនាដកម្មដែលបានចែករំលែក និងការជួយដល់គ្នាទៅវិញទៅមកបានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ចំណងទំនាក់ទំនង ឧទាហរណ៍ អ.ប.ច. និង ស.ច. បានចែករំលែកបទសម្ភាសន៍របស់ខ្លួនអំពីទង្វើតូចមួយនៃសេចក្ដីសប្បុរសចំពោះគ្នាទៅវិញទៅមក ដែលនៅពេលខ្លះមានន័យថាជាភាពខុសគ្នារវាងការរស់ ឬស្លាប់ ដោយចែករំលែកម្ហូបអាហារគ្នា ឬជួយបញ្ចប់កូតាការងារគ្នា។ ឈ្មោះហៅគ្នាក្រោយរៀបការត្រូវបានប្រើក្នុងសម្រង់ខាងក្រោមដើម្បីជួយសម្រួលដល់ការអាន។

ប្ដី៖ *ម្ដាយរបស់ខ្ញុំមិនចង់ឱ្យខ្ញុំចាកចេញពីប្រពន្ធខ្ញុំទេ ហើយគាត់មានរទេះគោ។ ដូច្នេះ គាត់សុំឱ្យខ្ញុំមកយកប្រពន្ធរបស់ខ្ញុំមករស់នៅជាមួយពួកយើង ព្រោះគាត់មិនចង់ឱ្យនាងទៅរស់នៅតែជាមួយម្ដាយ [របស់នាង] តែឯង ។ ដូច្នេះ ខ្ញុំក៏បានទៅរកប្រពន្ធរបស់ខ្ញុំ ហើយនាំនាងមកឱ្យម្ដាយខ្ញុំ។*

ប្រពន្ធ៖ *នៅពេលនោះ ខ្ញុំគ្មានរទេះគោទេ ម្ដាយរបស់ខ្ញុំកំពុងឈឺធ្ងន់ ហើយយើងមានសម្ភារៈមួយចំនួនដូចជាអង្ករ ចាន ឆ្នាំង ដែលខ្ញុំត្រូវយកទៅជាមួយនៅពេលដែលយើងធ្វើដំណើរ។*

ប្ដី៖ *ខ្ញុំបានទៅយកនាងនៅម៉ោង ១២ ថ្ងៃ ... តាមពិត ខ្ញុំក៏ចង់ឱ្យនាងរស់នៅជាមួយពួកយើងដែរ ព្រោះយើងអាចថែរក្សាគ្នាទៅវិញទៅមកនៅតាមផ្លូវនៅក្នុងព្រៃនោះ។ [ក្រោយមក] នៅពេលដែលយើងនៅក្នុងព្រៃជាមួយគ្នា យើងបានជួបប្រទះនូវការលំបាកជាច្រើន ហើយយើងបានជួយគ្នាទៅវិញទៅមក។ យើងចាប់ផ្ដើមមានអារម្មណ៍ល្អចំពោះគ្នាចាប់តាំងពីនោះមក។*

ប្រពន្ធ៖ *ថ្ងៃនោះ ប្អូនប្រុសរបស់ខ្ញុំបាននិយាយជាមួយខ្ញុំថា "តើនរណាកំពុងបររទេះគោនោះ? ខ្ញុំបានងាកមើល ក៏ឃើញប្ដីរបស់ខ្ញុំ ហើយឆ្ងល់ថាហេតុអ្វីបានជាគាត់មកនៅក្នុងភូមិរបស់ខ្ញុំ។ ខ្ញុំរៀបចំបន្តដំណើរទៅគោលដៅរបស់ខ្ញុំជាមួយនឹងម្ដាយរបស់ខ្ញុំ ហើយខ្ញុំមិនបានខ្វល់ថាតើគាត់ទៅណាជាមួយនឹងគ្រួសាររបស់គាត់ទេ។*

អ្នកសម្ភាសន៍៖ *តើអ្នកមានគម្រោងជួបជុំប្ដីរបស់អ្នកវិញទេ?*

ប្រពន្ធ៖ *ទេ។ ម្ដាយរបស់គាត់បានសុំឱ្យគាត់មកយកម្ដាយរបស់ខ្ញុំ និងខ្ញុំ។ គាត់បាននិយាយថា "ម្ដាយរបស់ខ្ញុំបានសុំខ្ញុំឱ្យមកទទួលមិត្ត ដូច្នេះយើងអាចនៅជាមួយគ្នា និងមើលថែរក្សាគ្នាទៅវិញទៅមកបាន"។ ខ្ញុំគិតថា ខ្ញុំមិនមានអ្វីធ្វើដំណើរនោះទេ ហើយខ្ញុំខ្លាចថា ខ្ញុំមិនអាចរួចខ្លួនទេ [ប្រសិនបើពួកខ្មែរក្រហមចាប់យើងបាន] ប្រសិនបើខ្ញុំមិនទៅជាមួយគាត់ទេនោះ។ ដូច្នេះ ប្ដី*

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

> *របស់ខ្ញុំបានយករបស់របរ និងម្ដាយរបស់ខ្ញុំទៅរទេះគោ ហើយយើងបានទៅរស់នៅជាមួយគ្រួសាររបស់ប្ដីខ្ញុំទៅ’*[96] ។

នៅទីបំផុត ពួកគេមានកូនប្រាំពីរនាក់ជាមួយគ្នា ដែលកូនទីមួយកើតនៅឆ្នាំ ១៩៨០។ ដោយសារក្រពេកមិនអាចរៀបចំពិធីមង្គលការបែបប្រពៃណីនៅគ្រានោះបាន នៅឆ្នាំ ២០០០ ពួកគេបានសម្រេចថតរូបរៀបការដោយស្លៀកពាក់សំលៀកបំពាក់ប្រពៃណី។

គូអាពាហ៍ពិពាហ៍ដោយបង្ខំមួយគូផ្សេងទៀតដែលនៅមិនបែកបាក់រហូតដល់សព្វថ្ងៃ ក្នុងចំណោមគំរូនៃករណីសិក្សា គឺជាគូអាពាហ៍ពិពាហ៍ដោយបង្ខំដែលមានការបំពាន ដែលស្ត្រីជាប្រពន្ធមិនអាចរត់ចេញបាន។ អាពាហ៍ពិពាហ៍ដោយបង្ខំដែលមានការបំពានអាចនឹងត្រូវគេរំពឹងថាជាករណីមួយក្នុងចំណោមករណីដែលលំបាកបំផុតក្នុងការដោះស្រាយដោយសារតែការសងសឹក ការពឹងផ្អែកលើគ្នាខាងសេដ្ឋកិច្ច ការខ្លាចមិនហ៊ានបោះបង់កូនចោល និងការប៉ះទង្គិចផ្លូវចិត្តដែលបណ្ដាលមកពីការរំលោភបំពាន។ ហ.ក. ដំបូងព្យាយាមរត់គេចខ្លួនពីប្ដីនៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលរំលោភបំពានភ្លាមៗ បន្ទាប់ពីការដួលរលំនៃរបបនោះនៅឆ្នាំ ១៩៧៩។ ដោយគិតថា នាងត្រូវបាន “ដោះលែងពីគាត់” ហើយ និងថា អាពាហ៍ពិពាហ៍នោះលែងមានសុពលភាពទៀតហើយ នាងក៏បានធ្វើដំណើរតែម្នាក់ឯងទៅភូមិកំណើតរបស់នាងវិញ។ ពីរខែក្រោយមក ប្ដីដែលគេចាត់តាំងឲ្យនាងនោះបានរកឃើញនាងនៅពេលដែលនាងមានផ្ទៃពោះប្រាំខែ។ ហ.ក. បានពន្យល់ពីការសម្រេចចិត្តរបស់នាងដែលសម្រេចរក្សាចំណងអាពាហ៍ពិពាហ៍ថា៖ “ដោយសារតែខ្ញុំមានផ្ទៃពោះ ហើយខ្ញុំមិនមានសាច់ញាតិណាឡើយ ហើយខ្ញុំមិនមានលុយកាសអ្វីទេ ហើយខ្ញុំមិនចង់ឲ្យកូនរបស់ខ្ញុំធំឡើងដោយមានបញ្ហា ដោយសារតែពួកគេមិនមានក្រុមគ្រួសារនឹងគេនោះឡើយ”។ នាងបានបន្តរៀបរាប់អំពីជីវិតអាពាហ៍ពិពាហ៍ជាង ៣០ ឆ្នាំក្រោយមកទៀតថា៖

> *“នៅពេលដែលខ្ញុំបានប្ដឹងសុំគាត់លែងលះ ប៉ូលីសបានចាប់ខ្លួន និងធ្វើការអប់រំគាត់ គាត់បានវាយខ្ញុំនៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ។ ខ្ញុំនៅតែមានស្លាកស្នាមមួយនៅលើកែងរបស់ខ្ញុំ ព្រោះគាត់បានចាក់ខ្ញុំនៅឆ្នាំ ២០១២ ខណៈពេលដែលខ្ញុំកំពុងដេកនៅមុខទូរទស្សន៍ គាត់បានចាក់សោរទ្វារ ហើយចាក់ខ្ញុំ ខ្ញុំបានស្រែកឲ្យកូនខ្ញុំជួយ។ កូនរបស់ខ្ញុំស្ទើរតែមិនអាចជួយខ្ញុំបាននៅពេលនោះ ដោយសារតែទ្វារត្រូវបានចាក់សោរជាប់ ... ក្នុងអំឡុងរបបនោះ ខ្ញុំមានតែព្រមទទួលយកអាពាហ៍ពិពាហ៍នោះ ហើយមាន*

[96] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៣, ប្ដីប្រពន្ធ (ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

*ទំនាក់ទំនងផ្លូវភេទដើម្បីរក្សាជីវិតរបស់ខ្ញុំប៉ុណ្ណោះ។ បន្ទាប់មក ខ្ញុំមានកូនជាមួយប្តីរបស់ខ្ញុំ ហើយនោះឯងជាហេតុផលដែលខ្ញុំបានបន្តរស់នៅជាមួយគាត់"[97]*។

កូនត្រូវបានគេលើកឡើងថា ជាកត្តាលើកទឹកចិត្តចម្បងគេមួយដោយអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ នៅពេលដែលរំលឹកដល់អំពីអាពាហ៍ពិពាហ៍ដែលមិនបែកបាក់ សម្រាប់យ៉ាងហោចណាស់អស់មួយរយៈដែរ។

កម្រិតខ្ពស់នៃការរំលោភបំពានក្នុងអាពាហ៍ពិពាហ៍ដែលមិនបែកបាក់ ត្រូវបានគេលើកឡើងនៅក្នុងបទសម្ភាសន៍។ ក្រៅអំពី ហ.ក. ស្ត្រីជាអ្នកផ្តល់បទសម្ភាសន៍បីនាក់ផ្សេងទៀតក៏បានរៀបរាប់អំពីការរំលោភបំពានក្នុងគ្រួសារនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេផងដែរ ជាពិសេសបំផុតបន្ទាប់ពីការដួលរលំនៃរបបនោះទៅ។ ក.ន. បានទទួលជោគជ័យក្នុងការធានាឲ្យមានការលែងលះគ្នា ជាចម្បងដោយសារតែនាងអាចស្វែងរកជម្រកការពារនៅក្នុងសហគមន៍ចាមមូស្លីមរបស់នាង (ប្តីដែលគេចាត់តាំងឲ្យនាងគឺជាពុទ្ធសាសនិកខ្មែរ)។ នាងបានរៀបរាប់ថា៖

*"គាត់ផឹកស្រាជាមួយនឹងប្រុសៗផ្សេងទៀតនៅក្នុងភូមិ ហើយគាត់បានវាយដំខ្ញុំ។ នៅឆ្នាំ ២០០៦ ខ្ញុំបានសម្រេចចិត្តលែងលះគ្នា។ ខ្ញុំគឺជាអ្នកសម្រេចចិត្តបែបនេះ។ ខ្ញុំបានរាយការណ៍ទៅមេឃុំឲ្យជួយខ្ញុំ ព្រោះខ្ញុំមានការលំបាកណាស់ក្នុងការរស់នៅជាមួយគាត់ ... នៅពេលដែលគាត់ដឹងអំពីការលែងលះ ប្តីរបស់ខ្ញុំបានយកកាំបិតគំរាមខ្ញុំ ហើយខ្ញុំត្រូវរត់ទៅផ្ទះរបស់អ្នកភូមិមួយទៀតដើម្បីលាក់ខ្លួន"[98]*។

អ្នកផ្តល់បទសម្ភាសន៍ក៏លើកឡើងពីអំពើហិង្សាក្នុងគ្រួសារ និងការបែកបាក់ចំណងអាពាហ៍ពិពាហ៍ដែលកើតឡើងបន្ទាប់ពីប្តីរបស់ពួកគេត្រូវបានគេកេណ្ឌឲ្យចូលជួរកងទ័ពនៅឆ្នាំ ១៩៨៣ ផងដែរ។ ប្រការ នេះបានចង្អុលបង្ហាញពីការសង្កត់ធ្ងន់ទៅលើជម្លោះដែលកំពុងបន្តកើតឡើងលើអាកប្បកិរិយា និងជម្រើសរបស់បុរស ព្រមទាំងអារម្មណ៍អសន្តិសុខដែលស្ត្រីបន្តមាន ជាពិសេសអ្នកដែលជាប់នៅក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំដែលគ្មានការគាំទ្រ ឬមានការរំលោភបំពាន ក្នុងឆ្នាំដែលមានភាពចលាចលខាងស៊ីវិលដែលកំពុងមាន។ ក.ន. បាននិយាយថា "ដំបូង គាត់មិនអីនោះទេ គាត់ស្តាប់ខ្ញុំ ប៉ុន្តែចាប់តាំងពីឆ្នាំ ១៩៨៣ មក [នៅពេលដែលគាត់បានក្លាយជាទាហាន] គាត់បានចាប់ផ្តើមផឹកស៊ី ហើយប្រែក្លាយជាមនុស្សចិត្តអាក្រក់។ គាត់បានវាយដំខ្ញុំ

---

[97] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៦, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

[98] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រីជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

គាត់មិនស្តាប់តាមខ្ញុំទៀតទេ”[99]។ ព.ស. បានរៀបរាប់ថា “គាត់ទៅធ្វើជាទាហាន ហើយបានដេកជាមួយស្រីៗផ្សេងទៀតនៅទីនោះ។ គាត់គឺជាទាហាន ហើយគាត់ក៏មានស្រីច្រើនទៀត”[100]។ ហ.អ. បានពន្យល់ថា “មុនពេលដែលគាត់ចាកចេញទៅធ្វើការជាទាហាន គាត់មិនអីនោះទេ។ គាត់ធ្វើស្រែ ហើយធ្វើស្ករ គាត់ជួយចិញ្ចឹមកូនៗ។ គាត់គឺល្អធម្មតាទេ ប៉ុន្តែនៅពេលដែលគាត់បានក្លាយជាទាហាន គាត់បានផ្លាស់ប្តូរអស់”[101]។

ដូចដែលសង្ខេបនៅក្នុងផ្នែកទី ២ ការស្រាវជ្រាវដទៃទៀតបានចង្អុលបង្ហាញពីពីអតិរេកនៃ “ស្ត្រីមេម៉ាយ” (ពាក្យដែលគេប្រើដើម្បីហៅស្ត្រីដែលបានរៀបការតែគ្មានស្វាមី ដោយមធ្យោបាយណាមួយក៏ដោយ)។ បទសម្ភាសន៍ករណីសិក្សាបានផ្សារភ្ជាប់អាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះទៅនឹងការកើនឡើងនៃការបោះបង់ចោលប្តី និងប្តីដែលមានប្រពន្ធច្រើន ដែលទុកឱ្យប្រពន្ធទំនុកបម្រុងកូនៗ និងចាស់ៗនៅក្នុងគ្រួសារ។ ព.ស. បានពន្យល់ថា “គាត់បានរត់គេចខ្លួនជាមួយស្រីម្នាក់ទៅកាន់ព្រំដែនថៃ ហើយមិនបានត្រឡប់មកវិញឡើយ។ កូនរបស់យើងបានសម្លឹងមើលឪពុកកូនគេផ្សេងទៀតដែលបានត្រឡប់មកវិញមករកពួកគេ ប៉ុន្តែប្តីរបស់ខ្ញុំមិនបានត្រឡប់មករកពួកយើងវិញទេ”[102]។ ហ.អ. បានរៀបរាប់អំពីអាពាហ៍ពិពាហ៍ដែលប្តីរបស់នាងមានប្រពន្ធច្រើនថា៖

*“យើងចែកផ្លូវគ្នានៅពេលដែលប្តីរបស់ខ្ញុំចូលធ្វើទាហាន។ គាត់បានឈរជើងនៅទីរួមខេត្តកំពត ហើយគាត់បានដេកជាមួយស្រី។ គាត់មានស្រីច្រើនណាស់។ នៅពេលដែលគាត់រកលុយបានខ្លះ គាត់បានរៀបការប្រពន្ធម្នាក់ទៀត ហើយទុកឱ្យខ្ញុំនៅផ្ទះមើលថែរក្សាម្តាយក្មេក។ យើងក៏មានកូនបីនាក់ដែរ។ ខ្ញុំបានដឹងអំពីអាពាហ៍ពិពាហ៍នោះ ព្រោះនៅខេត្តកំពត បញ្ហានេះមិនអាចលាក់ជិតទេ។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីនោះទេ។ ខ្ញុំមិនអាចចេញពីផ្ទះដើម្បីទៅរកប្តីរបស់ខ្ញុំបានឡើយ ពីព្រោះខ្ញុំមានផ្ទះសម្បែង មានកូន និងមានគោដែលត្រូវមើលថែ។ នៅពេលដែលខ្ញុំដឹងដំណឹងថាគាត់រៀបការ ខ្ញុំមានតែនៅផ្ទះ គ្មានធ្វើអ្វីទាំងអស់។ នៅពេលដែលគាត់គិតអំពីខ្ញុំ គាត់នឹងត្រឡប់មកវិញហើយ តាមខ្ញុំគិត ... គាត់មានប្រពន្ធច្រើនប្រពន្ធមួយហ្វូង។ ទីបំផុត ខ្ញុំបានទៅដល់កន្លែងដែលគាត់បានរៀបការ។ ខ្ញុំបានជិះរថភ្លើងទៅ។ កូនស្រី*

---

[99] ដូចឯកសារខាងលើ។

[100] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

[101] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

[102] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*ច្បងរបស់ខ្ញុំអាយុប្រហែល ១០ឆ្នាំ។ ខ្ញុំបានជួបនឹងមេរបស់គាត់ ហើយបានប្ដឹងឱ្យបញ្ឈប់អាពាហ៍ពិពាហ៍នោះ ដោយនិយាយថា គាត់នឹងមិនអាចបំពេញកាតព្វកិច្ចរបស់គាត់ចំពោះខ្ញុំបានឡើយ។ នៅព្រឹកថ្ងៃរៀបការនោះ មេរបស់គាត់បានយកគាត់ទៅបន្ទាយ និងមិនអនុញ្ញាតឱ្យគាត់ចូលរោងការឡើយ ដូច្នេះប្រពន្ធរបស់គាត់ក៏បានរៀបការជាមួយខោអាវរបស់គាត់ជំនួសវិញទៅ[103] ... បានមួយខែក្រោយមក គាត់នៅតែមិនទាន់ត្រឡប់មកផ្ទះវិញទៀត គាត់ខឹងនឹងខ្ញុំដែលបានបញ្ឈប់មិនឱ្យគាត់រៀបការ។ ខ្ញុំបានរង់ចាំរយៈពេលមួយខែ បន្ទាប់មកខ្ញុំបានសុំឪពុកម្ដាយក្មេករបស់ខ្ញុំចាកចេញទៅរស់នៅជាមួយម្ដាយរបស់ខ្ញុំវិញ។ ខ្ញុំមានកូនបីនាក់ ហើយគ្មាននរណាម្នាក់ជួយខ្ញុំចិញ្ចឹមពួកគេឡើយ។ ខ្ញុំបានសាងសង់ផ្ទះដែលយើងរស់នៅនោះ ដូច្នេះនៅពេលដែលខ្ញុំចាកចេញ ខ្ញុំបានរុះរើផ្ទះនោះ ហើយយកវាជាមួយខ្ញុំ[104] ... [ក្រោយមក] មានបុរសផ្សេងម្នាក់ទៀតបានសុំខ្ញុំរៀបការ ប៉ុន្តែខ្ញុំមិនបានយល់ព្រមទេ ខ្ញុំបានសម្រេចចិត្តដោយខ្លួនឯង ហើយខ្ញុំតាំងចិត្តហើយថា ខ្ញុំមិនរៀបការម្ដងទៀតទេ។ ខ្ញុំឆ្អែតលែងចង់ហើយក្នុងមួយជីវិតរបស់ខ្ញុំ បន្ទាប់ពីឆ្លងកាត់រឿងរ៉ាវជាមួយប្ដីដំបូងរបស់ខ្ញុំ ដែលខ្ញុំត្រូវធ្វើការ និងចិញ្ចឹមកូនតែម្នាក់ឯង ហើយជីវិតខ្ញុំនៅពេលនោះលំបាកណាស់[105]។*

ថ្វីបើការសម្រេចចិត្តនោះ គឺជាអ្វីដែលផ្ដល់អំណាចដើម្បីអះអាងពីការពឹងផ្អែកលើខ្លួនឯងយ៉ាងណាក៏ដោយ ក៏ជីវិតរបស់ ហ.អ. និងកូនរបស់នាងបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែរ ដោយសារតែប្ដីរបស់នាងបោះបង់នាងចោល និងការលែងលះរបស់នាងនៅទីបំផុត។ នាងបានរៀបរាប់ពីទុក្ខលំបាកជាច្រើនដែលនាងបានប្រឈមថា៖

*"នៅរដូវវស្សា នៅពេលដែលខ្ញុំកំពុងធ្វើការនៅស្រែ ខ្ញុំគ្មានប្ដីជួយ [ជាមួយនឹងការងារប្រើកម្លាំងពលកម្មធ្ងន់ៗ] ឡើយ។ ខ្ញុំមានកូនតូចៗ ហើយខ្ញុំត្រូវចេញទៅស្រែ និងធ្វើស្រែ។ នៅពេលនោះ យើងមានក្របី ដូច្នេះខ្ញុំត្រូវមើលថែក្របីនៅពេលយប់ទៀត។ នៅពេលដែលខ្ញុំមកដល់ផ្ទះវិញ កូនរបស់ខ្ញុំបានដេកលក់អស់ទៅហើយ។ វាយប់ជ្រៅណាស់ទៅហើយ ទម្រាំដល់ខ្ញុំដាំស្លរួចនោះ"[106]។*

---

[103] ការអនុវត្តរបស់ប្រជាជនខ្មែរអនុញ្ញាតឱ្យមានអាពាហ៍ពិពាហ៍កំបាំងមុខ។

[104] សូមមើល Bricknell "ចានក្នុងរាវ" អំពីស្ត្រីដែលរុះរើផ្ទះដោយកម្លាំងកាយនៅពេលលែងលះគ្នា។

[105] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

[106] ដូចឯកសារខាងលើ។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ការរៀបការម្ដងទៀត និងជាពិសេសសម្រាប់ស្ត្រី សម្ពាធដែលត្រូវរៀបការម្ដងទៀតបន្ទាប់ពីបែកបាក់អាពាហ៍ពិពាហ៍ដោយបង្ខំ គឺមានយ៉ាងច្បាស់ដូចដែលបានរៀបរាប់ក្នុងបទសម្ភាសន៍ដូចនោះដែរ។ ករណីសិក្សាប្រាំក្នុងចំណោមករណីសិក្សាប្រាំបី បានរៀបការម្ដងទៀតនៅក្រោយការដួលរលំនៃរបបនោះ ដោយរួមទាំងអ្នកផ្ដល់បទសម្ភាសន៍ជាបុរស (ករណីសិក្សាទី ១) និងស្ត្រីដែលត្រូវបានគេចាត់ទុកថាជាទាសករផ្លូវភេទ (ករណីសិក្សាទី ២)។ នេះបង្ហាញថា ការរំពឹងទុក និងទំនុកចិត្តខាងវប្បធម៌នៅក្នុងការផ្ដួចផ្ដើមឲ្យមានអាពាហ៍ពិពាហ៍នៅតែខ្លាំងដដែល ក្រោយពីការដួលរលំនៃរបបនេះ ជាពិសេសដោយសារតែវាពាក់ព័ន្ធនឹងការអនុវត្តរបស់ក្រុមគ្រួសារ និងពិធីសាសនា។ ការរៀបការម្ដងទៀតក៏អាចបម្រើឲ្យមានការកែតម្រូវ ឬយ៉ាងហោចណាស់កែបំបាត់ភាពអាម៉ាស់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ ជាពិសេសនៅពេលដែលពិធីជាប្រពៃណីត្រូវបានគេគោរពតាម បើយោងតាមអ្នកផ្ដល់បទសម្ភាសន៍។

ទោះជាយ៉ាងណា ការរំពឹងទុកលើការរៀបការម្ដងទៀតនៅក្រោយរបបនេះត្រូវបានរងផលប៉ះពាល់ដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំអំឡុងពេលនៃរបបនោះ ជាពិសេសសម្រាប់ស្ត្រី ដោយបង្ហាញថា *ច្បាប់ស្រី* បានបន្តមានឥទ្ធិពលលើរបៀបដែលគេឲ្យតម្លៃលើស្ត្រី ដោយផ្អែកលើភាពបរិសុទ្ធខាងផ្លូវភេទ និងការចុះសម្រុងយ៉ាងស្អិតរមួតក្នុងក្រុមគ្រួសារ។ ដូចដែលបានរៀបរាប់នៅក្នុងបទសម្ភាសន៍ ស្ត្រីបានប្រឈមនឹងចំណងពីរជាន់៖ ក្លាយជាស្ត្រីដែលគ្មានប្ដីជាថ្មីបន្ទាប់ពីបានរៀបការដោយបង្ខំ ឬមាន "ប្ដីច្រើនពេក" ដោយការរៀបការម្ដងទៀត។ បុរស ដែលឈរលើស្តង់ដារយេនឌ័រខុសគ្នា និងស្ថានភាពដែលគេផ្ដល់ឲ្យខាងលើ និងក្រៅអាពាហ៍ពិពាហ៍ មិនបានប្រឈមនឹងផលប៉ះពាល់ដូចគ្នានេះទេ បើយោងតាមបទសម្ភាសន៍។ ទំនាក់ទំនងនៃការមានប្រពន្ធច្រើនបានបង្ហាញពីភាពទ្រាំទ្របានរបស់បុរសក្នុងការមានប្រពន្ធច្រើន បន្តគ្នា ឬដំណាលគ្នា ដោយគ្មានការភ័យខ្លាចថានឹងត្រូវគេមាក់ងាយ ឬអាប់អោនអនាគតនោះទេ។ "អតិរេក" របស់ស្ត្រីច្រើនជាងបុរសនៅពេលនោះក៏បានផ្ដល់គុណប្រយោជន៍បន្ថែមទៀតឲ្យបុរស នៅលើទីផ្សារនៃការរៀបការម្ដងទៀតផងដែរ។

ការមាក់ងាយ ជាពិសេសមកលើស្ត្រី គឺខ្លាំងក្លាណាស់ជុំវិញអាពាហ៍ពិពាហ៍ដោយបង្ខំដែលបែកបាក់។ បើទោះបីអាពាហ៍ពិពាហ៍ដែលបែកបាក់ទាំងនេះបានកើតឡើងក្នុងចំនួនយ៉ាងច្រើនក៏ដោយ ក៏អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានចាត់ទុកនៅក្នុងបទសម្ភាសន៍ជាមួយស្ត្រីថាជាអាពាហ៍ពិពាហ៍ដ៏អន់៖ ពួកគេបានដកចេញទាំងការអនុញ្ញាតពីសំណាក់ឪពុកម្ដាយ ព្រមទាំងសុពលភាពនៃទំនៀមទម្លាប់ និងទាំងភាពស្របច្បាប់ដែលត្រូវប្រគល់ដោយពិធីប្រពៃណី។ ប្រការនេះបានជះផលប៉ះពាល់អវិជ្ជមានមួយ ជាពិសេសនៅពេលដែលអាពាហ៍ពិពាហ៍ដោយបង្ខំនេះបានបែកបាក់។ កេរ្តិ៍ឈ្មោះរបស់ក្រុមគ្រួសារបានប្រឈមនឹងការបាត់បង់ ហើយមិនដូច

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

អាពាហ៍ពិពាហ៍ដែលគេរៀបចំតាមប្រពៃណីនោះទេ ក្រុមគ្រួសារមិនត្រូវបានរាប់បញ្ចូលជាបណ្ដាញសុវត្ថិភាពឡើយ ប្រសិនបើមានការបែកបាក់ចំណងអាពាហ៍ពិពាហ៍។ ក.ន. បានពន្យល់ពីរបៀបដែលអាពាហ៍ពិពាហ៍ដោយបង្ខំរបស់នាងជាមួយប្ដីដែលរំលោភបំពានម្នាក់ (ដែលនាងបានលែងលះគ្នានៅឆ្នាំ ២០០៦) បានប៉ះពាល់ដល់អនាគតរបស់នាងនៅពេលក្រោយមកទៀតក្នុងជីវិតថា៖

> *"ដោយសារតែអាពាហ៍ពិពាហ៍ដោយបង្ខំនេះហើយ ទើបខ្ញុំមិនអាចរៀបការជាមួយបុរសដែលល្អជាងនេះបាន។ ខ្ញុំមិនបានរៀបការម្ដងទៀតឡើយបន្ទាប់ពីលែងលះហើយ ព្រោះខ្ញុំខ្លាចថាប្ដីក្រោយរបស់ខ្ញុំនឹងធ្វើបាបខ្ញុំម្ដងទៀត ហើយប្រហែលជាមិនល្អចំពោះកូនរបស់ខ្ញុំដែរ។ ខ្ញុំដឹងថា ក្នុងករណីនេះ ខ្ញុំអាចជ្រើសរើសបានដោយខ្លួនឯង ហើយម្ដាយរបស់ខ្ញុំក៏អាចរៀបចំមង្គលការឱ្យខ្ញុំបានដែរ។ ខ្ញុំក៏មានការខកចិត្តដែរដោយសារតែខ្ញុំមិនបានធ្វើពិធីដូចពេលបច្ចុប្បន្ន។ ខ្ញុំកាន់តែខកចិត្តទៅទៀតដែលប្ដីរបស់ខ្ញុំបានប្រែក្លាយទៅជាមនុស្សឃោរឃៅបែបនោះ ប៉ុន្តែ ខ្ញុំមិនអាចខឹងនឹងម្ដាយរបស់ខ្ញុំបានទេ ព្រោះគាត់មិនមែនជាអ្នកផ្សំផ្គុំគូឱ្យខ្ញុំនោះទេ។ ខ្ញុំខឹងនឹង ប៉ុល ពត ហើយខ្ញុំគិតថា អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមរបបខ្មែរក្រហមគឺជាបទឧក្រិដ្ឋដ៏អាក្រក់ខ្លាំងណាស់"*[107] ។

ព.ស. ដែលត្រូវបានគេបង្ខំឱ្យរៀបការដោយភ្ជុងនឹងកាំភ្លើងក្នុងនាមជាកូនក្រមុំក្មេងម្នាក់ ហើយបន្ទាប់មកត្រូវបានរំលោភយ៉ាងព្រៃផ្សៃដោយប្ដីរបស់នាង ដោយមានជំនួយពីអ្នកយាមរបស់ពួកខ្មែរក្រហមបានរំលឹកដល់ការរើសអើងដែលនាងបានប្រឈម នៅពេលដែលនាងព្យាយាមរៀបការម្ដងទៀតក្រោយពេលរបបខ្មែរក្រហមដួលរលំទៅ។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា នាងក៏បានគូសបញ្ជាក់ពីការដាក់សម្ពាធពីសហគមន៍ដើម្បីកែតម្រូវស្ថានភាពដែលរងការខូចខាតនៃ "ស្ត្រីមេម៉ាយ" ក្រោយពីបានរៀបការដោយបង្ខំតាមរយៈពិធីមង្គលការដែលត្រឹមត្រូវមួយថា៖

> *"ខ្ញុំបានសម្រេចចិត្តរៀបការម្ដងទៀតនៅពេលដែលខ្ញុំបានលឺថា មនុស្សចាស់ៗនៅក្នុងភូមិមកប្រាប់ម្ដាយរបស់ខ្ញុំថា ខ្ញុំគួរតែមានមង្គលការតាមប្រពៃណី ... នៅពេលដែលរបបនោះបានបញ្ចប់ទៅ មានបុរសម្នាក់បានស្រឡាញ់ខ្ញុំ។ យើងបានស្រឡាញ់គ្នាទៅវិញទៅមក។ ដូច្នេះ គាត់បានសុំឱ្យម្ដាយរបស់គាត់ឱ្យចូលមកនិយាយជាមួយម្ដាយរបស់ខ្ញុំ។ នៅពេលដែលគាត់មក គាត់បានខ្សឹបប្រាប់កូនប្រុសរបស់គាត់ថា "អា នាងធ្លាប់រៀបការរួចហើយក្នុងអំឡុងរបបខ្មែរក្រហមណាកូន។ នាងជាស្ត្រីមេម៉ាយ*

---

[107] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៨, ស្រីជនជាតិខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

*ដូច្នេះ ម៉ែមិនយល់ព្រមឲ្យកូនរៀបការជាមួយនាងទេ"។ គាត់បានព្យាយាមបញ្ចុះបញ្ចូលម្ដាយរបស់គាត់ថា គាត់មិនខ្វល់នោះទេថាតើខ្ញុំជាស្ត្រីមេម៉ាយ ឬមិនមែននោះ។ គាត់ចង់រៀបការជាមួយខ្ញុំ។ ម្ដាយរបស់គាត់នៅតែមិនយល់ព្រម ដូច្នេះ គាត់ក៏បានសុំឲ្យខ្ញុំលួចរត់ទៅរៀបការជាមួយគ្នា។ ខ្ញុំបានគិតថា ក្នុងអំឡុងរបបខ្មែរក្រហម ខ្ញុំបានរងគ្រោះច្រើនមកហើយ ហើយឥឡូវខ្ញុំមិនគួរលួចរត់ទៅរៀបការនោះទេ ព្រោះវានឹងបំផ្លាញកេរ្តិ៍ឈ្មោះរបស់គ្រួសារខ្ញុំ។ បន្ទាប់មក គាត់ក៏បានរៀបការជាមួយស្ត្រីម្នាក់ផ្សេងទៀតទៅ។ ខ្ញុំបានត្រឹមតែយំម្នាក់ឯង"[108] ។*

ដោយត្រូវបានកំណត់ថាជា "ទំនិញខូចខាត" ដោយសារតែការរៀបការ (ដោយបង្ខំ) លើកទីមួយ ព. ស. នៅទីបំផុតបានរៀបការម្ដងទៀតជាមួយប្ដីដែលរំលោភបំពាន។ នាងបានរៀបរាប់ពីរបៀបដែលគោលការណ៍នៃ*ច្បាប់ស្រីប្រកាន់តឹងរឹងប៉ុណ្ណាក្នុងការស៊ូទ្រាំនឹងការរំលោភបំពានដោយស្ងាត់ស្ងៀម* ដើម្បីការពារកិត្តិយសគ្រួសារជាជាងការស្វែងរកការលែងលះគ្នាជាលើកទីពីរថា៖

*"បន្ទាប់ពីនោះមក ខ្ញុំបានតាំងចិត្តថាមិនឲ្យនរណាម្នាក់ដឹងអំពីអាពាហ៍ពិពាហ៍លើកទីមួយរបស់ខ្ញុំនោះទេ។ សូម្បីតែកូនរបស់ខ្ញុំក៏មិនដឹងដែរ ... ក្រោយមក ពេលដែលវៀតណាមបានដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា មានទាហានម្នាក់បានស្រឡាញ់ខ្ញុំ។ ម្ដាយឪពុករបស់គាត់បានមកនិយាយគ្នាជាមួយម្ដាយរបស់ខ្ញុំ។ គាត់ក៏ជាបុរសពោះម៉ាយម្នាក់ដែរ ហើយមានកូនម្នាក់។ ដូច្នេះ ខ្ញុំសន្មត់ថាដោយសារតែយើងជាស្ត្រីមេម៉ាយ និងបុរសពោះម៉ាយដូចគ្នា គាត់ប្រហែលជាមិនមើលងាយខ្ញុំនោះទេ។ គាត់មិនបានដឹងពីអ្វីដែលបានកើតឡើងចំពោះខ្ញុំក្នុងអំឡុងរបបខ្មែរក្រហមនោះទេ ហើយគាត់ក៏មិនបានសួរដែរ។ ប៉ុន្តែ ជីវិតនោះគឺមិនល្អទេ។ គាត់មានស្រីច្រើនណាស់។ គាត់បានវាយដំខ្ញុំ។ គាត់បានបង្ខំខ្ញុំឲ្យរួមភេទជាមួយគាត់ ដែលជាទម្លាប់របស់មនុស្សប្រុស ហើយ [ក្នុងនាមជាប្រពន្ធរបស់គាត់] ខ្ញុំគ្មានសិទ្ធិនិយាយថាទេ ឬសម្រេចចិត្តអ្វីនោះឡើយ។ សម្រាប់ខ្ញុំ ខ្ញុំគ្រាន់តែចង់បានគ្រួសារមួយដែលមានសុភមង្គល ដូច្នេះ ខ្ញុំមិននិយាយអ្វីទាំងអស់អំពីរឿងនោះ។ ខ្ញុំបានព្យាយាម រកលុយសម្រាប់ឲ្យកូនទៅសាលារៀន។ សម្រាប់គាត់ គាត់មិនបានជួយរកប្រាក់ចំណូលនោះឡើយ។ គាត់បានមកលេង ហើយស្នាក់នៅ ហើយក៏ចាកចេញទៅបាត់។*

---

[108] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*ខ្ញុំគិតថា ប្តីដែលខ្ញុំមានពីរបបខ្មែរក្រហមខុសហើយ ដោយសារយើងមិនបានស្រឡាញ់គ្នា ហើយមិនបានព្រមព្រៀងជាមួយគ្នា។ ពេលដែលខ្ញុំបានរៀបការម្តងទៀត ខ្ញុំបានព្រមព្រៀង ដោយផ្អែកលើការសម្រេចចិត្តរបស់ខ្ញុំផ្ទាល់ ហើយឪពុកម្តាយរបស់ខ្ញុំក៏បានព្រមព្រៀងផងដែរ។ ប្រសិនបើខ្ញុំចង់លែងលះគ្នាម្តងទៀត នោះវានឹងបំផ្លាញកេរ្តិ៍ឈ្មោះរបស់ខ្ញុំ។ ប្រសិនបើខ្ញុំរត់ចេញឲ្យឆ្ងាយពីគាត់ ខ្ញុំនឹងមានអារម្មណ៍អាម៉ាស់ចំពោះអ្នកផងឯទៀតជាថ្មីម្តងទៀត។ ដូច្នេះ ខ្ញុំបានស៊ូទ្រាំ។ ខ្ញុំមានកូន ហើយបើខ្ញុំចាកចេញ តើខ្ញុំគួរទៅកន្លែងណា? ភាពអាម៉ាស់ពីរបបខ្មែរក្រហម គឺនៅតែមានដដែល ហើយបើខ្ញុំចាកចេញពីប្តីម្នាក់នេះទៀត តើអ្នកផ្សេងនឹងវិនិច្ឆ័យខ្ញុំថាជាមនុស្សស្រីរបៀបណា? ខ្ញុំបានគិតច្រើនណាស់ ហើយខ្ញុំក៏ជាមនុស្សដែលមិនបានរៀនសូត្រទៀត។ ខ្ញុំបានព្យាយាមប្រឹងប្រែងធ្វើការ និងស៊ូទ្រាំនៅជាមួយគាត់ ដូច្នេះកូនរបស់ខ្ញុំអាចមានឪពុកម្នាក់ដែរ ... ខ្ញុំមានកូនប្រាំមួយនាក់ជាមួយគាត់ និងកូនចិញ្ចឹមម្នាក់”*[109] ។

មរតករបស់ខ្មែរក្រហម រួមទាំងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ដូចជាការរំលោភសេពសន្ថវៈ និងអាពាហ៍ពិពាហ៍ដោយបង្ខំ បាននៅជាប់ជាមួយស្ត្រីក្នុងរយៈពេលដ៏យូរបន្ទាប់ពីរបបនោះបានដួលរលំទៅ។ ចំពោះស្ត្រីដែលមិនទាន់រៀបការ ឬអ្នកដែលគេបានបោះបង់ចោលទាំងឡាយបន្ទាប់ពីរបបនោះ ពួកគេជាញឹកញាប់បានបន្តរស់នៅក្នុងវប្បធម៌នៃការរំលោភសេពសន្ថវៈ និងនិទណ្ឌភាព។ ត្រឡប់ទៅរឿងរបស់ ច.ព. ដែលបានទទួលរងនូវការរំលោភជាក្រុម និងការវាយដំប្រចាំថ្ងៃដោយពួកកម្មាភិបាល និងការរំលោភរៀងរាល់យប់ដោយមន្ត្រីខ្មែរក្រហមម្នាក់ នាងបានលើកឡើងថា នាងមានជម្រើសតិចតួចណាស់នៅក្នុងរៀបការម្តងទៀតសម្រាប់ការពារខ្លួនឯង។ នៅពេលវិលត្រឡប់ទៅភូមិរបស់នាងបន្ទាប់ពីការដួលរលំនៃរបបនោះវិញ នាងបានរៀបរាប់ថា នាងត្រូវបានគេយាយីផ្លូវភេទ និងចាប់រំលោភម្តងហើយម្តងទៀត ក្នុងនាមជាស្ត្រីមិនទាន់រៀបការដែលជំរុញឲ្យនាងរៀបការម្តងទៀត៖

*“ជីវិតនៅពេលនោះគឺលំបាកខ្លាំងណាស់។ បុរសដែលបានរៀបការរួចបានមកដល់ផ្ទះរបស់ខ្ញុំនៅពេលយប់ ហើយរំខានខ្ញុំ លូកលាន់ខ្ញុំ ព្យាយាមបញ្ចុះបញ្ចូលខ្ញុំឲ្យរួមភេទជាមួយពួកគេ។ ពេលខ្លះ នៅពេលដែលខ្ញុំទៅទីផ្សារ ឬចូលរួមក្នុងពិធីណាមួយនៅក្នុងភូមិនោះ ពួកគេបានមករាំងផ្លូវខ្ញុំ ហើយព្យាយាមអោបខ្ញុំ និងប៉ះពាល់ខ្ញុំ ហើយខ្ញុំបានព្យាយាមរត់គេចខ្លួន។ ខ្ញុំបានប្រាប់ម្តាយ និងសាច់ញាតិរបស់ខ្ញុំ*

[109] ដូចឯកសារខាងលើ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

*ហើយពួកគេឱ្យយោបល់ខ្ញុំថាឱ្យខ្ញុំរៀបការជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំទៅ។ ខ្ញុំបានយំហាក់ដូចជាកំពុងតែស្ថិតក្នុងរបបខ្មែរក្រហមដូចនោះដែរ ... ខ្ញុំយំព្រោះខ្ញុំអាណិតខ្លួនឯង ... ជីវិតរបស់ខ្ញុំសែនវេទនាណាស់។ ខ្ញុំបានប្រាប់ប្រពន្ធរបស់មនុស្សប្រុសទាំងនោះថា ខ្ញុំមិនបានស្រឡាញ់ប្តីរបស់គេនោះទេ ហើយខ្ញុំបានសុំអង្វរឱ្យពួកគេឃ្លាំមើលប្តីរបស់ពួកគេកុំឱ្យមករំខានខ្ញុំទៀត។ ប្អូនស្រីរបស់ខ្ញុំបានឱ្យយោបល់ខ្ញុំថាឱ្យខ្ញុំរៀបការទៅប្រសិនបើមាននរណាម្នាក់មកចូលស្តីខ្ញុំនោះ ព្រោះជីវិតរបស់ខ្ញុំគឺវេទនាណាស់។ ខ្ញុំបានសម្រេចចិត្តរៀបការជាថ្មីម្តងទៀតដើម្បីឱ្យមាននរណាម្នាក់ការពារខ្ញុំ និងដើម្បីគេចពីមនុស្សប្រុសទាំងនោះដែលព្យាយាមចាប់រំលោភខ្ញុំ។ ប្រសិនបើមិនមែនដោយសារតែដូច្នោះ ខ្ញុំក៏មិនរៀបការម្តងទៀតដែរ ព្រោះខ្ញុំមិនចង់ឱ្យមនុស្សម្នានិយាយថា ខ្ញុំមានប្តីច្រើននោះទេ។ ប៉ុន្តែបងប្អូនបង្កើតរបស់ខ្ញុំមិនអាចការពារខ្ញុំបានទេនៅពេលយប់ នៅពេលដែលមានមនុស្សប្រុសមកព្យាយាមរំលោភខ្ញុំនោះ”[110] ។*

ហ.អ. មិនដែលបានរៀបការម្តងទៀតឡើយ បន្ទាប់ពីត្រូវប្តីដែលបានរៀបការដោយបង្ខំរបស់នាងបោះបង់នាងចោលមក ហើយនាងអាចនឹងជ្រើសរើសយកឯករាជ្យភាព និងភាពជាម្ចាស់ការលើខ្លួនឯងសម្រាប់ខ្លួនឯងផ្ទាល់ និងកូនរបស់នាងជំនួសវិញ។ នាងបានរៀបរាប់ថា គ្មានគោលនយោបាយជាតិណាដែលផ្តោតទៅលើការផ្តល់ការគាំទ្រដល់នាង ចំពោះផលវិបាកខាងសង្គម និងសេដ្ឋកិច្ចដែលខ្លួនបានជួបប្រទះដោយអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានបរាជ័យទៅហើយនេះឡើយ។

*“សម្រាប់ខ្ញុំ ការមានប្តីគ្មានប្រយោជន៍អ្វីនោះទេ។ ខ្ញុំមិនចង់មានប្តីពីរនោះទេ ... ប្តីដំបូងរបស់ខ្ញុំគឺខុសទៅហើយ ដូច្នេះខ្ញុំមិនចង់ធ្វើខុសជាលើកទីពីរទៀតនោះទេ ហើយខ្ញុំក៏ខ្លាចថា គាត់អាចនឹងមិនចិត្តល្អជាមួយកូនៗរបស់ខ្ញុំដែរ។ ខ្ញុំរកស៊ីដោយខ្លួនឯង ហើយខ្ញុំសម្រេចចិត្តថានឹងចំណាយ និងផ្តល់ឱ្យកូនៗរបស់ខ្ញុំច្រើនប៉ុណ្ណាតាមដែលខ្ញុំចង់ គ្មាននរណាម្នាក់ត្រួតត្រាលើអ្វីដែលខ្ញុំធ្វើ ឬសម្រេចចិត្តនោះឡើយ។ ខ្ញុំរកស៊ី និងសម្រេចចិត្តលើអ្វីៗគ្រប់យ៉ាងដោយខ្លួនឯង ហើយរបៀបនេះគឺវាងាយស្រួលជាងសម្រាប់ខ្ញុំ”[111] ។*

---

[110] បទសម្ភាសន៍ជាមួយករណីសិក្សាទី ២, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

[111] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ជាសង្ខេប អាពាហ៍ពិពាហ៍ដែលបានរៀបចំដោយពួកខ្មែរក្រហមបានបន្តមានផលប៉ះពាល់ដដែល សូម្បីតែក្រោយពីការដួលរលំនៃរបបនោះក្តី និងជាការពិតសូម្បីតែនៅពេលឈានចូលក្នុងអំឡុងពេលនៃការអភិវឌ្ឍនៅទសវត្សរ៍ឆ្នាំ ២០០០ រហូតដល់សព្វថ្ងៃ បើយោងតាមបទសម្ភាសន៍។ គូស្វាមីភរិយាមួយចំនួននៅតែរួមរស់នៅជាមួយគ្នាដោយសារក្តីស្រឡាញ់ ដើម្បីជាប្រយោជន៍ដល់កូន ឬក្នុងន័យជាកាតព្វកិច្ច។ អាពាហ៍ពិពាហ៍ផ្សេងទៀតបានបែកបាក់ដោយសារមរណភាព ការលែងលះគ្នា ឬបោះបង់គ្នាចោល។ អាពាហ៍ពិពាហ៍ដែលមិនបែកបាក់ សូម្បីតែមួយរយៈពេលក៏ដោយ គឺទំនងជាអាពាហ៍ពិពាហ៍ដែលមានការរំលោភបំពាន បើយោងតាមបទសម្ភាសន៍ករណីសិក្សា (និងត្រូវបានផ្តល់សុពលភាពដោយលទ្ធផលនៃការសិក្សាបែបបរិមាណវិស័យ)។ សម្រាប់ស្ត្រីដែលជាមេគ្រួសារ ផលវិបាកខាងសេដ្ឋកិច្ច និងសង្គមគឺខ្ពស់ ប៉ុន្តែមិនមែនមិនអាចជំនះបាននោះទេ ដោយសារតែភាពខ្លាំង និងភាពក្លៀវក្លារបស់ស្ត្រីខ្លួនឯង។

**ឃ. ផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ**

ទាំងបុរស និងស្ត្រីគឺជាជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំក្រោមរបបខ្មែរក្រហម។ អ្នកផ្តល់បទសម្ភាសន៍ជាស្ត្រី ជាពិសេស បានលើកឡើងពីរបៀបដែលគោលនយោបាយទាំងនេះ បន្ទាប់ពីការដួលរលំនៃរបបនេះ បាននាំឱ្យមានការអាម៉ាស់ និងការរើសអើង ជាមួយនឹងផលវិបាកនៃកម្មចំពោះពុទ្ធសាសនិក។ ផ្ទុយមកវិញ បុរសត្រូវបានគេចាត់ទុកថាមិនត្រូវបានកំណត់ដោយសង្គមតាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ហើយបុរសទំនងជារួចផុតពីការដកចេញពីសង្គមដែលកើតមានដោយការមាក់ងាយ និងការរើសអើងដែលបានលើកឡើងដោយអ្នកផ្តល់បទសម្ភាសន៍ជាស្ត្រី។

ការខកចិត្ត គឺជាការឆ្លើយតបខាងផ្លូវអារម្មណ៍ទូទៅរបស់អ្នកផ្តល់បទសម្ភាសន៍ករណីសិក្សា ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេ ពោលគឺខកចិត្តដែលបានបាត់បង់ឱកាសក្នុងការដាក់ការគ្រប់គ្រងលើការសម្រេចចិត្តដ៏ធំមួយក្នុងជីវិត ដូចជាអាពាហ៍ពិពាហ៍ជាដើម និងមិនបានឱ្យក្រុមគ្រួសារ និងជីដូនជីតាផ្តល់សុពលភាព និងបំពេញឱ្យត្រឹមត្រូវតាមច្បាប់លើការសម្រេចចិត្តដ៏ធំក្នុងជីវិតនោះ។ ពិធីមង្គលការត្រូវបានគេចាត់ទុកថា "គ្មានន័យ" ដោយសារតែមិនមានពិធីតាមប្រពៃណី វប្បធម៌ និងសាសនាឡើយ។ ក្នុងករណីជាច្រើន ការខ្វះអត្ថន័យនេះបានគ្របដណ្តប់លើអាពាហ៍ពិពាហ៍ទាំងមូលតែម្តង។ ហ.អ. ដែលត្រូវបានបោះបង់ចោលដោយប្តីនៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់នាងបានចែករំលែកថា៖

*"នៅក្នុងរបបខ្មែរក្រហម អាពាហ៍ពិពាហ៍គ្មានន័យអ្វីនោះទេ ដោយសារតែយើងគ្មានផ្កាស្លា គ្មានអាចារ្យ គ្មានចាស់ទុំដែលទទួលស្គាល់អាពាហ៍ពិពាហ៍របស់យើងនោះទេ។ យើងរៀបការដោយគ្រាន់តែនិយាយ*

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*មួយពាក្យ ឬពីរពាក្យប៉ុណ្ណោះ គ្មានន័យអ្វីទាំងអស់ ... វាគ្មានអ្វីទាំងអស់។ ស្វាមីភរិយា ៥០ ទៅ ៦០ គូ រៀបការជាមួយគ្នានៅពេលតែមួយ ក្នុងពិធីមង្គលការតែមួយ ហើយគ្រាន់តែនិយាយពាក្យពីរបីម៉ាត់ តើបែបនោះមានន័យដែរឬ"*[112]?

អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានគេចាត់ទុកជា "អាពាហ៍ពិពាហ៍ដ៏អាក្រក់" ជាក់ស្តែង ដែលហាក់ដូចជាស្របច្បាប់ ព្រោះពិតជាគ្មានការរាប់បញ្ចូលឪពុកម្តាយ និងដោយគ្មានសុពលភាពដោយពិធីតាមវប្បធម៌អ្វីទាំងអស់។ ដូច្នេះ ការយល់ព្រមទទួលយកអាពាហ៍ពិពាហ៍បែបនោះបានតំណាងឱ្យស្ថានភាពដែលពិបាកជ្រើសរើសនៃការប្រព្រឹត្តនូវទង្វើដែលមិនស្តាប់បង្គាប់។ ហ.អ. បានពន្យល់ថា "*អង្គការ*បានបង្ខំខ្ញុំឱ្យ ... ហើយបើឪពុកម្តាយរបស់ខ្ញុំដឹង ពួកគេនឹងស្តីបន្ទោសឱ្យខ្ញុំដោយសារតែពួកគេមិនបានដឹងអំពីអាពាហ៍ពិពាហ៍នេះ"[113]។ ការខកចិត្តដែលបានកប់ទុកក្នុងអាពាហ៍ពិពាហ៍ និងការស្តីបន្ទោសចំពោះការមិនស្តាប់បង្គាប់បានបណ្តាលឱ្យមានអារម្មណ៍ថាខ្លួនបរាជ័យ។ ហ.អ. បានបន្តទៀតថា៖

*"ខ្ញុំមានអារម្មណ៍ហាក់ដូចជា ជាមួយនឹងការប្តេជ្ញានេះ [ការប្តេជ្ញា ឬសម្បថ] គ្មាននរណាម្នាក់បានទទួលស្គាល់វានោះទេ ... ខ្ញុំមានអារម្មណ៍ខកចិត្តនឹងខ្លួនឯងណាស់ ខកចិត្តដែលខ្ញុំមិនបានរៀបការតាមធម្មតា ដែលឪពុកម្តាយរបស់ខ្ញុំមិនបានដឹងថាខ្ញុំរៀបការ បងប្អូនរបស់ខ្ញុំក៏មិនបានដឹងដែរ។ ខ្ញុំបានតែរៀបការដោយខ្លួនឯងប៉ុណ្ណោះ ក្នុងចំណោមក្រុមមនុស្សប្លែកមុខមួយក្រុម ដូច្នេះខ្ញុំមានការខកចិត្ត ... ប៉ុន្តែ ខ្ញុំបានយល់ព្រមរៀបការដើម្បីរស់"*។

អ្នកផ្តល់បទសម្ភាសន៍ករណីសិក្សាជាច្រើននាក់ ទាំងបុរស និងស្ត្រី មិនដែលបានចែករំលែកបទពិសោធន៍នៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួនជាមួយនឹងអ្នកដទៃឡើយ សូម្បីតែកូនៗរបស់ពួកគេផ្ទាល់។ ស.ប.ច. ដែលប្រពន្ធដែលគេចាត់តាំងឱ្យនោះបានចែកផ្លូវគ្នាជាមួយគាត់ភ្លាមៗក្រោយពីការដួលរលំរបបខ្មែរក្រហមទោះបីជានាងមានផ្ទៃពោះនៅពេលនោះក៏ដោយ បានលាក់ទុកបទពិសោធន៍របស់គាត់តែម្នាក់ឯងអស់រយៈពេលជិត ៤០ ឆ្នាំមកហើយ។ ពាក្យសម្តីរបស់គាត់គឺដូចគ្នានឹងចម្លើយតបរបស់អ្នកផ្តល់បទសម្ភាសន៍ផ្សេងដែរ៖ "ខ្ញុំមិនបានប្រាប់កូនរបស់ខ្ញុំណាម្នាក់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ព្រោះខ្ញុំមិនចង់ឱ្យពួកគេមាន

---

[112] ដូចឯកសារខាងលើ។

[113] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

អារម្មណ៍ថាមានកំហុស"[114]។ សម្ពាធនៃការលាក់ទុក "អាថ៌កំបាំងគ្រួសារ" បែបនោះអាចប៉ះពាល់ដល់ទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ព្រមទាំងដកចេញនូវអ្នកដែលនៅរស់រានមានជីវិតពីប្រភពដ៏សំខាន់មួយនៃការគាំទ្រផ្នែកផ្លូវអារម្មណ៍ និងផ្លូវចិត្ត។

ការប៉ះទង្គិចផ្លូវចិត្តដែលបណ្តាលមកពីអាពាហ៍ពិពាហ៍ដោយបង្ខំ បានជះផលប៉ះពាល់ដោយផ្ទាល់លើអត្តសញ្ញាណ និងការវាយតម្លៃយេនឌ័រ បើយោងតាមបទសម្ភាសន៍ករណីសិក្សាជាច្រើន។ វាហាក់ដូចជាថាស្ត្រី ជាពិសេស បានបៀមជាប់នូវក្តីអាម៉ាស់ និងការមាក់ងាយដែលគេបានផ្សារភ្ជាប់នឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានបកប្រែថាជាការធ្លាក់ចុះតម្លៃជាទូទៅនៃឋានៈក្នុងសង្គមរបស់ស្ត្រីបន្ថែមទៀត។ ព.ស. បានពន្យល់អំពីការប៉ះទង្គិចផ្លូវចិត្តជាហូរហែរដែលនាងបានជួបប្រទះថាជាលទ្ធផលមួយដែល៖

*"ខ្មែរក្រហមមិនឲ្យតម្លៃស្ត្រីឡើយ ពួកគេមិនចាត់ទុកស្ត្រីជាបងប្អូនស្រីរបស់ពួកគេ ជាម្តាយរបស់ពួកគេទេ ពួកគេមិនបានចាត់ទុកស្ត្រីថាជាមនុស្សមានតម្លៃក្នុងសង្គមឡើយ។ មនុស្សដែលបានរៀបការនៅសម័យនោះត្រូវបានគេចាត់ទុកដូចសត្វ។ យើងមិនអាចការពាររាងកាយ [កេរ្តិ៍ខ្មាស់] របស់យើងដូចដែលឪពុកម្តាយយើងធ្លាប់បានការពារឡើយ។ ខ្ញុំត្រូវបានគេរំលោភ ហើយពួកគេនៅមើលនៅទីនោះ ... យើងត្រូវបានគេបង្ខំឲ្យពាក់គ្នាដូចឆ្កែដូចឆ្មា។ ពេលដែលគេរំលឹកដល់បញ្ហានេះឲ្យខ្ញុំលឺ មាត់របស់ខ្ញុំប្រែទៅជាស្ងួត បេះដូងខ្ញុំលោតឡើងញាប់។ ចាសមែនហើយ [អាពាហ៍ពិពាហ៍នោះ] នៅតែជះផលប៉ះពាល់ដល់ខ្ញុំមកទល់នឹងពេលនេះ វាហាក់ដូចជាខ្ញុំស្លៀក "ខោរហែក" [សញ្ញានៃភាពអាម៉ាស់] ដូចនោះដែរ។ ខ្ញុំកម្រទៅផ្ទះអ្នកដទៃណាស់។ ខ្ញុំភាគច្រើននៅផ្ទះតែម្នាក់ឯង"[115]។*

អ្នកយាមពីរនាក់ដែលបានជួយក្នុងការចាប់រំលោភនោះនៅមានជីវិតរស់ដល់សព្វថ្ងៃ ព្រោះ ព.ស. ធ្លាប់ឃើញពួកគេម្តងនៅវត្តក្នុងភូមិនោះ ហើយដែលចាប់តាំងពីនោះមក នាងបានគេចមិនចូលកន្លែងនោះទៅថ្វាយឬបន់ស្រន់ដល់ព្រះពុទ្ធឡើយ។ នាងក៏ធ្លាប់បានជួបប្តីដែលគេបង្ខំឲ្យរៀបការនោះម្តងដែរ ដែលជាអ្នកដែលបានចាប់រំលោភនាងក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ ដែលកំពុងដើរឆ្លងផ្លូវជាមួយប្រពន្ធថ្មីរបស់គាត់។

---

[114] បទសម្ភាសន៍ជាមួយករណីសិក្សាទី ១, ប្រុស (ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤)។

[115] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

ភាពអាម៉ាស់ និងការស្ដីបន្ទោសដែលចោទដាក់លើជនរងគ្រោះ (ជាស្ត្រី) ដោយសហគមន៍ត្រូវបានគេលើកឡើងនៅក្នុងបទសម្ភាសន៍ភាគច្រើនជាមួយស្ត្រីនៅក្នុងគំរូ។ ព.ស. បានរៀបរាប់ថាតើការអាម៉ាស់បែបនោះ ដែលនៅពេលដែលកប់ទុកក្នុងចិត្ត បណ្ដាលឲ្យខ្លួនឯងមានភាពឯកោប៉ុណ្ណា។

*"ខ្ញុំមានអារម្មណ៍អាម៉ាស់ អាម៉ាស់ខ្លាំងណាស់ ហើយខ្ញុំមិនចង់ឲ្យនរណាម្នាក់ដឹងអំពីអតីតកាលរបស់ខ្ញុំទេ។ នៅពេលដែលខ្ញុំកំពុងលក់ត្រកួននៅឯផ្សារ ហើយខ្ញុំឃើញមនុស្សពីសម័យនោះ ខ្ញុំគេចពីពួកគេ។ ខ្ញុំមិនចង់ឃើញពួកគេទេ ព្រោះខ្ញុំមានអារម្មណ៍ពោរពេញទៅដោយភាពអាម៉ាស់។ ពេលខ្លះ មានអ្នកខ្លះនឹងសួរខ្ញុំ បើទោះជាខ្ញុំមិនចង់លឺក៏ដោយ ថា "អូ ឯណាប្ដីរបស់ឯង? ប្ដីរបស់ឯងដែលឯងបានរៀបការជាមួយនៅសម័យខ្មែរក្រហមនោះ តើឯងមិននៅជាមួយគ្នាទេឬ"? ដូច្នេះ ឥឡូវខ្ញុំទៅផ្សារមួយទៀតដែលគ្មានមនុស្សស្គាល់ខ្ញុំ។ ចាសមែនហើយ អាម៉ាស់។ អាម៉ាស់លើសពីអ្វីដែលខ្ញុំអាចរៀបរាប់បានទៅទៀត"[116] ។*

ការស្ដីបន្ទោសខ្លួនឯង និងភាពឯកោ ការបាត់បង់ឱកាសទទួលបានការចូលរួមពីផ្នែកព្រលឹងវិញ្ញាណ ក្ដីស្រឡាញ់ និងពិធីនៃសេចក្ដីស្រឡាញ់ ការបាត់បង់ការគាំទ្រផ្នែកផ្លូវចិត្ត និងឱកាសសេដ្ឋកិច្ចគឺជាតម្លៃមួយចំនួនដែលស្ត្រីបានចំណាយ ដោយសារតែការមាក់ងាយផ្សារភ្ជាប់ទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់របបខ្មែរក្រហម ដូចដែលបានរៀបរាប់នេះ។

ផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំបានជះដល់កូនៗ។ ប្ដីប្រពន្ធដែលនៅរួមរស់ជាមួយគ្នាក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំ និងដែលមានការរំលោភបំពានបាននិយាយពីការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់នៃអាពាហ៍ពិពាហ៍ និងការរំលោភបំពានដែលមានជាហូរហែរនោះ។ ហ.ក. បាននិយាយថា "ខ្ញុំខ្លាចថា កូនស្រីរបស់ខ្ញុំអាចនឹងរៀបការជាមួយមនុស្សប្រុសអាក្រក់ [ដូចខ្ញុំ] ហើយខ្ញុំខ្លាចថា កូនប្រុសរបស់ខ្ញុំវាយដំកូនប្រសារស្រីរបស់ខ្ញុំ [ដូចជាឪពុកគេវាយដំខ្ញុំដែរ]"[117]។ កូនៗក៏ប្រឈមមុខនឹងការមាក់ងាយ និងការរើសអើងពីសហគមន៍ផងដែរ។ ព.ស. បាននិយាយអំពីកូនរបស់នាងថា "មនុស្សមួយចំនួនក្នុងភូមិមិនចង់ឲ្យកូនរបស់ពួកគេរៀបការជាមួយកូនរបស់ខ្ញុំទេ។ ខ្ញុំបានលឺពាក្យនេះផ្ទាល់នឹងត្រចៀករបស់ខ្ញុំ"[118]។ ហ.អ. បានរៀបរាប់ថា៖

---

[116] ដូចឯកសារខាងលើ។

[117] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៦, ស្រី (ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៤)។

[118] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៥, ស្រី (ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤)។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

*“សព្វថ្ងៃនេះ តើអ្នកដឹងទេ? ខ្ញុំគ្មានអ្វីៗដូចអ្នកដទៃទេ។ ខ្ញុំមិនបានរៀបការដូចមនុស្សស្រីដទៃទៀតទេ ហើយសម្រាប់កូនខ្ញុំ មនុស្សនៅទីនេះតែងតែនិយាយថា “អូ ម្ដាយឯងគឺជាស្ត្រីមេម៉ាយ និងមិនបានរៀបការត្រឹមត្រូវតាមប្រពៃណីទេ”។ ចាសមែនហើយ សង្គមរើសអើងខ្ញុំ ព្រោះខ្ញុំជាស្ត្រីមេម៉ាយ។ ទោះជាឥឡូវនេះខ្ញុំប្រៀបបាននឹងចាស់ទុំម្នាក់ទៅហើយ ក៏គេមិនឲ្យខ្ញុំចូលរួមពិធីមង្គលការតាមប្រពៃណីដែរ ដូចជាពិធីហូបស្លាជាដើម។ [សហគមន៍] នេះមិនអនុញ្ញាតឲ្យខ្ញុំចូលរួមឡើយ ហើយពួកគេបានហៅខ្ញុំថា “ដើមឈើបាក់មែក”។ កូនខ្ញុំក៏ដូចគ្នា។ កូនស្រី និងកូនប្រុសរបស់ខ្ញុំក៏មិនមានអ្នកណាហៅឲ្យចូលរួមក្នុងពិធីជប់លៀងមង្គលការ ធ្វើជាអ្នកកំដរកូនក្រមុំ និងកូនកំលោះនោះដែរ ព្រោះពួកគេគ្មានឪពុក។ សូម្បីតែនៅក្នុងពិធីមង្គលការកូនស្រីរបស់ខ្ញុំផ្ទាល់ ខ្ញុំមិនអាចចូលរួមក្នុងពិធីផ្សេងៗបានទេ ឪពុកម្ដាយរបស់ខ្ញុំជាអ្នកដើរតួជាឪពុកម្ដាយរបស់កូនស្រីខ្ញុំ ហើយគេក៏មិនឲ្យខ្ញុំទទួលផ្កាស្លាដែរ។ ខ្ញុំមិនចង់រំលឹកពីរឿងនេះទាល់តែសោះ។ ខ្ញុំតូចចិត្តនឹងខ្លួនឯងណាស់។ ការគិតអំពីវាធ្វើឲ្យវាហាក់ដូចជារឿងថ្មីដូចនោះដែរ។ រឿងទាំងអស់ព្រោះតែខ្ញុំបានធ្វើខុសនឹងអាពាហ៍ពិពាហ៍នោះ ពោលគឺយើងមិនអាចជ្រើសរើសបាន យើងមិនបានស្គាល់គ្នាមុន យើងមិនសួរឪពុកម្ដាយ ឬសុំស្គាល់ឪពុកម្ដាយ [របស់ដៃគូយើង] យើងគ្មានដឹងអ្វីទាំងអស់ យើងមិនអាចជ្រើសរើសបានឡើយ។ រឿងនេះប៉ះពាល់ទាំងលើកូន និងម្ដាយពេញមួយជីវិតរបស់យើង។ ប្រសិនបើ ប៉ុល ពតមិនបានបង្ខំខ្ញុំឲ្យរៀបការទេ ខ្ញុំអាចនឹងរៀបការតាមបែបប្រពៃណីបាន ហើយកូនរបស់ខ្ញុំ និងខ្ញុំឥឡូវនេះក៏នឹងមានកេរ្តិ៍ឈ្មោះល្អដែរ”*[119] ។

ហ.អ. មិនមែនជាមនុស្សតែម្នាក់ដែលប្រឈមមុខនឹងការមាក់ងាយបែបនោះឡើយ ហើយនាងក៏មិនមែនជាមនុស្សតែម្នាក់ដែលខំប្រឹងយកឈ្នះឧបសគ្គទាំងនោះដែរ ពោលគឺបញ្ហាទាំងនោះក៏ត្រូវបានជួបប្រទះដោយស្ត្រីជាអ្នកផ្ដល់បទសម្ភាសន៍ភាគច្រើន ដែលអាពាហ៍ពិពាហ៍របស់ពួកគេបានបែកបាក់ បន្ទាប់ពីរបបនោះ ។ រឿងរបស់នាងក៏បានគូសបញ្ជាក់ពីការបង្វែរតួនាទីយេនឌ័រភ្លាមៗដោយសារតែអត្រាប្រេវ៉ាឡង់ខ្ពស់នៃស្ត្រីជាមេគ្រួសារ ដែលអាពាហ៍ពិពាហ៍ដោយបង្ខំដែលបែកបាក់នោះបានចូលរួមចំណែកយ៉ាងជាក់ច្បាស់។ ហ.អ. បានពន្យល់ថា៖

*“ខ្ញុំខិតខំប្រឹងប្រែងចិញ្ចឹម [កូនរបស់ខ្ញុំ] ខ្លាំងណាស់ និងបញ្ជូនពួកគេឲ្យទៅសាលារៀន។ ហើយពួកគេទាំងអស់សុទ្ធតែបានបញ្ចប់ថ្នាក់វិទ្យាល័យ ហើយកូនប្រុសរបស់ខ្ញុំឥឡូវនេះកំពុងបន្តការសិក្សានៅទី*

[119] បទសម្ភាសន៍ជាមួយករណីសិក្សាទី ៤, ស្រី (ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*ក្រុងភ្នំពេញ។ ខ្ញុំខិតខំខ្លាំងណាស់ ខិតខំខ្លាំងមែនទែន។ ខ្ញុំមានកង់កញ្ចាស់មួយ ហើយខ្ញុំបានជិះពី កន្លែងមួយទៅកន្លែងមួយដើម្បីរកបន្លែ និងបន្ទាប់មកលក់នៅផ្សារនានាក្នុងក្រុងភ្នំពេញ។ ខ្ញុំរកប្រាក់បានល្មម នឹងអាចបញ្ជូនកូនរបស់ខ្ញុំឱ្យទៅសាលារៀនបានតាមវិធីនេះ។ ចាសមែនហើយ ខ្ញុំមើលមកកូនរបស់ខ្ញុំ ហើយខ្ញុំឃើញក្មេងឯទៀតមានឪពុកគេចិញ្ចឹមពួកគេ ហើយវាកាន់តែងាយស្រួលថែមទៀតតាមវិធីនោះ ។ ប៉ុន្តែ ស្ត្រីមេម៉ាយខ្លះមិនមានលទ្ធភាពផ្គត់ផ្គង់កូនរបស់ពួកគេទេ ដូច្នេះ ខ្ញុំក៏មានមោទនភាពចំពោះខ្លួនឯងដែរ។ ឥឡូវនេះ សូម្បីតែអ្នកភូមិក៏សរសើរខ្ញុំដែរ។ "អូ អ្នកជាស្ត្រីមេម៉ាយទេ ប៉ុន្តែកូនរបស់អ្នកគឺជាកូនល្អ ស្តាប់តាមដំបូន្មានម្តាយ និងមានការងារល្អទៀត។ ដូច្នេះ ខ្ញុំឃើញថា ការខំប្រឹងប្រែងរបស់ខ្ញុំគឺមិនអត់ប្រយោជន៍នោះទេ"*[120] ។

មិនថាគូស្វាមីភរិយាដែលបានរៀបការដោយបង្ខំនោះរួមរស់នៅជាមួយគ្នា ឬបែកគ្នាក៏ដោយ ក៏អាពាហ៍ពិពាហ៍ដោយបង្ខំមានផលវិបាកធំធេងណាស់លើអត្តសញ្ញាណ និងតម្លៃផ្ទាល់ខ្លួន ឋានៈក្នុងសង្គម និងស្ថិរភាពហិរញ្ញវត្ថុរបស់អ្នកនៅនៅរស់រានមានជីវិតជាច្រើននាក់។ អ្នកផ្តល់បទសម្ភាសន៍ជាស្ត្រីជាញឹកញាប់បានរៀបរាប់អំពីការប៉ះទង្គិចផ្លូវចិត្ត ភាពអាម៉ាស់ និងការមាក់ងាយ ដែលជាញឹកញាប់បានបន្តដល់អ្នកជំនាន់ក្រោយទៀត។ ដោយសារតែស្ថានភាពរបស់ស្ត្រីត្រូវបានគេប្រៀបស្មើជាទំនៀមទម្លាប់ទៅនឹងអាពាហ៍ពិពាហ៍ដែលមានការចុះសម្រុងគ្នា និងជីវិតជាលក្ខណៈគ្រួសារ ស្ត្រីបានរៀបរាប់ថា ខ្លួនបានជាក់ជាប់ខ្លួននូវផលវិបាកខាងសង្គម ដែលមានការប៉ះពាល់យ៉ាងខ្លាំងពីគោលនយោបាយនៃរបបខ្មែរក្រហម បើយោងតាមគំរូ។ ជាលទ្ធផលនៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលបែកបាក់ តួនាទីយេនឌ័រត្រូវបានរៀបចំជាថ្មីគួរឱ្យកត់សម្គាល់ ដោយស្ត្រីដើរតួនាទីពីរ គឺជាអ្នកផ្គត់ផ្គង់ និងអ្នកមើលថែទាំ។ ប៉ុន្តែ ទោះបីជាជនរងគ្រោះដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំនេះត្រូវបានគេដកចេញ និងរើសអើងពីសង្គមក្តី (ដោយយោងទៅតាមករណីសិក្សា នៅក្នុងពិធីសាសនា នៅទីផ្សារសេដ្ឋកិច្ច និងនៅក្នុងបណ្តាញសហគមន៍) ក៏ស្ត្រីមួយចំនួនមានលទ្ធភាពក្រោកឡើងធ្វើជាអ្នកសម្រេចចិត្តឯករាជ្យ ដែលបានបើកចន្លោះថ្មីសម្រាប់សម្រេចបាននូវភាពរុងរឿង និងជោគជ័យរបស់ស្ត្រីនៅក្នុងជីវិតនេះ និងជីវិតនៅពេលក្រោយមកទៀត តាមរយៈលក្ខណៈវិនិច្ឆ័យដ៏ធំធេង និងដែលផ្តល់សិទ្ធិអំណាចដល់ពួកគេជាងនេះ។

---

[120] ដូចឯកសារខាងលើ។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

# V.
# កិច្ចពិភាក្សា និងការផ្តល់អនុសាសន៍

Deleted: *Unrevised translation. A revised translation will be provided upon request.*

ការវិភាគខាងក្រោមនេះពិចារណាលើការរកឃើញតាមបែបគុណភាពវិស័យ និងបរិមាណវិស័យ ដែលបានបង្ហាញនៅក្នុងផ្នែកទី IV នៅក្នុងទំនាក់ទំនងនឹងគ្នាទៅវិញទៅមក និងនៅក្នុងបរិបទនៃការស្រាវជ្រាវដែលបានបង្កើតឡើងដូចមានចែងក្នុងផ្នែកទី II។

**១. ការរកឃើញដ៏មានសារៈសំខាន់**

ការរកឃើញដ៏សំខាន់បំផុតដែលបានមកពីការសិក្សានេះគឺថា ក្នុងនាមជាគោលនយោបាយដែលបានផ្តួចផ្តើមឡើងយ៉ាងទូលំទូលាយនៃរដ្ឋខ្មែរក្រហម អាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំបានដកហូតយកសិទ្ធិជាមូលដ្ឋានក្នុងការជ្រើសរើស និងយល់ព្រមពីប្រជាជន។ ក្នុងការធ្វើដូច្នេះ វាបានធ្វើឱ្យវប្បធម៌នៃការរំលោភសេពសន្ថវៈ និងការរំលោភបំពាន ជាពិសេសមកលើស្ត្រីនៅស្ថិតស្ថេរជាប់រហូតដែលអំពើហិង្សាផ្លូវភេទ យេនឌ័រ ជាពិសេសនៅក្នុងអាពាហ៍ពិពាហ៍ និងសម្រាប់ការដាក់ទណ្ឌកម្ម គឺជារឿងធម្មតាតាមរយៈគោលនយោបាយរបស់រដ្ឋ និងដោយមាននិទណ្ឌភាព។ ផលប៉ះពាល់នៃការរំលោភបំពានទាំងនេះបានបន្តឱ្យជនរងគ្រោះមានរហូតមកដល់សព្វថ្ងៃ។

ការរកឃើញសំខាន់ៗផ្សេងទៀតដោយផ្អែកលើការស្រាវជ្រាវនេះត្រូវបានរាយដូចខាងក្រោម។

*អាពាហ៍ពិពាហ៍មុនរបបខ្មែរក្រហម*

- អាពាហ៍ពិពាហ៍បែបប្រពៃណីនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេរៀបចំជាញឹកញាប់បំផុតដោយការយល់ព្រមពីឪពុកម្តាយសម្រាប់កូនរបស់ខ្លួន។ ចំពោះបុរស ដែលជាអ្នកផ្តើមសុំរៀបការជម្រើសត្រូវបានគេផ្តល់ឱ្យ ទាំងបុរស និងស្ត្រីជាទម្លាប់ត្រូវបានគេសុំការយល់ព្រមនឹងការផ្សំផ្គុំនោះមុនពេលមង្គលការកើតមាន។ ខណៈពេលដែលពាក់កណ្តាលនៃអ្នកឆ្លើយសំណួរដែលបានរៀបការមុនរបបខ្មែរក្រហមបានរាយការណ៍ថា អាពាហ៍ពិពាហ៍ដែលរៀបចំជាលក្ខណៈប្រពៃណីរបស់ពួកគេមិនមែនជាជម្រើសរបស់គេទេ គ្មានអាពាហ៍ពិពាហ៍ណាមួយក្នុងចំណោមនេះត្រូវបានគេចាត់ទុកនៅក្នុងគំរូថាជាការគំរាមកំហែងដែរ សូម្បីតែនៅពេលដែលសម្ពាធក្រុមគ្រួសារបានបញ្ចេញឥទ្ធិពលខ្លាំងក៏ដោយ។
- ពិធីមង្គលការតាមប្រពៃណីខ្មែរគឺជាមធ្យោបាយដើម្បីផ្តល់សុពលភាព និងភាពស្របច្បាប់ដល់សហព័ន្ធនៅក្នុងភ្នែករបស់សហគមន៍ ក្រុមគ្រួសារ និងសម្រាប់ពុទ្ធសាសនិកជនភាគច្រើន នៅក្នុងផ្នែកដូនតានេះ។ ជាប្រពៃណី មង្គលការ និងអាពាហ៍ពិពាហ៍ក៏ជាវិធីបង្ហាញនូវការគោរព និងការគោរពប្រតិបត្តិរបស់កូនចំពោះឪពុកម្តាយដែរ ហើយទាំងពិធីអាពាហ៍ពិពាហ៍ក្តី ពិធីមង្គលការក្តីសុទ្ធតែបង្កប់

Deleted: *Unrevised translation. A revised translation will be provided upon request.*

នូវអត្ថន័យខាងស្មារតីទាំងអស់។ ចំពោះពុទ្ធសាសនិកជន រឿងនេះបានរួមបញ្ចូលទាំងផលវិបាកនៃកម្ម ដែលទាក់ទងទៅនឹងជីវិតក្នុងពេលអតីតកាល និងអនាគត។

*អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងរបបខ្មែរក្រហម*

- ការអនុវត្តរបស់រដ្ឋដ៏ទូលំទូលាយ និងជាប្រព័ន្ធនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំដូចដែលបានរៀបរាប់ដោយអ្នកឆ្លើយសំណួរទាំងប៉ុន្មាន គួបផ្សំជាមួយនឹងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ។
- យោងតាមបទសម្ភាសន៍ករណីសិក្សា “អាពាហ៍ពិពាហ៍ដោយបង្ខំ” ត្រូវបានយល់ដោយអ្នកឆ្លើយសំណួរថា វាតំណាងឲ្យបទល្មើសខុសៗគ្នាយ៉ាងហោចណាស់ចំនួនបី៖ ការបាត់បង់សិទ្ធិជ្រើសរើស និងការយល់ព្រម ការបាត់បង់នូវពិធីមង្គលការតាមប្រពៃណីជាមួយក្រុមគ្រួសារ និងការចូលរួមពីវិញ្ញាណក្ខន្ធដូនតា និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំ ដែលមានរយៈពេលពេញមួយរបបនោះ ។
- នីតិវិធីមង្គលការនៃរបបខ្មែរក្រហម គឺជាការប្រាសចាកទាំងស្រុងពីអាពាហ៍ពិពាហ៍ និងមង្គលការតាមបែបប្រពៃណី និងដោយមានការយល់ព្រម។ *អង្គការ*បានដើរតួនាទីជាឪពុកម្តាយរបស់ប្រជាជន។ *អង្គការ*បានផ្សំផ្គុំប្តីប្រពន្ធឲ្យ ហើយកម្មាភិបាលខ្មែរក្រហមបានបង្ខំទាំងហិង្សាឲ្យចូលរួមក្នុងនីតិវិធីពិធីមង្គលការ និងទំនាក់ទំនងសហព័ទ្ធ ដែលជាញឹកញាប់រវាងជនចម្លែក និងជនចម្លែកទាំងស្រុង។ ការចូលរួមរបស់ឪពុកម្តាយ និងពិធីសែនដូនតាត្រូវបានគេដកចេញ ដែលផ្តល់មកវិញជាផលវិបាកនៃកម្ម។
- ការស៊ូទ្រាំនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំគឺមានជាទូទៅ។ ភាគច្រើននៃអ្នកឆ្លើយសំណួរ (៧០,២%) បានបដិសេធចំពោះសំណើសុំឲ្យរៀបការយ៉ាងហោចណាស់ម្តង ប៉ុន្តែនៅទីបញ្ចប់ ស្ទើរតែទាំងអស់ (៩៧,២%) ត្រូវបានគេបង្ខំឲ្យរៀបការ និងស្ទើរតែទាំងអស់ (៩៧.០%) បានរាយការណ៍ថា អាពាហ៍ពិពាហ៍នោះមិនមែនជាជម្រើសរបស់ពួកគេទេ។
- ការពិន័យចំពោះការបដិសេធមិនព្រមរៀបការ ឬដើម្បីចូលរួមក្នុងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំ រួមមានការគំរាមកំហែងដោយពាក្យសម្តី និងការដាក់ទណ្ឌកម្មលើផ្លូវកាយដ៏ពិតប្រាកដដូចជាការវាយដំ ការរំលោភសេពសន្ថវៈ ការធ្វើជាទាសករផ្លូវភេទ និងការសម្លាប់។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

- នីតិវិធីមង្គលការដោយបង្ខំជាទ្រង់ទ្រាយធំ (ពាក់ព័ន្ធនឹងគូស្វាមីភរិយាពី បី ទៅរាប់រយគូ) ត្រូវបានរៀបចំឡើង ជាប្រព័ន្ធ និងនៅពេញប្រទេស ដូចដែលបានរៀបរាប់ដោយអ្នកឆ្លើយសំណួរក្នុងករណីសិក្សាដូច្នោះដែរ។
- បទសម្ភាសន៍ករណីសិក្សាបង្ហាញថា បុរសជាច្រើនមានឱកាសស្នើសុំដៃគូរបស់ខ្លួនក្នុងអំឡុងរបបនេះ ដែលរឿងនេះត្រូវបានលើកឡើងដោយពាក់កណ្ដាលនៃការឆ្លើយតបទាំងអស់។ ពាក់កណ្ដាលនៃការផ្សំផ្គុំផ្សេងទៀតត្រូវបានគេលើកឡើងថាជាការផ្សំផ្គុំតាមអំពើចិត្ត។
- ជិតពាក់កណ្ដាល (៤៦.៥%) នៃអ្នកឆ្លើយសំណួរនៅក្នុងការស្ទង់មតិទាំងអស់បានរាយការណ៍ថា ពួកគេស្គាល់គ្នា ឬដឹងអំពីគ្នានៅពេលរៀបនីតិវិធីមង្គលការនោះតែម្ដង ហើយករណីសិក្សាបានបង្ហាញថា ការស្គាល់គ្នានេះអាចកើតមានតែដោយប្រយោល ឬតាមរយៈបណ្ដាញសង្គម និងសាច់ញាតិប៉ុណ្ណោះ។ លទ្ធភាពដែលអាចរកបាននៃបណ្ដាញបែបនេះអាចនឹងផ្ដល់ប្រយោជន៍ដល់ប្រជាជន "ចាស់" ជាជាងប្រជាជន "ថ្មី" ដែលការប្រព្រឹត្តដាក់ដោយភាពលម្អៀងទៅលើប្រជាជន "ចាស់" ក៏ត្រូវបានលើកឡើងផងដែរនៅក្នុងករណីសិក្សា នៅក្នុងលក្ខខណ្ឌនៃនីតិវិធីមង្គលការនេះឯង។
- ជម្រើសដើម្បីរក្សាជីវិតជាយុទ្ធសាស្ត្រ គឺមានជាទូទៅក្នុងអំឡុងរបបខ្មែរក្រហម ដោយរួមមានការអនុវត្តតាមអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំ ដោយភ័យខ្លាចថានឹងត្រូវគេដាក់ទណ្ឌកម្ម ឬសម្លាប់ចោល។ ជម្រើសទាំងនេះជាធាតុនាំឲ្យមានការប៉ះទង្គិចផ្លូវចិត្ត និងផលវិបាកផ្លូវចិត្តសម្រាប់ស្ត្រីជាពិសេស ដោយសារតែក្រមសីលធម៌វប្បធម៌ដែលគេបដិសេធ និងស្ថានភាពយេនឌ័របន្ទាប់បន្សំ។
- អាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំគឺជាទម្រង់នៃអំពើហិង្សាផ្លូវភេទ យេនឌ័រ។ ហេតុដូច្នោះ ប្រព័ន្ធអាពាហ៍ពិពាហ៍នៅក្រោមរបបខ្មែរក្រហមត្រូវបានគេចាត់ទុកថាស័ក្តិសមនឹងវប្បធម៌នៃការរំលោភសេពសន្ថវៈដែលពង្រឹងដោយរដ្ឋ មានន័យថា ការរំលោភសេពសន្ថវៈត្រូវបានគេចាត់ទុកជារឿងធម្មតា ហើយត្រូវបានប្រព្រឹត្តដោយមាននិទណ្ឌភាពទៀត ពិសេសនៅក្នុងអាពាហ៍ពិពាហ៍ និងចំពោះការដាក់ទណ្ឌកម្ម។ ប្រភេទនៃការរំលោភសេពសន្ថវៈដែលគេបានរៀបរាប់រួមមាន ការរំលោភជាលក្ខណៈប្ដីប្រពន្ធ ការរំលោភជាក្រុម ទាសករផ្លូវភេទ និងការរំលោភដែលជួយដោយ ឬប្រព្រឹត្តដោយភ្នាក់ងាររបស់រដ្ឋ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

- អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកខ្មែរក្រហម អាចនឹងជាលក្ខណៈពិសេស ដោយសារស្វាមីបង្ខំរំលោភប្រពន្ធរបស់គេជាមធ្យោបាយដែលធានាឱ្យពួកគេនៅរស់រានមានជីវិត។ ករណីសិក្សាមួយបានរៀបរាប់ថា កម្មាភិបាលខ្មែរក្រហមបានជួយ និងញុះញង់ឱ្យប្ដីដែលគេផ្សំផ្គុំឱ្យនោះរំលោភប្រពន្ធរបស់គេ។
- ជិតមួយភាគបួន (២៤,៥%) នៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងអស់ត្រូវបានរាយការណ៍ថាពាក់ព័ន្ធនឹងការរំលោភបំពានលើដៃគូ។ អាពាហ៍ពិពាហ៍ទាំងនោះមាននៅក្នុងអំឡុងពេលលំបាកៗបំផុតផ្សេងទៀតនៃរបបដ៏ឃោរឃៅនេះ បន្តមានរហូតផុតពីរបបនោះ និងមួយចំនួនទៀតមិនបែកបាក់រហូតដល់ថ្ងៃនេះ។
- ភាគច្រើននៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងអស់ (៧៦,២%) ត្រូវបានគេរាយការណ៍ថាបានបណ្ដាលឱ្យមានកំណើតកូន ដែលជិតពាក់កណ្ដាលនៃអ្នកឆ្លើយសំណួរ (៤៤,៩%) មានកូនបួននាក់ឬលើសពីបួន។ ពេលខ្លះ ប្ដីត្រូវបានគេលើកឡើងថាជាអ្នកផ្ដល់ការផ្គត់ផ្គង់ដ៏សំខាន់ដល់ការរស់រានរបស់ប្រពន្ធនៅពេលពរពោះផងដែរ។
- ករណីសិក្សាទាំងអស់ បង្ហាញពីការកើនឡើងដល់ចំណុចកំពូលនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅឆមាសទីពីរនៃឆ្នាំ ១៩៧៨។
- ករណីសិក្សាទាំងអស់ ចង្អុលបង្ហាញពីការបន្តពូជប្រជាជនថាជាការជំរុញឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា អ្នកឆ្លើយសំណួរក្នុងករណីសិក្សាមួយបានចាត់ទុកមហិច្ឆិតានយោបាយរបស់មេដឹកនាំខ្មែរក្រហមក្នុងតំបន់ ថាជាការជំរុញឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហព័ទ្ធដែលត្រូវបានបង្ខំ ដោយបង្ហាញថា ពួកមេដឹកនាំថ្នាក់ខ្ពស់ៗបានដឹង និងលើកទឹកចិត្តឱ្យមានការអនុវត្តគោលនយោបាយនេះទៀតផង។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*អាពាហ៍ពិពាហ៍បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម*

- បន្ទាប់ពីការដួលរលំនៃរបបនេះ គ្មានគោលនយោបាយជាតិទូទៅណាមួយបានកើតចេញដើម្បីដោះស្រាយស្ថានភាព និងផលវិបាកនៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះទេ។ ប៉ុន្តែ អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកខ្មែរក្រហម បានជះផលប៉ះពាល់យ៉ាងខ្លាំងលើការអនុវត្តធ្វើពិធីអាពាហ៍ពិពាហ៍ភ្លាមៗបន្ទាប់ពីរបបនេះបានដួលរលំទៅ និងជាច្រើនទសវត្សរ៍ក្រោយមកទៀត។
- ការស្រាវជ្រាវនេះបង្ហាញថា អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាកត្តាមួយរួមចំណែកឲ្យមានការកើនឡើងនៃការរំលោភបំពានក្នុងគ្រួសារ (នៅក្នុងបរិបទនៃសង្គ្រាមស៊ីវិលដែលនៅតែបន្ត និងការកេណ្ឌប្ដីឲ្យចូលបម្រើជាកងទ័ព) និងអត្រាខ្ពស់នៃការរត់ចោលប្ដី ឬប្រពន្ធ ការមានប្ដី ឬប្រពន្ធច្រើន ការរៀបការម្ដងទៀត និងស្ត្រីជាមេគ្រួសារក្រោយពីការដួលរលំនៃរបបដឹកនាំទៅ។
- ច្រើនជាងពាក់កណ្ដាលនៃអ្នកឆ្លើយសំណួរទាំងអស់ (៥៣,១%) បាននៅរួមរស់ជាមួយគ្នាក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួន បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ដែលភាគច្រើនត្រូវបានជំរុញដោយកូនៗដែលកើតចេញពីអាពាហ៍ពិពាហ៍នេះ ដូចដែលបានរៀបរាប់ក្នុងករណីសិក្សា។ ការជំរុញផ្សេងទៀតដែលឲ្យពួកគេរួមរស់នៅជាមួយគ្នាក្នុងអាពាហ៍ពិពាហ៍នោះរួមមាន ការអាណិតអាសូរផលវិបាកនៃកម្មដែលឆ្លងដល់ជំនាន់ក្រោយៗ ទំហំធំធេងនៃការឆ្លងកាត់បទពិសោធន៍ដែលប៉ះទង្គិចផ្លូវចិត្តរួមគ្នាក្នុងអំឡុងពេលនៃរបបនោះ និងនិយាយរួមទៅគឺក្ដីស្រឡាញ់។ អាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់មួយចំនួននៅមានដោយសារតែការរំលោភបំពាន ដែលដៃគូមិនអាចរត់គេចចេញបាន។
- អាពាហ៍ពិពាហ៍ដោយបង្ខំដែលមិនបែកបាក់ជាច្រើន ត្រូវបានរាយការណ៍ថាមានដំណើរការមិនល្អ ដែលមានជាងពាក់កណ្ដាល (៥២,៩%) នៅក្នុងគំរូនៃការស្ទង់មតិ ដោយបានលើកឡើងពីការរំលោភបំពានរបស់ដៃគូ ពោលគឺមួយករណី ដូចដែលបានពិភាក្សារួចនៅក្នុងការវិភាគករណីសិក្សាកំពុងជួបប្រទះនឹងការរំលោភរបស់ដៃគូដែលបន្តរហូតមកដល់សព្វថ្ងៃនេះ។
- ភាគច្រើន (៧០.០%) នៃអ្នកទាំងនោះដែលបែកបាក់ចំណងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេបន្ទាប់ពីរបបនេះ នៅទីបំផុតបានរៀបការម្ដងទៀត។ ក្នុងចំណោមអ្នកដែលមិនបានរៀបការម្ដងទៀតបន្ទាប់ពីរបបនេះ ៧២,២% បានរាយការណ៍ថា ពួកគេមិនចង់រៀបការជាថ្មីម្ដងទៀតឡើយដោយសារតែបទពិសោធន៍ជាមួយនឹងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេនោះ។ ខណៈពេលដែលការឆ្លើយសំណួររួមបញ្ចូលទាំងអ្នកឆ្លើយសំណួរជាបុរស និងជាស្ត្រី ការរកឃើញនេះគឺមានសារៈ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

សំខាន់ណាស់នៅពេលប្រៀបធៀបទៅនឹងអាពាហ៍ពិពាហ៍ស្មើរតែជាទូទៅរបស់ស្ត្រី នៅមុនរបបខ្មែរក្រហមដូចដែលបានរៀបរាប់ដោយការស្រាវជ្រាវលើកមុន។

*ផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហម*

- ប្រព័ន្ធអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហមបណ្តាលឱ្យមានការដកចេញពីសង្គម និងការរើសអើងក្នុងសង្គម ជាពិសេសសម្រាប់ស្ត្រីដែលត្រូវបានគេបោះបង់ចោល លែងលះគ្នា ស្ថិតក្នុងអាពាហ៍ពិពាហ៍ដែលប្តីមានប្រពន្ធច្រើន ឬជាស្ត្រីមេម៉ាយ។ ករណីសិក្សាបង្ហាញថា ផលប៉ះពាល់ទាំងនេះបានបន្តជាផលប៉ះពាល់អន្តរជំនាន់ និងបណ្តាលឱ្យមានការលំបាកខាងសេដ្ឋកិច្ចនៅក្នុងករណីជាច្រើន។
- ភាគច្រើននៃអ្នកឆ្លើយសំណួរទាំងអស់ (៧០,២%) បានរាយការណ៍អំពីបញ្ហាសុខភាពផ្លូវចិត្តដែលមានបន្តជាប់រហូតដោយសារតែអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ដោយបានលើកឡើងពីការឈឺចាប់ និងកំហឹងពីការដែលត្រូវគេបង្ខំឱ្យរៀបការនេះ។ លើសពីនេះទៀត អ្នកឆ្លើយសំណួរច្រើនជាងមួយភាគបី (៣៥,៤%) បានលើកឡើងពីផលវិបាកផ្នែកសេដ្ឋកិច្ចអវិជ្ជមានដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។
- ខណៈពេលដែលអ្នកឆ្លើយសំណួរភាគច្រើនបានលើកឡើងថា ខ្លួនមិនបានលាក់រឿងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពីអ្នកដទៃ ករណីសិក្សាទាំងអស់បានបំភ្លឺពីការខកចិត្តដែលបានកប់ទុក និងភាពអាម៉ាសដែលជនរងគ្រោះជាច្រើនមានជាប់មកជាមួយ ដែលជាលទ្ធផលនៃការផ្សំផ្គុំដែលគេបានរៀបចំឱ្យនោះ។ ឪពុកម្តាយ ជាពិសេស បានរាយការណ៍នៅក្នុងករណីសិក្សាអំពីការលំបាកក្នុងការចែករំលែករឿងពិតអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនោះជាមួយនឹងកូនៗ ដែលកើតចេញពីសហព័ន្ធនោះ។ ក្នុងចំណោមអ្នកដែលមិនបានចែករំលែកបទពិសោធន៍នៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេជាមួយអ្នកដទៃនោះ ច្រើនជាងពាក់កណ្តាល (៥២,៦%) បានប្រាប់ថា ខ្លួនមានអារម្មណ៍អាម៉ាស់ រីឯច្រើនជាងមួយភាគបី (៣៦,៨%) បានប្រាប់ថា ខ្លួនមានការភ័យខ្លាចនឹងការមាក់ងាយ និងការរើសអើង។
- អាពាហ៍ពិពាហ៍ដោយបង្ខំបន្ទាប់ពីការដួលរលំនៃរបបនេះ បានរួមចំណែកដល់ការផ្លាស់ប្តូរទាំងស្រុងនូវតួនាទី និងទំនួលខុសត្រូវយេនឌ័រ។ ស្ត្រីនៅដែលជាមេគ្រួសារ ជាពិសេស បានទទួលរងនូវបន្ទុកបន្ថែមទៀត សូម្បីតែខ្លួនកំពុងជួបប្រទះនឹងភាពលំបាកខាងសង្គម និងសេដ្ឋកិច្ច ការចិញ្ចឹមកូន និងការថែទាំមនុស្សចាស់ហើយក៏ដោយ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01037027-01037085
Translated: [01037039-01037060]; [01037064-01037080]

- ការរកឃើញនៃការស្រាវជ្រាវនេះបង្ហាញថា ជនរងគ្រោះគឺនៅតែត្រូវការការគាំទ្រ និងសេវាសង្គមក្នុងរយៈពេលវែងដដែល។ ការប្តេជ្ញាចិត្តរបស់ម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិនៅតែជាសេចក្តីត្រូវការដ៏ចាំបាច់មួយសម្រាប់គម្រោងដែលរៀបចំជាកម្មវិធី និងដែលផ្អែកលើការស្រាវជ្រាវក្នុងការគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវា។
- ទោះបីជាមានសោកនាដកម្មពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះក្តី មនុស្សជាច្រើនបានសម្រេចកែទម្រង់ជីវិតរបស់ពួកគេដោយជោគជ័យរួចហើយដែរ ដោយជាញឹកញាប់មានការគាំទ្រពីក្រុមគ្រួសារ និងតាមរយៈការពឹងផ្អែកលើខ្លួនឯង។ ការរកឃើញនេះបានចង្អុលបង្ហាញជាជាពិសេសអំពីភាពក្លៀវក្លារបស់ស្រ្តីកម្ពុជា និងតម្រូវការក្នុងការវាយតម្លៃឡើងវិញពីតួនាទីយេនឌ័រ និងផ្នត់គំនិតខាងវប្បធម៌ដ៏តឹងរ៉ឹងដែលនៅតែបន្តជះឥទ្ធិពលដដែល។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

## ២. អនុសាសន៍

អាពាហ៍ពិពាហ៍គឺជាស្ថាប័នមួយដែលមានមុខងារដូចតទៅ៖ វាផ្លាស់ប្តូរឋានៈ តួនាទី សិទ្ធិ និងទំនួលខុសត្រូវ ដូចដែលបានជូនដំណឹងដោយការអនុវត្តវប្បធម៌ និងការកំណត់អត្តសញ្ញាណយេនឌ័រ។ អាពាហ៍ពិពាហ៍ដោយបង្ខំដែលបានផ្តួចផ្តើមឡើងដោយរបបខ្មែរក្រហម តំណាងឲ្យអំពើហិង្សាផ្លូវភេទ យេនឌ័រជាមួយនឹងផលប៉ះពាល់យ៉ាងធំធេង។ គោលនយោបាយខ្មែរក្រហមគឺជាបទឧក្រិដ្ឋមួយប្រឆាំងនឹងមនុស្សជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ក្នុងការលើកយកមកកាត់ទោស និងតាមរយៈការផ្តល់សំណងគ្រប់គ្រាន់ និងមានប្រសិទ្ធភាព។ លើសពីនេះទៀត អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាទុក្ខលំបាកសម្រាប់ការអភិវឌ្ឍរបស់រដ្ឋាភិបាលកម្ពុជា ដោយសារតែអាពាហ៍ពិពាហ៍ដោយបង្ខំដែលមានការរំលោភបំពាននៅតែបន្តមិនបែកបាក់ ដោយសារតែស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារដែលបណ្តាលមកពីអាពាហ៍ពិពាហ៍ដោយបង្ខំកាន់តែចាស់ទៅ ដោយមិនមានបណ្តាញសុវត្ថិភាពគ្រប់គ្រាន់ ហើយដោយសារកូនដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះត្រូវជួបប្រទះនឹងការប៉ះទង្គិចផ្លូវចិត្តអន្តរជំនាន់ និងផលវិបាកអវិជ្ជមានខាងសង្គមសេដ្ឋកិច្ចផ្សេងៗទៀត។

### ក. រាជរដ្ឋាភិបាលកម្ពុជា

- ផ្តួចផ្តើមឲ្យមានកាកែខៃ និងការផ្តល់សំណងដល់ជនរងគ្រោះពីអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានសំណងហិរញ្ញវត្ថុ និងសេវាគាំទ្រផ្លូវចិត្តផ្សេងៗទៀតសម្រាប់អ្នកដែលនៅរស់រានមានជីវិតពីអាពាហ៍ពិពាហ៍ដោយបង្ខំរបស់របបខ្មែរក្រហម ឲ្យស្របជាមួយនឹងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភទ្រង់ទ្រាយធំលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សជាតិអន្តរជាតិ ព្រមទាំងសេចក្តីប្រកាសទីក្រុងណៃរ៉ូប៊ីស្តីពីសិទ្ធិស្ត្រី និងក្មេងស្រីក្នុងការទទួលបានដំណោះស្រាយ និងសំណង។
- ចងក្រងឯកសារអំពីភាពរីកចម្រើន នៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) នាពេលខាងមុខ និងសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗទៀតដែលរាយការណ៍អំពីការលើកកម្ពស់ស្ថានភាព និងសមភាពយេនឌ័ររបស់ស្ត្រីខ្មែរ ជាពិសេសនៅក្នុងលក្ខខណ្ឌនៃការប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតយេនឌ័រខាងវប្បធម៌ដ៏តឹងរ៉ឹង ហើយនៃការអនុវត្តការផ្តល់

Deleted: *Unrevised translation. A revised translation will be provided upon request.*

សំណាង ដែលបានអំពាវនាវនៅក្នុងសេចក្តីសង្កេតចុងក្រោយនៃគណៈកម្មាធិការ CEDAW ឆ្នាំ ២០១៣។

- ប្តេជ្ញាចិត្តមិនឱ្យមានបទឧក្រិដ្ឋដែលទាក់ទងនឹងយេនឌ័រជាថ្មីម្តងទៀត នៅក្នុងពេលមានជម្លោះ និងក្រោយជម្លោះ ដោយអភិវឌ្ឍផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខឱ្យស្របជាមួយនឹង UN SCR 1325 និងដំណោះស្រាយបងប្អូនរបស់វា។ និងដូចដែលបានអំពាវនាវនៅក្នុងសេចក្តីសង្កេតចុងក្រោយនៃគណៈកម្មាធិការ CEDAW ឆ្នាំ ២០១៣។
- រួមបញ្ចូលអាពាហ៍ពិពាហ៍ដោយបង្ខំជាផ្នែកមួយនៃការផ្តោតការយកចិត្តទុកដាក់ នៅក្នុងគម្រោងអភិវឌ្ឍ រួមមានផែនការសកម្មភាពជាតិស្តីពីការលើកកម្ពស់ស្ត្រី (NAPWA) និងផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី (NAPVAW)។ សង្កត់ធ្ងន់ទៅលើការគាំទ្រផ្លូវចិត្ត និងសេដ្ឋកិច្ចសម្រាប់ក្រុមជនរងគ្រោះដែលមានវ័យចំណាស់ និងកូនរបស់ពួកគេ។

Deleted: *Unrevised translation. A revised translation will be provided upon request.*